ការ
តាំងសញ្ញានៃការអធិស្ឋាន
សម្រាប់កុមារ

ព្រះគុណ	ឱ ព្រះវរបិតាដែលគង់នៅស្ថានសួគ៌អើយ សូមអរព្រះគុណចំពោះការស្រលាញ់ទូលបង្គំ ហើយធ្វើអោយទូលបង្គំក្លាយជាកូនម្នាក់របស់ទ្រង់។
សេចក្តីស្រឡាញ់	សូមជួយទូលបង្គំឲ្យស្រឡាញ់ និងស្តាប់បង្គាប់ទ្រង់។
ការអាណិតអាសូរ	សូមជួយទូលបង្គំអោយចេះស្រលាញ់អ្នកដទៃ តាមរបៀបដែលព្រះអង្គស្រលាញ់ដល់ទូលបង្គំ។
ការប្រែចិត្ត	ទូលបង្គំសោកស្តាយចំពោះអំពើបាបរបស់ទូលបង្គំ សូមលាងសំអាតទូលបង្គំអោយបានស្អាត។
ការថ្វាយបង្គំ	ទូលបង្គំនឹងសរសើរទ្រង់ដោយអស់ពីដួងចិត្តទូលបង្គំ!
ការប្តេជ្ញាចិត្ត	ព្រះយេស៊ូវអើយ ទូលបង្គំចង់ដើរតាមទ្រង់ ធ្វើជាព្រះអង្គម្ចាស់របស់ទូលបង្គំ សូមកែច្នៃទូលបង្គំតាមទ្រង់សព្វព្រះហឫទ័យ។
ការពឹងផ្អែក	សូមបំពេញទូលបង្គំដោយព្រះវិញ្ញាណបរិសុទ្ធនៃទ្រង់។ ទូលបង្គំចង់ស្គាល់ផែនការរបស់ទ្រង់សម្រាប់ទូលបង្គំ។
ឥទ្ធិពល	សូមកែទូលបង្គំធ្វើជាអ្នកនាំសារនៃព្រះគុណ សេចក្តីពិត និងសេចក្តីយុត្តិធម៌របស់ទ្រង់។
ភាពជាសិស្ស	សូមប្រើទូលបង្គំសម្រាប់ជាសិរីល្អរបស់ទ្រង់ និងដើម្បីនាំអ្នកផ្សេងទៀតឲ្យគេមកតាមទ្រង់។
សិទ្ធិអំណាច	អធិស្ឋានក្នុងព្រះនាមព្រះយេស៊ូវគ្រីស្ទ។ អាម៉ែន។

ខព្រះគម្ពីរចងចាំ

ប្រស្នាអំពីចៀមដែលបាត់ លូកា ១៥.១-៧ | មើល សេចក្តីស្រឡាញ់យ៉ាងណាហ្ន ដែលព្រះវរបិតាបានផ្តល់មកយើងរាល់គ្នា ឲ្យយើងបានហៅថាជាកូនរបស់ព្រះដូច្នេះ ។ —១យ៉ូហាន ៣.១

រឿងលោកអ័ប្រាហាំ លោកុប្បត្តិ ១២.១-៥ | ៣៧ នោះព្រះយេស៊ូវឆ្លើយថា «ត្រូវឲ្យស្រឡាញ់ព្រះអម្ចាស់ ជាព្រះនៃឯងឲ្យអស់អំពីចិត្ត អស់អំពីព្រលឹង ហើយអស់អំពីគំនិត —។ ម៉ាថាយ ២២.៣៧-៣៨

អ្នកស្រុកសាម៉ារីមានចិត្តសប្បុរសម្នាក់ លូកា ១០.២៥-៣៧ | នេះជាសេចក្តីបញ្ញត្តិរបស់ខ្ញុំ គឺឲ្យអ្នករាល់គ្នាស្រឡាញ់ដល់គ្នាទៅវិញទៅមក ដូចជាខ្ញុំបានស្រឡាញ់អ្នករាល់គ្នាដែរ ។ — យ៉ូហាន ១៥.១២

ប្រស្នាអំពីបាវបំរើដែលបានអត់ទោសឲ្យ ម៉ាថាយ ១៨.២១-៣៥ |
សូមលាងទូលបង្គំឲ្យយ៉ាងស្អាត ពីអំពើទុច្ចរិតរបស់ទូលបង្គំផង
សូមលាងសំអាតអំពើបាបរបស់ទូលបង្គំ ។ —ទំនុកដំកើង ៥១.២

រឿងកំណើតព្រះយេស៊ូវ លូកា ២.១-២០ | ខ្ញុំនឹងសរសើរដល់ព្រះយេហូវ៉ាអស់ពីចិត្តខ្ញុំ ខ្ញុំនឹងប្រាប់អំពីការអស្ចារ្យទាំងអស់របស់ទ្រង់។ —ទំនុកដំកើង ៩.១

ពេត្រុសមិនគ្រប់លក្ខណ៍ លូកា ២២.៥៤-៦២ | រួចទ្រង់មានព្រះបន្ទូលទៅមនុស្សទាំងអស់ថា បើអ្នកណាចង់មកតាមខ្ញុំ ត្រូវឲ្យអ្នកនោះលះកាត់ចិត្តខ្លួនឯង ទាំងផ្ទុកឈើឆ្កាងខ្លួនរាល់តែថ្ងៃ ហើយមកតាមខ្ញុំចុះ។ —លូកា ៩.២៣

អ្នកកំសាន្តចិត្ត យ៉ូហាន ១៤.១៥-៣១ | សូមឲ្យបានពេញជាព្រះវិញ្ញាណវិញ។ —អេភេសូ ៥.១៨ខ

ព្រះយេស៊ូវ និងក្មេងតូចៗ ម៉ាថាយ ១៨.១-៦ | យើងរាល់គ្នាបានឃើញសិរីល្អទ្រង់ គឺជាសិរីល្អនៃព្រះរាជបុត្រាតែ១ ដែលមកពីព្រះវរបិតា មានពេញជាព្រះគុណ និងសេចក្តីពិត។ —យ៉ូហាន ១.១៤

សុលមកពីតើស៊ីសត្រូវបានប្តូរឈ្មោះជាប៉ុល កិច្ចការ ៩.១-២២ | ដូច្នេះ សូមទៅបញ្ចុះបញ្ចូលឲ្យមានសិស្សនៅគ្រប់ទាំងសាសន៍ ព្រមទាំងធ្វើបុណ្យជ្រមុជទឹកឲ្យដោយនូវព្រះនាមព្រះវរបិតា ព្រះរាជបុត្រា និងព្រះវិញ្ញាណបរិសុទ្ធចុះ។ ម៉ាថាយ ២៨.១៩

មនុស្សខ្វាក់ម្នាក់ឈ្មោះបារទីមេ ម៉ាកុស ១០.៤៦-៥២ | ដោយហេតុនោះបានជាព្រះបានលើកទ្រង់ឡើងយ៉ាងខ្ពស់ ហើយបានប្រទានឲ្យមាននាមដ៏ប្រសើរ លើសជាងអស់ទាំងនាមផង។ ភីលីព ២.៩

ការ
តាំងសញ្ញា នៃការអធិស្ឋាន
សម្រាប់កុមារ

| បង្រៀនកុមាររបៀបអធិ ស្ឋាន!

ខេនឌី ម៉ាបេលី
ជាមួយនឹ ង ស្ទេផាន អេរី

សេចក្តី ពន្យល់ ដោយ លូកា ផ្លៅវ៉ រ | បុព្វកថា ដោយ ជើ រី គី ក

The Prayer Covenant Inc.
P.O. Box 40841
Cincinnati, OH 45240
www.theprayercovenant.org

Copyright © 2014 by Candy Marballi. All rights reserved.
©2018 The Prayer Covenant for Children/Games provided by GameLife77.com. All rights reserved.

All rights reserved. No part of this book may be produced by any means, electronic, mechanical, photocopying, scanning, or otherwise, without permission in writing from the publisher, except by a reviewer, who may quote passages in a review. The Prayer Covenant Card may be copied but not altered, edited, or amended and is also available online with free downloads at **www.theprayercovenant.org/children**.

Materials to supplement *The Prayer Covenant for Children* are available at www.theprayercovenant.org, including free multiple-language versions of *The Prayer Covenant Children prayer* cards, *The Prayer Covenant for Children* 24 page booklet and *The Prayer Covenant for Children Coloring Book*. Special discounts are available for bulk purchases.

Unless otherwise stated, biblical quotations are taken from THE HOLY BIBLE, NEW INTERNATIONAL VERSION®, NIV®
Copyright © 1973, 1978, 1984, 2011 by Biblica, Inc.™ Used by permission. All rights reserved worldwide.

Khmer Translator: អេរ៉ៀម សំឆួល និង កែង ម៉ុនណេរ

Design by Sound Press and Granite Creative, inc

ISBN 978-0-9899525-8-3

តារាងមាតិការ

ការអធិស្ឋានសម្រាប់កុមារ ១
បដិលេខ ៦
ការដឹងគុណ ៨
បុព្វកថា ៩
សេចក្តីផ្តើម ១០
មេរៀនសាមញ្ញ ១២

ព្រះគុណ ១៨
សេចក្តីស្រឡាញ់ ២៦
ការអាណិតអាសូរ ៣៤
ការប្រែចិត្ត ៤២
ការថ្វាយបង្គំ ៥០
ការប្តេជ្ញាចិត្ត ៥៨
ការពឹងផ្អែក ៦៦
ឥទ្ធិពល ៧៤
ភាពជាសិស្ស ៨២
សិទ្ធិអំណាច ៩០

ការកត់ទុកការតាំងសញ្ញានៃការអធិស្ឋានរបស់ខ្ញុំ ៩៨
ទំព័រជាត់ពណ៌ ៩៩
ធ្វើចលនាដៃពីការបង្កើត រហូតព័ន្ធកិច្ចរបស់ព្រះគ្រីស្ទ ១០៩

បដ្ឋិ លេខ

វាជាអំណរ និងការគោរពដល់ Biblica-សមាគមព្រះគម្ពីរអន្តរជាតិ ដែលបានក្លាយជាដៃគូរ លើការតាំងសញ្ញានៃការអធិស្ឋានសម្រាប់កុមារ។ កុមារមិនត្រឹមតែជាអ្នកដឹកនាំពួកជំនុំថ្ងៃអនាគតប៉ុណ្ណោះទេ ពួកគេភាគច្រើន ថែមទាំងជាអ្នកចូលរួមក្នុងពួកជំនុំជុំវិញពិភពលោកសព្វថ្ងៃនេះផងដែរ។ ការអធិស្ឋានសម្រាប់កុមារមានកទ្ធិពលខ្លាំង និងផ្តល់ផលអស់កល្បដែរ ដែលតាមរយៈពួកគេ នោះមនុស្សជុំវិញពិភពលោកនឹងស្គាល់ព្រះគ្រីស្ទផងដែរ។ សៀវភៅនេះក៏នឹងជួយបំពេញកិច្ចការនោះផងដែរ!

– លោក ទ្បារេអ៊ូ អេនឌើសាន់ នាយកជាន់ខ្ពស់ភាពជាដៃគូសកល នៃ BIBLICA-សមាគមព្រះគម្ពីរអន្តរជាតិ។

កទ្បូវនេះ ជាពេលដែលត្រូវតម្រង់ភ្នែករបស់យើងទៅកាន់កុមារ ដែលពួកគេជាមនុស្សជំនាន់ថ្មីនៃអ្នកផ្លាស់ប្រែពិភពលោក ដែលពិភពលោកកំពុងរង់ចាំទទួលយកការបញ្ចេះដោយសេចក្តីជំនឿ។ ការតាំងសញ្ញានៃការអធិស្ឋានសម្រាប់កុមារ ជាពន្លឺដូចជាកុងតាក់ភ្លើង ដែលកំពុងដើរតួយ៉ាងសំខាន់សម្រាប់ការផ្លាស់ប្តូរ។ តាមរយៈការអធិស្ឋាន កុមារកំពុងតែត្រូវបានផ្តោតការយកចិត្តទុកដាក់ និងកំពុងផ្លាស់ប្រែជីវិតរបស់ពួកគេ។ ការតាំងសញ្ញានៃការអធិស្ឋានសម្រាប់កុមារ គឺកំពុងក្លាយជាឧបករណ៍សំខាន់មួយ ដើម្បីលើកកម្ពស់កុមារទាំងសកលក្នុងពេលព្រមគ្នា ខណៈពេលដែលយើងបាត់បង់គុណតម្លៃស្នូ លដ៏សំខាន់របស់ពួកគេ នោះគឺការអធិស្ឋាន ដែលព្រះយេស៊ូវបានបង្រៀន។ ការតាំងសញ្ញានៃការអធិស្ឋាន ជាការត្រាស់ហៅមកពីព្រះ ហើយលោកស្រី ខេនឌី ម៉ាបេលី ក៏បានសរសេរទុកក្នុងសៀវភៅរបស់គាត់ផងដែរ។

– លោក ល្វីស ប៊ូស អ្នកសម្របសម្រួលអន្តរជាតិ TWC អ្នកបំរើស្មោះត្រង់ ការបំផ្លាស់បំប្រែពិភពលោក ២០២០ សហស្ថាបនិកចលនា4/14 ជាមួយនឹងគ្រូគង្វាល ណាម ស៊ូ គឹម

ការតាំងសញ្ញានៃការអធិស្ឋានសម្រាប់កុមារ គឺជាការពុះពារជំនៈឧបសគ្គ ដែលនឹងចងដួងចិត្តកុមារ ក្នុងបេសកកម្ម ដើម្បីជំរុញឲ្យការរីកចម្រើនក្នុងនគរព្រះ តាមរយៈការអធិស្ឋានរបស់ពួកគេ។ អរគុណដល់ លោកស្រី ខេនឌី សម្រាប់សៀវភៅដែលមានប្រសិទ្ធភាពនេះ។

– លោក ហ្គារី ហ្រ្វូ ស អនុប្រធាន តំបន់បច្ចឹមកណ្តាល និងប្រធានបេសកកម្មអាមេរិកខាងជើង។

ការតាំងសញ្ញានៃការអធិស្ឋានសម្រាប់កុមារ ជាសៀវភៅដ៏អស្ចារ្យណាស់! អំណាចនៃការផ្តោតលើ ភាពច្បាស់លាស់ និងមានភាពសាមញ្ញដែលងាយយល់ វាជាអំណោយយ៉ាងសំខាន់ ក្នុងរូបកាយរបស់ព្រះគ្រីស្ទ! ខ្ញុំជឿថា ព្រះជាម្ចាស់នឹងប្រើសៀវភៅនេះ ដើម្បីជួយឲ្យក្មេងជំនាន់ក្រោយ ឲ្យមានចិត្តអធិស្ឋានយ៉ាងក្លៀវក្លា ចាក់គ្រឹះមាំក្នុងព្រះបន្ទូ លព្រះ និងការលះបង់ក្នុងការបំរើព្រះ ដើម្បីថ្វាយសិរីល្អដល់ទ្រង់! ក្នុងនាមជាឌីពុក និងគ្រូគង្វាលនៃសេចក្តីអធិស្ឋាន ខ្ញុំណែនាំទទូច សម្រាប់ការប្រើប្រាស់សៀវភៅមួយនេះ! ចូរយើងដើរតាមព្រះគ្រីស្ទជាមួយគ្នា ដោយការអធិស្ឋាន ជាមួយនឹងកូនៗរបស់យើងទាំងអស់គ្នា!

– បណ្ឌិត ចេសាន់ ហ៊ុបបាដ នាយកមជ្ឈមណ្ឌលពន្លឺនៃការអធិស្ឋានពិភពលោក

សៀវភៅនេះគឺជាមគ្គុទេសដែលបានពន្យល់យ៉ាងក្បោះក្បាយ និងជាមគ្គុទេសអធិស្ឋាន សម្រាប់កុមារនៅជុំវិញពិភពលោក សម្រាប់ពួកជំនុំ សាលារៀន និងតម្រូវការរបស់គ្រួសារ។ សៀវភៅនេះក៏កំពុងផ្សាភ្ជាប់យ៉ាងល្អ ទៅនឹងការអនុវត្តជាក់ស្តែងរបស់អ្នកសិក្សាផងដែរ។

– លោក រូបឺត មើកដូណាល់ អគ្គនាយកដែលបានចូលនិវត្តន៍ ប្រធាន

ការតាំងសញ្ញានៃការអធិស្ឋានសម្រាប់កុមារ កំពុងផ្សាភ្ជាប់យ៉ាងអាប់រហ័សផងដែរ។ គ្រូបង្រៀនអាចយកវាមកប្រើប្រាស់បាន និងជាមេរៀន ដែលមានតុល្យភាពរវាងការអធិស្ឋាន សិក្សាព្រះគម្ពីរ និងការអនុវត្តជាក់ស្តែងបានយ៉ាងល្អ។ សៀវភៅនេះ ជាសៀវភៅមួយក្នុងចំណោមសៀវភៅកុមារដែលលក់ដាច់បំផុត។ ហើយការតាំងសញ្ញានៃការអធិស្ឋាន ផ្តល់នូវគុណតម្លៃពិសេស ដល់ថ្នាក់បង្រៀនកុមារថ្ងៃអាទិត្យប្រកបដោយប្រសិទ្ធភាព។ ខ្ញុំសូទ្បាញ់ ការតាំងសញ្ញានៃការអធិស្ឋានសម្រាប់កុមារនេះណាស់ ព្រោះវាបង្ហាញផ្លូ វឲ្យកុមារមានការសន្ទនាជាមួយព្រះដ៏អស្ចារ្យ និងមានកទ្ធិពល ហើយពេលពួកគេអាចយល់សេចក្តីពិតក្នុងព្រះគម្ពីរយ៉ាងស៊ីជម្រៅ ដែលសាមញ្ញងាយយល់ និងមានការល្បែងកំសាន្តសប្បាយៗផងដែរ។ វាបាននាំអ្នកអានឲ្យដកពិសោធន៍នូវការល្អរបស់ព្រះ តាមរយៈជីវិតផ្ទាល់ខ្លួ នរបស់ពួកគេ ហើយវានឹងនាំពួកគេមើលឃើញនូវរឿងរ៉ាវទាំងមូលនៃការតាំងសញ្ញារបស់ព្រះ ជាមួយនឹងមនុស្សជាតិ។សៀវភៅនេះ មានមេរៀនជាច្រើន សម្រាប់កុមារគ្រប់វ័យ។ មេរៀនសប្បាយៗ ងាយយល់ និងមានប្រសិទ្ធភាព។

– យ៉ូស្វេ ម៉ាហុនី អ្នកគ្រប់គ្រងធនធាន គ្រប់ទាំងអស់ជារបស់ព្រះគ្រីស្ទ

បដ្ឋិ លេខ

កាលបុណ្យថ្ងៃទី៥០ សាវកពេត្រុសបានធ្វើការប្រកាសថា រាស្ត្រនៅនគរព្រះជាម្ចាស់ និងអំណោយទាននៃព្រះវិញ្ញាណបរិសុទ្ធ ជាកម្មសិទ្ធិរបស់យើង និងដល់កូនចៅយើងផងដែរ (កិច្ចការ ២.ពាឯ)។ ការតាងំសញ្ញានៃការអធិស្ឋានសម្រាប់កុមារ បង្ហាញនូវសិទ្ធិដែលថា សេចក្តីពិតនៃការសន្យារបស់ព្រះមានជាប់ទាក់ទង ហើយនិងកើតមានពិតប្រាកដ សម្រាប់ពួកជំនុំនាពេលបច្ចុ ប្បន្ន ក៏ដូចជាពេលអតីតកាលដែរ។

– ស៊ីដនី ម៉ូស្យូ អនុប្រធានប្រចាំតំបន់អាហ្វ្រិក សេចក្តីមេត្តាអន្តរជាតិ

រាជាឯកសិទ្ធិពិសេសណាស់ ដើម្បីចូលរួមជាមួយនឹងកិច្ចសន្យាអធិស្ឋានសម្រាប់កុមារ និងអធិស្ឋានរួមគ្នា ដូច្នេះ គ្រប់មនុស្ស គ្រប់ទីកន្លែង អាចស្គាល់ព្រះគ្រីស្ទបាន! ការអធិស្ឋានសម្រាប់កុមារ នាំមកនូវការរួបរួមជាមួយយើងទាំងអស់គ្នា ព្រមទាំងនាំនូវការសព្វព្រះហប្ចទ័យរបស់ព្រះជាម្ចាស់ផងដែរ!

– ជើរី អូស្ទើឡៅ សេចក្តីអធិស្ឋានសកល គម្រោងភាពយន្តព្រះយេស៊ូវ

ខ្ញុំមានសេចក្តីសោមនស្ស ក្រៃលែង ដែលការតាំងសញ្ញានៃការអធិស្ឋាននេះ ត្រូវបានរៀបចំឡើងសម្រាប់កុមារ ជាប្រយោជន៍ឲ្យប្រើប្រាស់ក្នុងជីវិតអធិស្ឋានរបស់ពួកគេ។ ខ្ញុំមានសេចក្តីអស្ចារ្យផងដែរ បើការប្រើប្រាស់សៀវភៅនេះឲ្យបានត្រឹមត្រូវបំផុត នោះនឹងអាចឲ្យកុមារនៅជុំវិញពិភពលោកអាចរស់នៅក្នុងជីវិតដែលពេញដោយការអធិស្ឋាន។ ហេតុនេះ យើងសូមប្រកាសឲ្យខ្លាំងថា "អាប់ឡើងក្មេងៗ តោះយើងរៀនអធិស្ឋាន និងរៀនថ្វាយបង្គំព្រះអម្ចាស់"។

– បណ្ឌិត លូ ស៊ីរ៉ី នាយកអភិវឌ្ឍន៍បុព្វជិត/ព័ន្ធកិច្ចអធិស្ឋាន ពួកជំនុំបរិសុទ្ធបុណ្យថ្ងៃទី៥០អន្តរជាតិ

ព្រះយេស៊ូវសព្វព្រះទ័យឲ្យកុមារ មករកព្រះអង្គ។ ការតាំងសញ្ញានៃការអធិស្ឋានសម្រាប់កុមារ មិនត្រឹមតែផ្តល់ជាផ្លូ វឲ្យកុមារគ្រប់វ័យ ដែលអាចស្គាល់ទ្រង់ដោយជិតស្និទ្ធិប៉ុណ្ណោះទេ រាថែមទាំងផ្តល់ឲ្យសិទ្ធិអំណោចទៅពួកគេ ដោយក្លាយជាអ្នកដើរតាមព្រះគ្រីស្ទដែលពេញដោយអំណរពេលដែលពួកគេអធិស្ឋាន និងចែកចាយដល់កុមារឯទៀត។ ខេនឌី អរគុណចំពោះធនធានដ៏អស្ចារ្យនេះ!

– ដូន ស្តេនប៊ិន នាយកការិយាល័យនៃខ្សែភាពយន្តព្រះគ្រីស្ទ គម្រោងកាតាលីរ

ក្នុងភាពជាដៃគូជាមួយនឹងព័ន្ធកិច្ចជាច្រើនទៀត ការតាំងសញ្ញានៃការអធិស្ឋាន គឺការផ្លាស់ប្តូ រជីវិតដែលវាកំពុងកើតមានគ្រប់ទីកន្លែង។ ខ្ញុំមានចិត្តរំភើបចំពោះសៀវភៅអធិស្ឋានដែលមានផលផ្លែនេះណាស់ (ឥឡូ វកាន់តែល្អប្រសើរជាងមុនទៀត) រានឹងជម្រុញឲ្យកុមារទាំងសកល រាប់លាននាក់អាចចូលរួមអធិស្ឋានដោយថា "ព្រះអម្ចាស់អើយ សូមបំពេញខ្ញុំដោយព្រះវិញ្ញាណបរិសុទ្ធ!"

– ក្រេក ស្តតតុន អ្នកសម្របសម្រួលគម្រោង និងភាពជាដៃគូ ការិយាល័យប្រធានអង្គការនិស្សិត

របៀបផ្លាស់ប្តូ រជីវិតសម្រាប់កុមារ ត្រូវបានបង្រៀនឲ្យពួកគេយល់ពីតម្រូវការ នៃសេចក្តីអធិស្ឋាន របៀបអធិស្ឋាន និងអំណាចនៃការអធិស្ឋាន! បន្ថែមពីនេះ អំពីសារៈសំខាន់នៃការអធិស្ឋាន សៀវភៅនេះក៏បង្រៀនកុមារអំពីសេចក្តីស្រឡាញ់របស់ព្រះសម្រាប់ពួកគេ និងអំពីសារៈសំខាន់នៃការស្តាប់បង្គាប់ទ្រង់ផងដែរ។

– ថូម៉ាស់ ត្រាស់ម៏ អតីតអគ្គនាយកនៃក្រុមគ្រួសាររបស់ព្រះ

ព្រះកំពុងរើសកុមារ និងយុវជន ដែលជាអ្នកផ្លាស់ប្តូ រពិភពលោកជំនាក់ក្រោយ។ ការតាំងសញ្ញានៃការអធិស្ឋានសម្រាប់កុមារ ជាធនធានយ៉ាងអស្ចារ្យ ដែលឲ្យពួកគេរៀន អធិស្ឋានដោយយកព្រះគ្រីស្ទជាអតិភាពសម្រាប់ជីវិត និងជួយដល់អ្នកដទៃ ជារៀងរាល់ថ្ងៃ។ រាពិតជាល្អណាស់! ខ្ញុំជាអ្នកគាំទ្រម្នាក់! ខ្ញុំមានផែនការចែកចាយសៀវភៅនេះ ជាមួយនឹងមិត្តភ័ក្តរបស់ខ្ញុំទាំងអស់ និងមិត្តរួមការងាររបស់ខ្ញុំ ជាពិសេសជាមួយក្មេងៗ។ ខ្ញុំលើកទឹកចិត្តអ្នកឲ្យធ្វើដូចជាខ្ញុំដែរ។

– ថម រ៉ុចទ័រ ប្រធាន សម្ព័ន្ធបេសកកម្ម អ្នកសម្របសម្រួល តំបន់អាមេរិកខាងជើង៤ដល់១៤

ការតាំងសញ្ញានៃការអធិស្ឋានសម្រាប់កុមារ ជាលំនាំតាមព្រះគម្ពីរដ៏អស្ចារ្យមួយ ដើម្បីរីកចម្រើននូវក្តីស្រឡាញ់ និងភាពស្និទ្ធស្នាលរបស់យើងជាមួយនឹងព្រះជាម្ចាស់។ ខ្ញុំជឿថា រានឹងលើកទឹកចិត្តអ្នកជឿទាំងអស់ឲ្យអធិស្ឋាន ធ្វើផ្សាយដំណឹងល្អ និងបង្រៀនកូនៗរបស់យើង ឲ្យដើរតាមដោយស្តាប់បង្គាប់ទៅនឹងព្រះរាជបញ្ជាដ៏សំខាន់ និងបេសកកម្មដ៏អស្ចារ្យ។ ខ្ញុំសូមអរព្រះគុណព្រះ សម្រាប់អំណោយដ៏អស្ចារ្យមួយនេះ ដើម្បីរួបកាយព្រះគ្រីស្ទ!

– ម៉ាសល រីលៀម ស៊ើ គ្រូគង្វាលជាន់ខ្ពស់ ពួកជំនុំបាប់ទីស្ទណាសារ៉ែត ផីឡាដិលហ្វាប៉ា PA និងជាប្រធាន ការប្រកបអាមេរិក-អាហ្រិកជាតិ SBC

ការដឹងគុណ

ជូនចំពោះ កុមារទាំងអស់ជុំវិញពិភពលោក សូមឲ្យអ្នកអាចរីកចម្រើន ឲ្យយល់ពីសេចក្តីស្រឡាញ់ដ៏ជ្រាលជ្រៅរបស់ព្រះវរបិតាដែលគង់នៅស្ថានសួគ៌។

ជូនចំពោះ វីក ស្វាមីដ៏ជាទីគោរពរបស់ខ្ញុំ និងកូនៗរបស់យើង យ៉ូណាថាន់ និងម៉ារា សម្រាប់ក្តីស្រឡាញ់ ការគាំទ្រ និងការលើកទឹកចិត្ត។

ជូនចំពោះ ស្តេផាន អ៊ីរី ដៃគូរនិពន្ធរបស់ខ្ញុំ សម្រាប់ការអំណោយទានចំណេះដឹងទាញរបស់គាត់ ការណែនាំផ្លូវ និងការប្តេជ្ញាចិត្តចំពោះគម្រោងមួយនេះ ដោយស្មោះត្រង់។

ជូនចំពោះ ជើរីគើក សម្រាប់សន្តានចិត្ត និងការគាំទ្រយ៉ាងពេញទំហឹង ក្នុងការពង្រីកទស្សនវិស័យនៃការតាំងសញ្ញានៃការអធិស្ឋាន ទៅដល់កុមារនៅជុំវិញពិភពលោក។

ជូនចំពោះ ស្ត្រីទាំងអស់ ដែលនៅក្នុងក្រុម ចំពោះការជួយឲ្យមានភាពប្រសើរឡើង សម្រាប់ការអធិស្ឋានសម្រាប់កុមារ ដែលមាន: អាមី គើក, សារ៉ុន ម៉ាសុន, ស្តេផានី ផ្លោនក្លឹក, សារ៉ុន ស្កាត និង កាទី ស្មេលី ។

ជូនចំពោះ អ៊ីម៉ា ចន និង កាទី ស្មេលី នៃចលនា ៥/១៤ សម្រាប់ការដាក់បញ្ចូល និងការណែនាំរបស់ពួកគាត់។

បុព្វកថា

ខ្ញុំបានចូលរួមជាមួយនឹងផ្នែកកិច្ច តាមរយៈការតាំងសញ្ញានៃការអធិស្ឋានជាមួយយុវជន អស់រយៈពេលជាង ៤៥ឆ្នាំ ហើយ។ ខ្ញុំមានសេចក្តីរីករាយណាស់ ដែលឃើញការដែលព្រះកំពុងប្រទានពរ និងពង្រីកផ្នែកកិច្ចនេះ។ ការតាំងសញ្ញានៃការអធិស្ឋានសម្រាប់កុមារ គឺជាឧបករណ៍មួយដែលព្រះសព្វព្រះហឫទ័យ។ ខ្ញុំមិនដែលមានទស្សនវិស័យនេះពីមុនមកទេ រហូតដល់ លោកស្រី ខេនឌី ម៉ាប៊ែល បានចែកចាយទស្សនវិស័យរបស់គាត់ដល់ខ្ញុំ។ ព្រះជាម្ចាស់បានដឹកនាំគាត់ ឲ្យបង្កើតក្រុមជំនាញមួយ សម្រាប់ផ្នែកកិច្ចកុមារនេះឡើង។ ចាប់តាំងខេនឌី និងក្រុមគាត់ លះបង់គ្រប់បែបយ៉ាង លើផ្នែកកិច្ចសម្រាប់កុមារមក ពួកគាត់មានចិត្តរីករាយណាស់ ដើម្បីជ្រើសរើសយកការតាំងសញ្ញានៃការអធិស្ឋាន តាមភាសាសម្រាប់កុមារ។ ក្រោយពីបង្កើតទស្សនវិស័យសម្រាប់កុមារ តាមរយៈការតាំងសញ្ញានៃការអធិស្ឋាននេះ ខេនឌី និងអ្នកឯទៀត បានឃើញពីតម្រូវការចាំបាច់ តាមរយៈសៀវភៅមួយនេះ។

ក៏ដូចជាសៀវភៅសម្រាប់យុវជនដែរ ដែលការតាំងសញ្ញានៃការអធិស្ឋានសម្រាប់កុមារនេះ ជាឧបករណ៍មួយ ដែលបង្ហាញផ្លូវ និងបង្កើនភាពជាប់លាប់ក្នុងការអធិស្ឋាន។ ហើយដូចជាសេចក្តីបញ្ជាក់កន្លងទៅដែរ ដែលការតាំងសញ្ញានេះត្រូវបានសរសេរឡើងសម្រាប់កុមារ។ វាបង្ហាញឲ្យកុមារឃើញថា ពួកគេកំពុងនៅឯណា តែវាមិនបានទុកឲ្យកុមារចោលនៅទីនោះទេ។ ការតាំងសញ្ញានេះល្អ សង្ខេបខ្លី ន័យត្រង់ និងជម្រុញចិត្តក្នុងការអធិស្ឋាន ដែលឲ្យកុមាររីកចម្រើនខាងព្រលឹងវិញ្ញាណរបស់ពួកគេបាន។

សៀវភៅនេះ ត្រូវបានសរសេរផ្តោតលើកុមារ។ ប៉ុន្តែ ខ្ញុំជឿជាក់ថា វានឹងអាចនាំព្រះពរ និងការរីកចម្រើនដល់ឪពុកម្តាយ ដែលអាចឲ្យពួកគាត់នឹងក្លាយជាផ្លូវនៃព្រះពរ ដល់ក្មួយៗរបស់ពួកគាត់។ ហើយការតាំងសញ្ញានេះក៏នឹងផ្តល់ព្រះពរ និងចម្រើនដល់គ្រូបង្រៀនកុមារថ្ងៃអាទិត្យ ដែលពួកគាត់នឹងឲ្យពរទៅដល់សិស្សរបស់ពួកគាត់។ លើសពីនេះទៀត វាក៏នឹងផ្តល់ព្រះពរ ព្រមទាំងចម្រើនដល់គ្រួគង្វាល ដែលពួកគាត់ក៏នឹងឲ្យពរ និងចម្រើនលើដំណើរការ ការបង្រៀនដល់គ្រីស្ទបរិស័ទជាច្រើនទៀតផងដែរ។

វានឹងជួយកុមារឲ្យចេះអធិស្ឋានដោយខ្លួនឯង និងនាំឲ្យពួកគេចេះអធិស្ឋានបានជាមួយនឹងឪពុកម្តាយរបស់ពួកគេ ដែលពួកគេជឿជាក់ និងស្រឡាញ់។ អ្វីដែលជាការតាំងសញ្ញានៃការអធិស្ឋានផ្តល់ឲ្យឪពុកម្តាយ និងគ្រូបង្រៀនជាមួយនឹងផ្លូវ ដែលកុមារនឹងអាចអធិស្ឋានបាន។ វាគឺជាផ្លូវដែលសំលៀងការអធិស្ឋាន ដែលបង្ហាញកុមារ ឲ្យឃើញនូវក្តីស្រឡាញ់ និងសេចក្តីសុខសាន្ត ដែលព្រះប្រទានឲ្យ ហើយកុមារគ្រប់ភ្លូបក៏ត្រូវការផងដែរ។

ជាដំបូងឡើយ ការតាំងសញ្ញានៃការអធិស្ឋានសម្រាប់កុមារ គ្រាន់តែជាគំនិតល្អមួយតែប៉ុណ្ណោះ។ ឥឡូវនេះ ខ្ញុំជឿជាក់ថា ការបង្កើតជាសៀវភៅការតាំងសញ្ញាលនៃការអធិស្ឋានសម្រាប់កុមារគឺជាការសម្រេចចិត្តមួយដែលសំខាន់បំផុតដែលក្រុមអ្នកដឹកនាំយើងខ្ញុំបានបង្កើតឡើង។ វាអាចជាការផ្តុំគ្នាឡើង ដែលអាចឲ្យភ្លើងឆេះសន្ធោសន្ធៅឡើង នៅជុំវិញពិភពលោក តាមរយៈការតាំងសញ្ញានៃការអធិស្ឋាននេះ។

ជើរី គើក
ស្ថាបនិក និងជាប្រធាននៃការតាំងសញ្ញានៃការអធិស្ឋាន

សេចក្តីផ្តើម

បង្រៀនកុមាររបៀបអធិ ស្ឋាន

ព្រះគម្ពីរលូកាជំពូក ១១ ចាប់ផ្តើមជាមួយនឹងការទូលសូមដ៏សាមញ្ញមួយរបស់ពួកសិស្ស “សូមទ្រង់បង្រៀនយើងខ្ញុំ ឲ្យចេះអធិស្ឋាន”។ ចាប់តាំងពីការបោះពុម្ពផ្សាយលើកដំបូងនៅឆ្នាំ ២០១៤ នៅពេលដែល ថម វ៉ិកធ័រ បានអញ្ជើញយើងឲ្យរៀបចំសៀវភៅនេះឡើងនៅ ក្នុងសន្និសីទអនុវត្តន៍ឈ្នាំ ផុត៤/១៤ នៅក្រុងញ៉ូ យ៉ក (the 4/14 Best Practices Conference in NYC) ព្រះបានប្រើប្រាស់ ការតាំងសញ្ញានៃការអធិស្ឋានសម្រាប់កុមារ នេះ ដើម្បីផ្សាយដំណឹងល្អ និងបង្រៀនកុមារ ទន្ទឹមនឹងការបង្រៀនឲ្យពួកគេឲ្យចេះអធិស្ឋានផងដែរ។ ពេលដែលកុមារមានបទពិសោធពីការឆ្លើយ តប និងពីអំណាចនៃការអធិស្ឋាន ពួកគេរីករាយ ហើយជំនឿពួកគេរឹងមាំ ព្រមទាំងពួកគេនឹងចង់អធិស្ឋានច្រើនថែមទៀត។

ការអធិស្ឋាន គឺជាវិន័យខាងព្រលឹងវិញ្ញាណដ៏សំខាន់បំផុតមួយ ពីព្រោះការអធិស្ឋានរក្សាទំនាក់ទំនងរបស់យើងជាមួយនឹងព្រះយេស៊ូវ។ នៅពេលដែលយើងចំណាយពេលអធិស្ឋានកាន់តែច្រើន នោះយើងនឹងក្លាយកាន់តែដូចព្រះយេស៊ូវដែរ ដែលពេញដោយព្រះគុណ ក្តីស្រឡាញ់ ក្តីមេត្តាករុណា និងការអត់ទោស។ ការអធិស្ឋានរបស់យើង គឺថា សៀវភៅនេះនឹងជួយសម្រួលដល់ចលនាអធិស្ឋានព្រមគ្នា ទាំងកុមារនិងយុវជននៅគ្រប់ទីកន្លែង និងនាំឲ្យមានអ្នកដើរតាមព្រះគ្រីស្ទជំនាន់ក្រោយ ដែលយល់នូវតម្លៃនៃការបង្រៀនត្រឹមត្រូវ ព្រមទាំងជាឯកសិទ្ធិ ដែលយើងទទួលបាន ដូចជាកូនរបស់ទ្រង់ ដែលចំណាយពេលទៀងទាត់ក្នុងការនិយាយជាមួយនឹងទ្រង់ដែរ។

នៅពេលដែលកុមារចាប់ផ្តើមដំណើរក្នុងការអធិស្ឋាននេះ យើងចង់ឃើញពួកគេដកពិសោធជាមួយព្រះ តាមវិធីដែលមានអំណាច ការរៀនពីរបៀបស្តាប់បង្គាប់ទ្រង់ និងការឆ្លើយតបពីការនាំនៃព្រះវិញ្ញាណបរិសុទ្ធ។

ព្រះទ្រង់មានបន្ទូលទៅកាន់កូនរបស់ទ្រង់ ដោយវិធីផ្សេងៗជាច្រើនកតគណនា តាមរយៈព្រះវិញ្ញាណបរិសុទ្ធ។ ការរៀនស្តាប់ គឺជាអ្វីដែលយើងសង្ឃឹមថា ពួកគេនឹងស្វែងរកឃើញ ពេលដែលពួកគេចាប់ផ្តើមរបៀបនៃការអធិស្ឋាន។ ខូលីន មីឡា អ្នកបញ្ជោះការអធិស្ឋាន ហើយបានចែកចាយជាមួយនឹងខ្ញុំថា “សូមឲ្យព្រះនូវការសរសើរតម្កើង” ដែលដកស្រង់ពី ទំនុកដំកើង ៤៦.១០ បានចែងថា “សូមបង្អង់សិន ឲ្យបានដឹងថា អញជាព្រះ”។ វាគឺជាការអញ្ជើញមួយ ដើម្បីអនុញ្ញាតឲ្យកុមារស្ងៀមស្ងាត់រយៈពេល ៥នាទី ជាមួយនឹងព្រះដ៏ខ្ពស់បំផុត។ ពិតជាគំនិតដ៏អស្ចារ្យណាស់ សម្រាប់កុមារ និងយុវជន! គ្រាន់តែអញ្ជើញកុមារចំណាយពេលស្ងៀមស្ងាត់ ៥នាទីប៉ុណ្ណោះ នៅចំពោះព្រះ និងអនុញ្ញាតឲ្យពួកគេស្តាប់នូវអ្វីដែលទ្រង់ចង់មានបន្ទូល ឬប្រាប់ឲ្យពួកគេធ្វើ។ យើងនឹងពន្យល់បន្ថែម នៅជំពូកបន្ទាប់ទៀត។ ការស្តាប់សំលេងព្រះរបស់យើង គឺមានសារៈសំខាន់ដូចទៅនឹងការអធិស្ឋានរបស់យើងដែរ។ ទ្រង់មានបន្ទូលមកកាន់យើងតាមរយៈព្រះបន្ទូលរបស់ទ្រង់ ហើយនិងការប្រាប់យ៉ាងយកចិត្តទុកដាក់ពីព្រះវិញ្ញាណបរិសុទ្ធ។ នៅក្នុងព្រះគម្ពីរ ក្មេងតូច សាំយ៊ូអែល រៀនស្គាល់សំលេងរបស់ព្រះ ហើយព្រះក៏អាចប្រើគាត់ឲ្យដឹកនាំប្រជាជាតិមួយបានផងដែរ។

បេសកកម្មរបស់យើង គឺជាការស្រែកឃ្លានចង់បានរបស់យើង: ការដឹកនាំកុមារ និងយុវជនដើរតាមព្រះយេស៊ូវ តាមរយៈអំណាចនៃការតាំងសញ្ញានៃការអធិស្ឋាន។ ពេលដែលយើងកំពុងប៉ះកុមារជាមួយនឹងសៀវភៅនេះ ព្រះក៏កំពុងធ្វើការយ៉ាងអស្ចារ្យតាមរបៀបដែលមានសក្តានុពល តាមរយៈពួកគេផងដែរ។ យើងបានឈោងចាប់កុមារជាង ២,៥ លាននាក់ នៅក្នុង ៥ពាក្យទេសទូទាំងពិភពលោករួចមកហើយ។ កុមារ ២,៥ លាននាក់នេះដែរ កំពុងដើរតាមព្រះយេស៊ូវទាំងអស់គ្នា! កុមារ ២,៥ លាននាក់ ក៏កំពុងរៀនស្តាប់សំលេង និងស្តាប់បង្គាប់ព្រះជាម្ចាស់ផងដែរ! ហើយយើងជឿថា វាគ្រាន់តែជាការចាប់ផ្តើមប៉ុណ្ណោះ។

អ្នកអាចស្វែងរកមើលសៀវភៅល្អៗសម្រាប់កូនរបស់យើងតាមគេហទំព័រ: theprayercovenant.org/children ។អ្នកនឹងរកឃើញនូវសៀវភៅដែលមានរូបភាព និងទីបន្ទាល់ជាច្រើន ពីការតាំងសញ្ញានៃការអធិស្ឋានសម្រាប់កុមារពាសពេញពិភពលោក។ យើងចូលចិត្តរឿងទាំងនោះណាស់! សូមសរសេរចុះ និងចែកចាយរឿងក្នុងការតាំងសញ្ញានៃការអធិស្ឋាន ជាមួយនឹងយើង។ យើងខ្ញុំទន្ទឹងរង់ចាំទទួលដំណឹងពីអ្នក។

សេចក្តីផ្តើម

ការរៀនអធិ ស្ឋាន

កូនៗរបស់អ្នកប្រហែលនឹងសួរថា តើការតាំងសញ្ញាគឺជាអ្វី? វាគ្រាន់តែជាការសន្យារវាងមនុស្ស២នាក់ ឬច្រើននាក់ ដែលការសន្យាដើម្បីអធិស្ឋានសម្រាប់គ្នាទៅវិញទៅមក នៅវេលាណាមួយជាក់លាក់ដែលពួកគេជាជ្រើសរើសបាន។ កុមារមានទំនាក់ទំនងគ្នា ដែលជាទស្សន:នៃការអធិស្ឋានសម្រាប់មនុស្សម្នាក់ ពីរនាក់ ឬ ក៏បីនាក់ នោះគួរឲ្យរីករាយ ដែលងាយស្រួល ដើម្បីឲ្យពួកគេយល់បាន។ ពេលដែលអ្នកសិក្សាតាមរយៈមេរៀននីមួយៗ ត្រូវប្រាកដដោយសួរថា “តើនរណាដែលព្រះជាម្ចាស់កំពុងដាក់នៅក្នុងចិត្តអ្នក ដើម្បីបញ្ចូលក្នុងការតាំងសញ្ញានៃការអធិស្ឋានជាមួយ?” ហើយតើតាមមធ្យោបាយអ្វី ដែលព្រះកំពុងមានបន្ទូលមកកាន់អ្នក ដើម្បីឲ្យចែកចាយរឿងរបស់ទ្រង់ជាមួយនឹងអ្នកឯទៀតនោះបាន?

ជារឿយៗ កុមារចាប់ផ្តើមការតាំងសញ្ញាជាមួយនឹងឪពុកម្តាយ បងប្អូនប្រុសស្រី និងមិត្តភក្តិ។ ពួកគេអាចចូលក្នុងការតាំងសញ្ញានៃការអធិស្ឋានថ្មីនៅពេលណាក៏បាន។ គោលបំណងចំបង គឺដើម្បីឲ្យកុមាររីកចម្រើនដឹងពីនៃការអធិស្ឋាន។ ជាញឹកញាប់ដែរ នេះទៅទៀត កុមារទាំងនោះគឺជាអ្នកដែលចាប់ផ្តើមដឹកនាំការអធិស្ឋាននៅផ្ទះរបស់ពួកគេ។

យើងសង្ឃឹមថា អ្នកនឹងរីករាយជាមួយនឹងប្លង់ថ្មី ដែលដាក់បញ្ចូលសៀវភៅទាំងមូល ទៅជា១០ជំពូក ដែលរួមមានផ្នែកនៃការបង្កើតសិស្ស: ព្រះគុណ ក្តីស្រឡាញ់ ក្តីមេត្តាករុណា ការប្រែចិត្ត ការថ្វាយបង្គំ ការប្តេជ្ញាចិត្ត ការពឹងផ្អែក កិច្ចពិល ភាពជាសិស្ស និងសិទ្ធិអំណាច។ មេរៀនគួរឲ្យរំភើបនីមួយៗ រួមមានរឿង៉ារព្រះគម្ពីរ ខគម្ពីរចងចាំ ក្រដាសកិច្ចការ ការអធិស្ឋានស្រុះគ្នា ការគោះឡើង និងមានសកម្មភាពជនទៃទៀត។
សូមរកមើលរូបតំណាងទាំង១០នេះ ដែលរូបនីមួយៗសម្គាល់ឲ្យសកម្មភាពទៅនឹងមេរៀននីមួយៗ។

តើអ្នកអាចនិយាយបានទេ?

តើអ្នកអាចស្វែងរកបានទេ?

តើអ្នកអាចដឹងបានទេ?

ការអធិស្ឋានព្រមគ្នា

សូមពណ៌នា!

តើអ្នកអាចស្តាប់ឮទេ?

តើអ្នកអាចធ្វើវាបានទេ?

សូមសាកល្បង!

ក្រដាសកិច្ចការ

ការគោះឡើង!

កម្មវិធីសិក្សា គឺមានភាពបទបែនបាន។ សូមសម្រេចចិត្តនូវអ្វីដែលអាចដំណើរការបានសម្រាប់អ្នក មិនថាក្នុងថ្នាក់បង្រៀនថ្ងៃអាទិត្យ កម្មវិធីVBS ឬកម្មវិធីសិក្សាតាមក្រុមតូច។ យើងផ្តល់មតិឲ្យដាក់ចូលទៅក្នុងចំណាត់ថ្នាក់ផង។ ទីមួយ បង្រៀនកុមារតាមរយៈខ្លឹមសារគោលទាំង១០ ក្នុងរយៈពេល១០សប្តាហ៍ បន្ទាប់មកស្នើឲ្យពួកគេធ្វើការព្រមព្រៀងជាមួយនឹងមិត្ត ឬសមាជិកក្នុងគ្រួសាររបស់គេណាម្នាក់។ ពេលអ្នកបញ្ចប់កម្មវិធីសិក្សារួចរាល់ សូមរក្សាការអធិស្ឋានជាអធិភាពក្នុងថ្នាក់រៀន។ ធ្វើដូចជាពេលដែលអ្នកចំណាយពេលថ្វាយបង្គំដោយចម្រៀង និងបន្ថែមពេលវេលារាល់សប្តាហ៍ ដើម្បីចូលរួមការថ្វាយបង្គំអធិស្ឋាន។ សូមស្នើសុំកុមារឲ្យចែកចាយ:

- របៀបដែលព្រះកំពុងផ្លាស់ប្តូរពួកគេ
- របៀបដែលព្រះកំពុងផ្លាស់ប្តូរនរណាម្នាក់ ដែលពួកគេកំពុងអធិស្ឋានឲ្យ
- របៀបដែលព្រះកំពុងមានបន្ទូលទៅកាន់ពួកគេ
- សូមឆ្លើយតបនឹងការអធិស្ឋាន
- សំណូមពរអធិស្ឋាន

អរគុណ សម្រាប់ភាពជាដៃគូរក្នុងការដឹកនាំអ្នកដទៃទៅព្រះគ្រីស្ទ តាមរយៈអំណាចនៃការអធិស្ឋាន។

ព្រះគុណ

សកម្មភាព ទី១៖ តើអ្នកអាចនិយាយបានទេ?

សកម្មភាព ទី១

ការចងចាំនៃការអធិស្ឋាន

ឱ ព្រះវរបិតាដែលគង់នៅស្ថានសួគ៌ សូមអរព្រះគុណចំពោះការស្រឡាញ់ទូលបង្គំ និងធ្វើឱ្យទូលបង្គំក្លាយជាកូនម្នាក់របស់ទ្រង់។

សូមអានសេចក្តីអធិស្ឋានទាំងស្រុងទាំងអស់គ្នា - សូមផ្តោតទៅលើខ្លឹមសារ ដូចជា អំពីព្រះគុណ។

សូមច្រៀងនូវសេចក្តីអធិស្ឋានទាំងស្រុងទាំងអស់គ្នា។ (ចាក់បទចម្រៀង)

ការទន្ទេញខគម្ពីរ (១យ៉ូហាន ៣.១)

ល្បែងល្បងប្រាជ្ញា

ពាក្យនីមួយៗមានចំនែកផ្សេងៗគ្នា។ ចំនែកទាំងនោះត្រូវដាក់ពាក្យឱ្យត្រឹមត្រូវ ដើម្បីបំពេញខគម្ពីរ។

ល្បែងកំសាន្តក្តាខៀនស

អ្នកមានគ្រូបង្ហាត់ម្នាក់ ជាមួយនឹងខគម្ពីរទាំងស្រុងដែលបានសរសេរលើក្តាខៀនស។ កុមារចាប់ផ្តើមអានខនោះឡើងព្រមគ្នា ក្រោយមកគ្រូបង្ហាត់នោះនឹងចាប់ផ្តើមលុបពាក្យខ្លះៗ រហូតពាក្យទាំងអស់ត្រូវលុបចេញទាំងអស់ក្នុងខនោះ រួចឱ្យកុមារអាន ដោយចងចាំវានៅក្នុងចិត្ត។

ឈរជាជួរ!

ប្រាប់កុមារឱ្យឈរជាជួរ។ ក្មេងនីមួយៗអានពាក្យក្នុងខគម្ពីរបន្តបន្ទាប់គ្នា។ បើពួកគេអានខុសពាក្យណាមួយ ពួកគេត្រូវរង់ចុះ។

សូមផ្តល់រង្វាន់លើកទឹកចិត្ត សម្រាប់អ្នកណាដែលអាចទន្ទេញខគម្ពីរ។

កុមារត្រូវប្តូរគ្នាអាន ជាមួយនឹងខគម្ពីរផ្សេងៗគ្នា។

សកម្មភាពទី២៖ តើអ្នកអាចរកឃើញទេ?

សកម្មភាពទី២៖

ពេលសិក្សាព្រះគម្ពីរ-ដឹកឱ្យជ្រៅទៅក្នុងព្រះបន្ទូលព្រះ។ មានខគម្ពីរយោង ដែលទាក់ទងនឹងអត្ថបទរឿង។ បង្កើតឱ្យមានការប្រកួតប្រជែង ថាតើអ្នកណាដែលអាចរកឃើញខគម្ពីរមុនគេ (ពាខព្រះគម្ពីរ ដូចខាងក្រោម)៖

ខគម្ពីរនិយាយពី "ព្រះគុណ"

យ៉ូហាន ៣.១៦

១យ៉ូហាន ៤.១០

រ៉ូម ៨.៣៨-៣៩

(អ្នកអាចប្រើខគម្ពីរទាំងនេះឬប្រើខផ្សេងទៀត)

តើខគម្ពីរនេះកំពុងប្រាប់អ្វីដល់ខ្ញុំ?

តើខគម្ពីរនេះឆ្លើយតបយ៉ាងណា សម្រាប់ជីវិតខ្ញុំ?

តើខ្ញុំបានពីអ្វី អំពីព្រះគុណ?

សកម្មភាពទី៣៖ តើអ្នកអាចយល់បានទេ?

សកម្មភាពទី៣៖

ការពិភាក្សា ឬការចែកចាយ។ ផ្អែកតាមការយល់ឃើញដោយសេរី-កុមារអាចបង្ហាញចេញនូវការសង្ស័យពីជំនឿរបស់ខ្លួន ការចោទសួរ ការចែកចាយពីភាពភ័យខ្លាច ។ល។ ក្មេងនីមួយៗបញ្ចេញនូវការយល់ឃើញផ្សេងៗគ្នាទាក់ទងនឹងជំនឿ។ អ្នកដឹកនាំគួរតែបើកចំហរចិត្ត ដោយចែកចាយរឿងរ៉ាវផ្ទាល់ខ្លួនក្នុងជីវិតរបស់ពួកគាត់ទាក់ទងនឹងព្រះគុណ។ សូមបន្ទាបខ្លួនចុះចូលជាមួយនឹងកុមារ ធ្វើដូច្នេះ នោះកុមារនឹងធ្វើដូចជាអ្នកដឹកនាំដែរ។

ឧទាហរណ៍ខ្លះៗនៃសំនួរទាំងនោះមានដូចជា៖

១. តើអ្នកដឹងយ៉ាងដូចម្តេច ថាព្រះស្រឡាញ់យើង?

២. តើអ្នកបង្ហាញសេចក្តីស្រឡាញ់អ្នកយ៉ាងដូចម្តេច?

៣. តើអ្វីដែលធ្វើឲ្យអ្នកយល់សេចក្តីស្រឡាញ់បាន?

៤. តើអ្វីដែលធ្វើឲ្យយើងក្លាយជាកូនរបស់ព្រះ?

សកម្មភាពទី៤៖ ការអធិស្ឋានព្រមគ្នា

សកម្មភាពទី៤៖

នេះជាឱកាសមួយ ដែលអាចឱ្យកុមាររអធិស្ឋានព្រមគ្នា។ អ្នកខ្លះប្រហែលជាមិនដែលធ្លាប់អធិស្ឋានដូចនេះពីមុនមកទេ ហើយអ្នកខ្លះរៀនខ្លាស់ក្នុងការអធិស្ឋានផងដែរ។ ការអធិស្ឋានព្រមគ្នា នឹងជួយធ្វើឱ្យការទូលអង្វរដល់ព្រះមានភាពសប្បុរស និងមានអំណរ ដែលវាហាក់ដូចជាអ្នកកំពុងបន្លឺសំឡេងជាពាក្យតែមួយ ឬ ជាប្រយោគអធិស្ឋានខ្លីៗព្រមគ្នាឡើង។ ចាប់ផ្តើមដោយការបង្រៀនកុមារ ពីព្រះនាមផ្សេងៗរបស់ព្រះ និងកិច្ចការរបស់ទ្រង់។ ការនេះក៏ជាវិធីក្នុងការថ្វាយបង្គំ និងសរសើរតម្កើងផងដែរ។ កុមារចូលចិត្តការអធិស្ឋានបែបនេះ ហើយនិងទទួលបានចម្លើយរាប់រហ័ស។ អ្នកដឹងជាក់ថាព្រះវិញ្ញាណបរិសុទ្ធនឹងតម្កើងឡើងតាមរយៈការអធិស្ឋានរបស់ពួកគេ។ ថ្ងៃនីមួយៗ ការអធិស្ឋានរបស់ពួកគេនឹងកាន់តែងាយស្រួលឡើង ព្រមទាំងរាល់ថ្ងៃចុងសប្តាហ៍ ការអធិស្ឋាននេះនឹងជម្រុញពួកគេចាប់ផ្តើមចែកចាយ សំណូមពរអធិស្ឋានផ្ទាល់ខ្លួនបានទៀតផង។

ព្រះអម្ចាស់ជាព្រះសុចរិតរបស់យើង (ព្រះយេហូវ៉ា ស៊ីតកេនូ)
អេម៉ាញ៉ូអែឡ (អេម៉ាញ៉ូអែល)
ព្រះវរបិតា (អ័ប៊ា)
ព្រះដ៏នៅអស់កល្បជានិច្ច (អែលអូឡាម)
ព្រះដ៏ខ្ពស់បំផុត (អែលអេលយ៉ុន)
ចៀម (សូបផេត)
ព្រះជាម្ចាស់ជាអ្នកគង្វាលរបស់ខ្ញុំ (ព្រះយេហូវ៉ា រូហ៊ី)
ព្រះជាម្ចាស់ជាថ្មដារបស់ខ្ញុំ (ព្រះយេហូវ៉ា ស៊ូរី)
ព្រះយេហូវ៉ាជាសេចក្តីសុខសាន្តរបស់ខ្ញុំ (យេហូវ៉ា សាឡូម)
ព្រះ អទិករដ៏មានព្រះចេស្តា (អែលឡូហ៊ីម)
ព្រះអម្ចាស់ (ព្រះយេហូវ៉ា)
ព្រះដែលទតមើលខ្ញុំ (អែល រី)
ព្រះដ៏មានគ្រប់ព្រះចេស្តា (អែល សាដដាយ)
ព្រះអម្ចាស់នឹងផ្គត់ផ្គង់ឱ្យ (ព្រះយេហូវ៉ា យីរេ)
ព្រះអម្ចាស់ដែលព្យាបាល (ព្រះយេហូវ៉ា រូផេ)

សកម្មភាពអធិស្ឋានមួយទៀត គឺ “ការអធិស្ឋានតាមពណ៌”។ ចាក់ភ្លេងចម្រៀងថ្វាយបង្គំសម្រាប់កុមារ ហើយឱ្យពួកគេផ្តេកខ្លួនលើស្មៅ ដោយរីករាយជាមួយនឹងការបង្កើតរបស់ព្រះ ដូចជាផ្ទៃមេឃ ដើមឈើ ពពក។ នៅលើក្រដាសធំព័រស សូមឱ្យកុមារគូរស្នាមៗ ទៅតាមអារម្មណ៍គេ នូវអ្វីក៏ដោយដែលពួកដឹងបានថាព្រះកំពុងមានបន្ទូលទៅកាន់ពួកគេ។ កុមារចូលចិត្តការអធិស្ឋានតាមពណ៌ណាស់ ហើយអ្នកនឹងស្ងើចសរសើរ ពេលដែលអ្នកឃើញនូវអ្វីដែលកុមារចែកចាយ។ សកម្មភាពនេះចំណាយពេល ៣០នាទី។

សកម្មភាពទី៥៖ សូមនិយាយ!

សកម្មភាពទី៥៖

សូមឲ្យកុមារចែកចាយគំនិតរបស់ពួកគេដោយសេរី អំពីសេចក្តីស្រឡាញ់ព្រះ៖ ការភ័យខ្លាច និងការព្រួយបារម្ភ លើការបាត់បង់សេចក្តីស្រឡាញ់ ឬអំណរដែលពួកគេទទួលបានពីការរៀនទូរសេចក្តីស្រឡាញ់ទ្រង់ចំពោះពួកគេ។

ប្រធានបទខ្លះៗ សម្រាប់ការពិភាក្សាបន្ត រួមមាន៖

ព្រះគុណមានន័យថា ត្រូវបានស្រឡាញ់ ទោះបីជាយើងមិនបានធ្វើអ្វី ដើម្បីស័ក្តសមនឹងបានសេចក្តីស្រឡាញ់នោះក៏ដោយ។

តើអ្វីជា សេចក្តីស្រឡាញ់ដ៏អស់កល្បជានិច្ច? វាមានន័យថា សេចក្តីស្រឡាញ់ដែលនឹងមិនបញ្ចប់! វានឹងមិនបញ្ចប់ ដោយព្រោះអ្នកធ្វើអ្វីខុសនោះឡើយ។ វាមិនបញ្ចប់ ដោយព្រោះអ្នកមានអារម្មណ៍ភ័យខ្លាចនោះឡើយ។ វានឹងមិនបញ្ចប់ ដោយព្រោះតែឪពុកម្តាយអ្នកបាត់បង់ការងារនោះឡើយ។ វានឹងមិនបញ្ចប់ ដោយព្រោះ.... (សូមឲ្យពួកគេបំពេញចន្លោះទំនេរ)។

មិនថាមានរឿងអ្វីកើតឡើង សេចក្តីស្រឡាញ់របស់ព្រះយេស៊ូវនឹងមិនដែលបញ្ចប់ និងមិនដែលខកបំណងនោះឡើយ។

សកម្មភាពទី៦៖ អ្នកអាចស្តាប់លឺទេ?

សកម្មភាពទី៦៖

ពេលនិទានរឿង ជាការចូលចិត្តសម្រាប់កុមារ។ សូមចាប់ផ្តើមអានរឿងប្រាប់កុមារ ព្រមទាំងសួរសំណួរ។ (១៥នាទី)

ជ្រើសរើសអ្នកស្ម័គ្រចិត្តឲ្យសម្តែងជាតួអង្គ រឿងក្នុងព្រះគម្ពីរជាសាច់រឿង។ ស្លៀកពាក់សាមញ្ញ ដោយមានសំភារៈសម្រាប់អ្នកគង្វាល និងសត្វសមទៅនឹងពេលវេលា ដូចជាក្រមាវុំក្បាល និងខ្សែចង់។ (១៥នាទី)

ដើរតួដោយនិទានរឿងម្តងទៀត។ និយាយប្រាប់រឿងដោយសាមញ្ញ ដដែលៗ និងអនុញ្ញាតឲ្យកុមារនិយាយរឿងឡើងវិញ។ បង្កើត ៨ក្រុម រួចបោះបាល់ឲ្យដល់ក្មេងម្នាក់។ ពួកគេចាប់ផ្តើមជាមួយសាច់រឿងដំបូង បន្ទាប់មកបោះបាល់ទៅឲ្យក្មេងម្នាក់ទៀត ដែលក្មេងម្នាក់នោះនឹងនិយាយរឿងបន្ទាប់។ បោះបាល់រហូតដល់កុមារនិយាយរឿងបានទាំងស្រុង។ (១៥នាទី)

សកម្មភាពទី៧: តើអ្នកអាចធ្វើបានទេ?

ការដាក់ពាក្យ

ពេលពិភាក្សា: សូមពិភាក្សាតាមសំនួរដូចតទៅនេះ ឬក៏បង្កើតជាសំនួរផ្ទាល់ខ្លួនអ្នក:

តើអ្នកអាចឆ្លើយតប នូវអ្វីដែលអ្នករៀនបានថ្ងៃនេះសម្រាប់ជីវិតអ្នក បានយ៉ាងដូចម្តេច?

តើអ្នកបានឃើញពីព្រះគុណ តាមសកម្មភាពទេ?

តើការអ្វីមួយ ដែលអ្នកអាចធ្វើបាន ដើម្បីបង្ហាញដល់អ្នកឯទៀតអំពីព្រះគុណ?

សកម្មភាពទី៨: សូមដើរតួ! (DJ'S GAMES from GameLife)

ល្បែងកំសាន្តអំពី "អ្នកគង្វាល និងចៀម"

១. ចំណុចសំខាន់: ល្បែងកំសាន្តនេះដូចជាល្បែង "លួចសាច់" ដែលចែកជា ៤ក្រុក និងក្រៅពីនេះរួមមាន: "ចៀម" "ចចក" និង "អ្នកគង្វាល"។

២. ចូរប្រាប់អ្នកលេងនូវព្រំដែនកំណត់ ដោយល្បែងនេះស្ថិតនៅលើផ្ទៃការេធំមួយ។ ចំនុចកណ្តាលការេធំ មានការេតូចជាងដែលជាកន្លែង "ចៀមដែលបាត់" រស់នៅ។ មានចចកចំនួន ៦ក្បាល ដែលកំពុងចាំការពារចៀមដែលបាត់នោះ។ សូមចែកអ្នកលេងទៅជា ៤ក្រុម ដែលក្រុមនីមួយៗ ស្ថិតនៅកន្លែងផ្ទះសេងគ្នានៃក្រកទាំង៤ ដោយនៅខាងក្រៅផ្ទៃការេធំ។

៣. អ្នកលេងត្រូវចែកជា ៤ក្រុម (ត្រូវចែកជា ២ក្រុម បើមានអ្នកលេងតិចជាង ១០នាក់) ចូរឱ្យលេខរៀងតាមជួរអ្នកលេងនីមួយៗ ដោយអ្នកលេងទាំងនោះមានលេខរៀងទី១ ២ ៣ និងច្រើនទៀត។

៤. សូមពន្យល់ នៅពេលដែលអ្នកបង្ហាត់លេងស្រែក "លេខណាមួយ" អ្នកលេងទាំង ៤ក្រក ដែលត្រូវនឹងលេខរៀងរបស់ខ្លួន ត្រូវរត់ចូលក្នុងផ្ទៃការេ ដើម្បីព្យាយាមប៉ះ និងសង្គ្រោះចៀមដែលបាត់មួយនៅចំកណ្តាល។ ប្រសិនបើអ្នកលេងនោះត្រូវចចកចាប់បានវិញ អ្នកលេងនោះត្រូវចាញ់ ដោយចាំលេងវគ្គក្រោយទៀត។

៥. ចំណុចសំខាន់ៈ ត្រូវមាន "ចចក" ច្រើនជាង "អ្នកជួយសង្គ្រោះចៀម"។

៦. ចៀមទាំងឡាយនឹងមិនអាចជួយចៀមដែលបាត់នោះបានទេ ព្រោះមានចចកច្រើនណាស់ចាំការពារ។

៧. ចំណុចសំខាន់ៈ សូមលេងម្តងទៀត លើកនេះសូមពន្យល់ ដោយមានគ្រូបង្ហាត់លេងម្នាក់ ដែលនឹងធ្វើជា "អ្នកគង្វាលល្អ" ហើយនិងអាចហៅគ្រប់ពេលថា "ចចកចេញទៅ! ចៀមត្រឡប់ទៅផ្ទះវិញ!" ពេលលឺចចកត្រូវអង្គុយចុះ ហើយចៀមទាំងអស់អាចទៅផ្ទះ តាមជួររបស់ខ្លួនដើម្បីលេងម្តងទៀត។

- សេចក្តីពិតផ្សាភ្ជាប់ជីវិត: អ្នកគង្វាលល្អតែងតែប្រាកដថា ចៀមទាំងអស់មានសុវត្ថិភាព នៅផ្ទះរបស់ខ្លួន។

សកម្មភាពទី៩៖ ក្រដាសកិច្ចការ

សកម្មភាពទី ៩៖

សូមឲ្យក្រដាសកិច្ចការ ដល់ក្មេងម្នាក់ៗ។ ឲ្យចិច ខ្មៅដៃ ខ្មៅដៃពណ៌ និងដីសពណ៌ ដើម្បីធ្វើកិច្ចការ។ អ្នកមិនត្រូវឲ្យក្រដាសដែលគូសរួចហើយទេ តែជាក្រដាសថ្មីដែលត្រូវសរសេរ ឬគូសដោយខ្លួនឯង។ សំណួរំលើកទៅតាមអត្ថបទរឿងនីមួយៗ។

១. តើអ្នកចងចាំសេចក្តីអធិស្ឋាននៃជួរទី១ បានទេ? ចូរសរសេរចុះដូចខាងក្រោម:

២. បំពេញចន្លោះ

> ១យ៉ូហាន ៣.១ "មើល _____ ដែល _____
> បានផ្តល់មក _____ ឲ្យយើងបានហៅជា _____ ។

៣. តាមពាក្យសំដីផ្ទាល់ខ្លួន តើអ្នកអាចចែកចាយបានទេ ការដែលឲ្យអ្នកដឹងថា អ្នកជាកូនព្រះជានិច្ចនោះ?

៤. ព្រះយេស៊ូវស្គាល់អ្នកតាមឈ្មោះ និងស្គាល់គ្រប់ទាំងអស់របស់អ្នក! តើអ្នកអាចសរសេរប្រយោគមួយ ឬ គូសជារូបភាពមួយ ដែលពិពណ៌នា ពីរបៀបដែលធ្វើឲ្យអ្នកស្គាល់ថាជាកូនទ្រង់បាន?

៥. ពេលឆ្លើយតប

> ជាការល្អដែលត្រូវអរព្រះគុណព្រះ! ការនេះគាប់ព្រះទ័យដល់ព្រះយេស៊ូវណាស់។ តើអ្នកអាចសរសេរចុះនូវការអរព្រះគុណ ដែលអ្នកទទួលបានពីព្រះយេស៊ូវបានទេ? (សូមផ្តល់ឲ្យជាក្រដាសជាត់ពណ៌ ដីសពណ៌ ខ្វឹត ខ្មៅដៃ និងរូបភាពបិទភ្ជាប់ផ្សេងៗ ដើម្បីឲ្យកុមារបង្កើតជាកាតអរព្រះគុណដល់ព្រះយេស៊ូវ។ ឬ ជ្រើសរើសរូបភាពដែលគូសរួចហើយណាមួយក៏បាន។)

សកម្មភាពទី១០៖ ការគោះឡើង!

សកម្មភាពទី ១០៖

នេះជាការចំណូលចិត្តមួយផ្សេងទៀតសម្រាប់កុមារ។ អត្ថបទរឿងនីមួយៗបញ្ចប់ដោយការគោះ។ វាអនុញ្ញាតិឲ្យកុមារបង្ហាញនូវគំនិតច្នៃប្រឌិតរបស់ខ្លួន។ សូមឲ្យក្មេងៗនូវសំភារៈមួយចំនួនដូចជា៖ ស្គរគោះ ក្តាចុចសំភារៈដែលបង្កើតសំលេងណាមួយ ឬក៏ឲ្យពួកគេនូវសំភារៈផ្សេងៗក្នុងផ្ទះក៏បាន។ សូមរើសក្មេងម្នាក់ឲ្យគោះ និងកុមារឯទៀតក្នុងក្រុមឆ្លើយតបជាពាក្យបន្ទោរ ដែលពាក្យបន្ទោរនោះទាក់ទងនឹង ព្រះគុណ។

ព្រះគុណ

ឱ ព្រះវរបិតាដែលគង់នៅស្ថានសួគ៌អើយ
សូមអរគុណចំពោះការស្រឡាញ់ទូលបង្គំ ហើយធ្វើ
ឲ្យទូលបង្គំក្លាយជាកូនម្នាក់របស់ទ្រង់។



ប្រស្នាអំពីចៀមដែលបាត់ លូកា ១៥.១-៧

១យ៉ូហាន ៣.១

មើល សេចក្តីស្រឡាញ់យ៉ាងណាហ្ន ដែលព្រះវរបិតាបានផ្តល់មកយើងរាល់គ្នា ឲ្យយើងបានហៅថាជាកូនរបស់ព្រះដូច្នេះ។

ព្រះគុណ

តើ អ្នកអាចនិ យាយបានទេ?

ឱ ព្រះវរបិតាដែលគង់នៅស្ថានសួគ៌អើយ សូមអរគុណចំពោះការស្រឡាញ់ទូលបង្គំ ហើយធ្វើ ឲ្យទូលបង្គំក្លាយជាកូនម្ចាក់បស់ទ្រង់។

១យ៉ូហាន ៣.១

មើល សេចក្តីស្រឡាញ់យ៉ាងណាហ្ន ដែលព្រះវរបិតាបានផ្តល់មកយើងរាល់គ្នា ឲ្យយើងបានហៅថាជាកូនរបស់ព្រះដូច្នេះ។

តើ អ្នកអាចដឹ ងបានទេ?

តើអ្នកដឹងយ៉ាងដូចម្តេច ថាព្រះស្រឡាញ់យើង?

តើអ្នកបង្ហាញសេចក្តីស្រ ឡាញ់អ្នកយ៉ាងដូចម្តេច?

តើអ្វីដែលធ្វើឲ្យ យើងក្លាយជាកូនទ្រង់?

តើអ្វីដែលធ្វើឲ្យអ្នកដឹង ថាសេចក្តីស្រឡាញ់?

តើ អ្នកអាចស្វែងរកបានទេ?

យ៉ូហាន ៣.១៦

១យ៉ូហាន ៤.១០

រ៉ូម ៨.៣៨-៣៩

ព្រះគុណ



"ការអធិ ស្ឋានពេតលី ង"

បើថ្នាក់អ្នកធំពេក សូមបំបែកទៅជាក្រុមតូចៗ ហើយដឹកនាំពួកគេដោយ "ឱ ព្រះវរបិតាដែលគង់នៅស្ថានសួគ៌អើយ សូមអរគុណចំពោះការស្រលាញ់ទូលបង្គំហើយធ្វើឲ្យ ទូលបង្គំក្លាយជាកូនម្នាក់របស់ទ្រង់។" ឲ្យកុមារនិយាយសារឡើងវិញតាមជួរ បន្ទាប់មកសុំឲ្យពួកគេម្តងម្នាក់ៗ ឲ្យអធិស្ឋានម្នាក់មួយប្រយោគ ដោយទូលដល់ព្រះ នូវរបៀបដែលពួកគេស្រឡាញ់ក្នុងនាមជាកូនទ្រង់ អ្វីជាសេចក្តីស្រឡាញ់អស់កល្បជានិច្ចរបស់ព្រះដែលមានន័យសម្រាប់ពួកគេ ហើយនឹងការអរព្រះគុណសម្រាប់សេចក្តីស្រឡាញ់ទ្រង់ផងដែរ។ ពួកគេទូលទៅកាន់ព្រះនាមព្រះ ឬ ការទៅកាន់កិច្ចការដែលទ្រង់បានធ្វើ ដូចដែលបានចែកចាយនៅក្នុងមេរៀនគំរូ។ តែបើថ្នាក់របស់អ្នកតូច អ្នកអាចធ្វើការអធិស្ឋានដោយរៀបចំឲ្យកុមារកាន់ដៃជារង្វង់ ហើយឲ្យក្មេងម្នាក់ៗដឹកនាំការអធិស្ឋាន ពួកគេនឹងអាចធ្វើបាន។

សូមពណ៌ នា!

- ព្រះគុណមានន័យថាទទួលបានការស្រឡាញ់ ទោះបីជាយើងមិនធ្វើអ្វីទាំងអស់ដើម្បីទទួលបានវាក៏ដោយ។
- យើងដឹងថាព្រះស្រឡាញ់យើង ដោយព្រះទ្រង់បានបង្កើតយើង ផ្គត់ផ្គង់យើង និងបានបញ្ជូនព្រះរាជបុត្រាទ្រង់តែមួយ គឺអង្គព្រះយេស៊ូវ ដើម្បីមកសុគតនៅលើឈើឆ្កាងសម្រាប់យើងរាល់គ្នា។
- តើអ្នកដឹងទេថា អ្វីជាសេចក្តីស្រឡាញ់ដ៏នៅអស់កល្បជានិច្ច? វាមានន័យថាសេចក្តីស្រឡាញ់ដែលគ្មានទីបញ្ចប់ ទោះបីជាពេលវេលាឃ្លាតយ៉ាងណាក៏ដោយ។
- វាមិនដែលបញ្ចប់ឡើយ ទោះបីជាអ្នកធ្វើកំហុសក៏ដោយ។
- វាមិនដែលបញ្ចប់ឡើយ ទោះបីជាអ្នកមានអារម្មណ៍ភ័យខ្លាចក៏ដោយ។
- វាមិនដែលបញ្ចប់ឡើយ ទោះបីនរណាមនុស្សដែលយើងស្រឡាញ់ស្លាប់ក៏ដោយ។
- វាមិនដែលបញ្ចប់ឡើយ ទោះបីជាឪពុកម្តាយអ្នកបាត់បង់ការងារធ្វើក៏ដោយ។
- វាមិនដែលបញ្ចប់ឡើយ ទោះបីជាអ្នកទទួលបានចំណាត់ថ្នាក់នៅសាលាមិនល្អក៏ដោយ។
- មិនថាមានរឿងអ្វីកើតឡើងក៏ដោយ សេចក្តីស្រឡាញ់របស់ព្រះយេស៊ូវនឹងមិនបញ្ចប់ ហើយនិងមិនដែលបរាជ័យឡើយ។

សូមឲ្យកុមារចែកចាយគំនិតយោបល់ដោយសេរី ពីសេចក្តីស្រឡាញ់របស់ព្រះ៖ ការភ័យខ្លាច ការចង់បារម្ភ អំពីការបាត់បង់សេចក្តីស្រឡាញ់របស់ព្រះ ឬក៏ សេចក្តីសុខ និងការដកពិសោធន៍សេចក្តីអំណរ ព្រមទាំងការរៀនអំពីសេចក្តីស្រឡាញ់របស់ទ្រង់។

ព្រះគុណ

តើ អ្នកអាចស្តាប់លឺ ទេ?

ប្រស្នាអំពីចៀមដែលបានបាត់ (លូកា ១៥.១-៧)

ព្រះយេស៊ូវចង់ឲ្យមនុស្សម្នាដឹងថា តើព្រះស្រឡាញ់ពួកគេខ្លាំងប៉ុណ្ណា។ ទ្រង់ក៏បាននិទានរឿងអំពីអ្នកគង្វាលម្នាក់ ហើយនិងចៀមរបស់គាត់ដែលបានបាត់។ អ្នកគង្វាលព្រួយបារម្ភពីចៀមមួយដែលបានបាត់ ហេតុនោះហើយបានជាគាត់ទុកចៀមក្នុងហ្វូងផ្សេងៗទៀតចោល និងស្វែងរកចៀមដែលបានបាត់នោះ។ ពេលខ្លះចៀមរងរង្គើ និងដើរទៅតាមផ្លូវរបស់ពួកវារៀងខ្លួន។ ពួកវាជាសត្វដែលគ្មានសង្ឃឹម ដែលងាយស្រួលរងការវាយប្រហារឬចាប់ជាចំណីពីសត្វខ្លាឃ្មុំ ហ្វូងចចក ឬ ហ្វូងតោ។

ការងាររបស់អ្នកគង្វាល គឺការងារចៀមពីគ្រោះថ្នាក់ នោះគឺជាអ្វីដែលអ្នកគង្វាលបានធ្វើ។ គាត់មានចិត្តសប្បាយរីករាយណាស់នៅពេលដែលគាត់រកឃើញចៀមដែលបានបាត់ ហើយបីត្រកងដោយដៃរបស់គាត់តាមផ្លូវមកផ្ទះវិញ។ បន្ទាប់មកគាត់បានហៅមិត្តភក្តិ ព្រមទាំងអ្នកជិតខាងរបស់គាត់មករបរអរសាទរនឹងចៀមមួយដែលបានរកឃើញវិញ។ ព្រះយេស៊ូវបានមានបន្ទូលថា រឿងនេះដូចជាអ្វីដែលនៅស្ថានសួគ៌នៅពេលដែលក្មេងប្រុស ឬ ស្រី បុរស ឬ នារី ទទួលទ្រង់ជាព្រះអង្គសង្គ្រោះ ពួកគេចេញពីផ្លូវ ត្រូវបានរងើងត្រឡប់ជារកឃើញវិញ ដែលនោះនឹងនាំសេចក្តីអំណរយ៉ាងខ្លាំង និងការរបរអរសាទរនៅស្ថានសួគ៌។ កណ្ឌព្រះគម្ពីរ សេផានា ៣.១៧ ជួយយើងឲ្យដឹងថា សេចក្តីអំណរបស់ព្រះវរបិតាដែលគង់នៅស្ថានសួគ៌សាទរចំពោះកូនទ្រង់។ “ព្រះអង្គជាព្រះដ៏មានកិត្តិឫទ្ធិ ដែលនឹងសង្គ្រោះ ព្រះអង្គនឹងរីករាយចំពោះអ្នកដោយអរសប្បាយ ព្រះអង្គនឹងធ្វើសឲ្យអ្នកមានចិត្តស្ងប់ដោយសេចក្តីស្រឡាញ់របស់ព្រះអង្គ ព្រះអង្គនឹងរីករាយចំពោះអ្នក ដោយសំឡេងច្រៀងយ៉ាងឮ”។ តើការនេះ ធ្វើឲ្យអ្នកមានអារម្មណ៍យ៉ាងដូចម្តេច?

តើ អ្នកអាចធ្វើ វាបានទេ?

- សូមជឿថា ព្រះយេស៊ូវបានសុគតសម្រាប់អំពើបាបរបស់អ្នក ហើយទ្រង់រស់នៅក្នុងចិត្តរបស់អ្នក។
- សូមជឿថា ព្រះគុណទ្រង់ធ្វើឲ្យអ្នកបានក្លាយជាកូនជាទីស្រឡាញ់របស់ទ្រង់។
- សូមជឿថា សេចក្តីស្រឡាញ់ទ្រង់សម្រាប់អ្នក នឹងមិនដែលបញ្ចប់ ទោះមានរឿងអ្វីកើតឡើងក៏ដោយ។
- សូមជឿថា ព្រះអាចប្រើអ្នក ដើម្បីចែកចាយព្រះបន្ទូលនៃព្រះគុណទ្រង់ ជាមួយនឹងនរណាម្នាក់នៅថ្ងៃនេះ។

ព្រះគុណ

សូមសាកល្បង!

ល្បែងកំសាន្តអំពី "អ្នកគង្វាល និងចៀម"

១. ចំណុចសំខាន់: ល្បែងកំសាន្តនេះដូចជាល្បែង "លួចសាច់" ដែលចែកជា ៤ក្រុក និងក្រៅពីនេះរួមមាន: "ចៀម" "ចចក" និង "អ្នកគង្វាល"។

២. ចូរប្រាប់អ្នកលេងនូវព្រំដែនកំណត់ ដោយល្បែងនេះស្ថិតនៅលើផ្ទៃការេធំមួយ។ ចំនុចកណ្តាលការេធំ មានការេតូចជាងដែលជាកន្លែង "ចៀមដែលបាត់" រស់នៅ។ មានចចកចំនួន ៦ក្បាល ដែលកំពុងចាំការពារចៀមដែលបាត់នោះ។ សូមចែកអ្នកលេងទៅជា ៤ក្រុម ដែលក្រុមនីមួយៗ ស្ថិតនៅកន្លែងផ្សេងគ្នានៃក្រុកទាំង៤ ដោយនៅខាងក្រៅផ្ទៃការេធំ។

៣. អ្នកលេងត្រូវចែកជា ៤ក្រុម (ត្រូវចែកជា ២ក្រុម បើមានអ្នកលេងតិចជាង ១០នាក់) ចូរឲ្យលេខរៀងតាមជួរអ្នកលេងនីមួយៗ ដោយអ្នកលេងទាំងនោះមានលេខរៀងទី១ ២ ៣ និងច្រើនទៀត។

៤. សូមពន្យល់ នៅពេលដែលអ្នកបង្ហាត់លេងស្រែក "លេខណាមួយ" អ្នកលេងទាំង ៤ក្រុក ដែលត្រូវនឹងលេខរៀងរបស់ខ្លួន ត្រូវរត់ចូលក្នុងផ្ទៃការេ ដើម្បីព្យាយាមប៉ះ និងសង្គ្រោះចៀមដែលបាត់មួយនៅចំកណ្តាល។ ប្រសិនបើអ្នកលេងនោះត្រូវចចកចាប់បានវិញ អ្នកលេងនោះត្រូវចាញ់ ដោយចាំលេងវគ្គក្រោយទៀត។

៥. ចំណុចសំខាន់៖ ត្រូវមាន "ចចក" ច្រើនជាង "អ្នកជួយសង្គ្រោះចៀម"។

៦. ចៀមទាំងឡាយនឹងមិនអាចជួយចៀមដែលបាត់នោះបានទេ ព្រោះមានចចកច្រើនណាស់ចាំការពារ។

៧. ចំណុចសំខាន់៖ សូមលេងម្តងទៀត លើកនេះសូមពន្យល់ ដោយមានគ្រូបង្ហាត់លេងម្នាក់ ដែលនឹងធ្វើជា "អ្នកគង្វាលល្អ" ហើយនិងអាចហៅគ្រប់ពេលថា "ចចកចេញទៅ! ចៀមត្រឡប់ទៅផ្ទះវិញ!" ពេលលឺចចកត្រូវរអង្គុយចុះ ហើយចៀមទាំងអស់អាចទៅផ្ទះ តាមជួររបស់ខ្លួនដើម្បីលេងម្តងទៀត។

- សេចក្តី ពិ តផ្សាភ្ជាប់ជី វិ ត: អ្នកគង្វាលល្អតែងតែប្រាកដថា ចៀមទាំងអស់មានសុវត្ថិ ភាព នៅផ្ទះរបស់ខ្លួន។

សំណួរ

១. លេងលើកដំបូង តើនរណាម្នាក់អាចជួយសង្គ្រោះចៀមចេញពីហ្វូងចចកបាន ដែរឬទេ? បើមិនអាច ហេតុអ្វី?

២. នៅព្រះគម្ពីរ តើមានចៀមប៉ុន្មានដែលអ្នកគង្វាលល្អចេញទៅជួយសង្គ្រោះ? តែ១គត់! ក្មេងទាំងអស់គ្នា តើអ្នករាល់គ្នាដឹងដែរទេថា បើសិនជាអ្នកជាចៀមដែលបានបាត់ តើអ្នកគង្វាលល្អ ឬ ព្រះយេស៊ូវ នឹងត្រឡប់មករកអ្នកដែរឬទេ? តើការអ្វីដែលធ្វើឲ្យអ្នកដឹងថា ព្រះយេស៊ូវកំពុងស្វែងរកអ្នកគ្រប់ពេលវេលា?

៣. គោះយើងរធិស្ឋាន។ សូមថាតាមខ្ញុំ។ ព្រះអង្គម្ចាស់អើយ ទូលបង្គំអរព្រះគុណទ្រង់ ដែលយើងមានអំណរក្នុងការលេងល្បែងកំសាន្តនេះ សូមជួយទូលបង្គំឲ្យយល់ថា ព្រះគុណគឺការទទួលបានអ្វីមួយ ដែលទូលបង្គំបានសន្សំ ឬ ប្រឹងប្រែងរកវាដោយខ្លួនឯងឡើយ។ នោះជាអំណោយវិញ។ គោះយើឈប់បន្តិច ហើយស្តាប់សំឡេងដែលទ្រង់និយាយមកកាន់យើង។ តើទូលបង្គំធ្លាប់បានសុំព្រះពីអំណោយនៃព្រះគុណនោះទេ? (ឈប់បន្តិច) ព្រះអង្គម្ចាស់អើយ សូមអរព្រះគុណទ្រង់ ដែលទ្រង់ធ្វើឲ្យទូលបង្គំក្លាយជាកូនម្នាក់នៃកូនៗរបស់ទ្រង់។ ទូលបង្គំជាកូនរបស់ទ្រង់ហើយ!

* [អ្នកដឹកនាំ ការអធិស្ឋានទាំងនេះគឺ "ការអធិស្ឋានដែលថាតាមខ្ញុំ" ទាំងក្មេងប្រុសៗ និងស្រីៗថាតាមខ្ញុំទាំងអស់គ្នា...]
* * [អ្នកដឹកនាំ សូមឈប់បន្តិចរយៈពេល ១០វិនាទី ដោយអនុញ្ញាតឲ្យព្រះនិយាយទៅកាន់ចិត្តរបស់ក្មេងម្នាក់ៗ។ យើងកំពុងបង្រៀនកុមារ ឲ្យអាចនិយាយក្នុងសេចក្តីអធិស្ឋាន ព្រមទាំងស្តាប់សំឡេងក្នុងសេចក្តីអធិស្ឋានផងដែរ។]

©2018 The Prayer Covenant for Children/Games provided by GameLife77.com. All rights reserved.

ព្រះគុណ

ក្រដាសកិច្ចការ

១ តើ អ្នកអាចចាំជួរទី ១ នៃសេចក្តី អធិ ស្ឋាន និ ងសសេរចុះដូចខាងក្រោមនេះទេ?

២ បំពេញចន្លោះ

១យ៉ូហាន ៣.១ "មើ ល _____ ដែល _____ បានផ្តល់មក_____

ឲ្យយើ ងបានហៅជា..... ។

៣ តាមពាក្យសំដី ផ្ទាល់ខ្លួន តើ អ្នកអាចចែកចាយបានទេ ពី ការដែលធ្វើ ឲ្យដឹ ងបានថា អ្នកជាកូនព្រះជានិ ច្ចនោះ?

៤ ដូចជាឪពុកម្តាយអ្នកដែរ ព្រះយេស៊ូវស្គាល់ឈ្មោះអ្នក និ ងស្គាល់អ្វី ៗទាំងអស់របស់អ្នក!
តើ អ្នកអាចសរសេរប្រយោគមួយ ឬ គូសជារូបភាពមួយ ដែលពិ ពណ៌ នា ពី របៀបដែលធ្វើ ឲ្យអ្នកស្គាល់ថា អ្នកជាកូនទ្រង់?

៥ ពេលឆ្លើ យតប
ជាការល្អដែលត្រូវអរព្រះគុណព្រះ! ការនេះគាប់ព្រះទ័ យដល់ព្រះយេស៊ូវណាស់។ តើ អ្នកអាចសរសេរ ការអរព្រះគុណព្រះ ដែលអ្នកមើ លឃើ ញពី ព្រះយេស៊ូវបានទេ?

ព្រះគុណ

ការគោះឡើង!

ខ្ញុំគឺ ជាកូនជាទី ស្រឡាញ់របស់ស្តេចលើ អស់ទាំងស្តេច!

គឺ ជាខ្ញុំ គឺ ជាខ្ញុំ!

ខ្ញុំគឺ ជាកម្មសិ ទ្ធិ របស់ទ្រង់ នៃស្ថានដ៏ នៅអស់កល្បជានិ ច្ច!

គឺ ជាខ្ញុំ គឺ ជាខ្ញុំ!

ខ្ញុំត្រូ វបានសង្គ្រោះដោយព្រះគុណ និ ងការប្រោសលោះដោយលោហិ តរបស់ទ្រង់!

គឺ ជាខ្ញុំ គឺ ជាខ្ញុំ!

ខ្ញុំត្រូ វបានគ្របបាំងដោយព្រះហស្តរបស់ទ្រង់ឲ្យមានសុវត្ថិ ភាព ចៀសផុតពី គ្រោះថ្នាក់!

គឺ ជាខ្ញុំ គឺ ជាខ្ញុំ!

ខ្ញុំអរព្រះគុណ ដែលសេចក្តី ស្រឡាញ់ទ្រង់ សម្រាប់ខ្ញុំ នឹ ងមិ នដែលផុតឡើ យ ក៏ មិ នត្រូ វបញ្ចប់ដែរ!

គឺ ជាខ្ញុំ គឺ ជាខ្ញុំ!

ខ្ញុំគឺ ជាកូននៃព្រះដ៏ ខ្ពស់បំផុត!

អាម៉ែន!

គ្រូបង្រៀនអានអក្សរនៅផ្នែកពណ៌ខ្មៅ ហើយកុមារឆ្លើយតប ដោយអានតាមតែនៅផ្នែកពណ៌ខៀវវិញ។ ក្រោយមក សូមលើកទឹកចិត្តពួកគេឲ្យសរសេរលើក្តាគោះរបស់ពួកគេតាមក្រុម ដោយសរសេរសំណួរពរពួកគេនៅលើក្តាខៀន។ សូមមើលចំណាប់អារម្មណ៍ ដែលពួកគេគោះឮអ្វីដែលពួកគេបានសរសេរនោះចុះ!

សេចក្តីស្រឡាញ់

សូមជួយទូលបង្គំឲ្យស្រឡាញ់ និងស្តាប់បង្គាប់ទ្រង់។



រឿងរបស់លោកអ័ប្រាហាំ លោកុប្បត្តិ ១២.១-៥

ម៉ាថាយ ២២.៣៧, ៣៨

ត្រូវឲ្យស្រឡាញ់ព្រះអម្ចាស់ ជាព្រះនៃឯងឲ្យអស់អំពីចិត្ត
អស់អំពីព្រលឹង ហើយអស់អំពីគំនិតឯង
នេះជាបញ្ញត្តិយ៉ាងសំខាន់ទី១។

សេចក្តី ស្រឡាញ់

តើ អ្នកអាចនិ យាយបានទេ?

សូមជួយទូលបង្គំឲ្យស្រឡាញ់ និងស្តាប់បង្គាប់ទ្រង់។

ម៉ាថាយ ២២.៣៧, ៣៨

ត្រូវឲ្យស្រឡាញ់ព្រះអម្ចាស់ ជាព្រះនៃឯងឲ្យអស់អំពីចិត្ត អស់អំពីព្រលឹង ហើយអស់អំពីគំនិតឯង នេះជាបញ្ញត្តិយ៉ាងសំខាន់ទី១។

តើ អ្នកអាចស្វែងរកបានទេ?

ចោទិ យកថា ៧.៩

យ៉ូហាន ១៤.១៥

២យ៉ូហាន ១.៦

កូឡូស ៣.២០

តើ អ្នកអាចដឹ ងបានទេ?

- តើការស្តាប់បង្គាប់ជាអ្វី?
- តើសេចក្តីស្រឡាញ់សំខាន់ជាងការស្តាប់បង្គាប់ មែនឬ?
- ហេតុអ្វីបានជាសេចក្តីស្រឡាញ់ត្រូវបានផ្សាភ្ជាប់ទៅនឹងការស្តាប់បង្គាប់?

សេចក្តី ស្រឡាញ់



"ការអធិ ស្ឋានពោតលី ង"

សូមនាំកុមារចំណាយពេលអធិស្ឋានផ្ទាល់ៗខ្លួនម្តងទៀត ដោយការអធិស្ឋាន "សូមជួយឱ្យទូលបង្គំស្រឡាញ់ និងស្តាប់បង្គាប់ទ្រង់"។ សូមឱ្យកុមារថាតាមសេចក្តីអធិស្ឋាន។ សូមលើកទឹកចិត្តពួកគេឱ្យអធិស្ឋានតែសេចក្តីអធិស្ឋានត្រឹមតែមួយប្រយោគ ដោយទូលសូមព្រះទៅតាមពាក្យផ្ទាល់ខ្លួនរបស់ពួកគេ ដើម្បីសូមទ្រង់ជួយបង្រៀនពីសេចក្តីស្រឡាញ់ និងការស្តាប់បង្គាប់ទ្រង់។ ពួកគេអំពាវនាវតាមព្រះនាមផ្សេងៗរបស់ព្រះអង្គ ហើយនិងស្តាព្រះហស្តរបស់ទ្រង់ ដូចដែលបានចែកចាយក្នុងមេរៀនជាគំរូស្រាប់។

សូមពណ៌ នា!

- ព្រះយេស៊ូវចង់ឱ្យយើងស្តាប់បង្គាប់ឪពុកម្តាយរបស់យើង។
- ព្រះយេស៊ូវចង់ឱ្យយើងស្តាប់បង្គាប់ព្រះអង្គ។ ការនេះនាំឱ្យទ្រង់សព្វព្រះហឫទ័យ។
- យើងបង្ហាញសេចក្តីស្រឡាញ់ចំពោះទ្រង់ ដោយស្តាប់បង្គាប់ទ្រង់គ្រប់ការទាំងអស់។
- អ្នកនឹងឃើញតាមរយៈរឿង ដែលព្រះពរទទួលបានដោយការស្តាប់បង្គាប់។
- ការស្តាប់បង្គាប់ និងការដើរតាមព្រះយេស៊ូវ គឺជាការធ្វើដំណើរដ៏គួរឱ្យរីករាយមួយ។

នៅទីនេះអ្នកអាចចាប់ផ្តើមកិច្ចពិភាក្សាដែលនិយាយអំពីការស្តាប់បង្គាប់។ ពេលយើងស្តាប់បង្គាប់ឪពុកម្តាយរបស់យើង នោះសរបញ្ជាក់ឱ្យយើញថាយើស្តាប់បង្គាប់ព្រះអង្គដែរ ព្រោះទ្រង់មានបន្ទូ លថា យើងត្រូវតែស្តាប់បង្គាប់ឪពុកម្តាយរបស់យើងក្នុងគ្រប់ការទាំងអស់។ សូមឱ្យកុមារចែកចាយ ចំណុចពិបាកៗដែលពួកគេមានទាក់ទងនឹងការស្តាប់បង្គាប់ ប៉ុន្តែទន្ទឹមនឹងនេះ ចែកចាយពីព្រះពរដែលគេដកពិសោធន៍ពេលពួកគេស្តាប់បង្គាប់។ ចុងក្រោយ សូមជួយពួកគេឱ្យយល់ពីការផ្សាភ្ជាប់គ្នា រវាងសេចក្តីស្រឡាញ់ និងការស្តាប់បង្គាប់។

សេចក្តី ស្រឡាញ់

តើ អ្នកអាចស្តាប់លឺ ទេ?

រឿងរបស់លោកអ័ប្រាហាំ (លោកុប្បត្តិ ១២.១-៥)

លោកអ័ប្រាហាំបានរស់នៅតាំងពីយូរលង់ណាស់មកហើយ។ ពេលដែលគាត់ឈានចូលវ័យចំណាស់ ព្រះជាម្ចាស់បានមានបន្ទូលទៅកាន់គាត់ថា “សូមចេញពីស្រុក ពីញាតិសន្តាន និងពីផ្ទះឪពុកឯង ទៅនៅឯស្រុកដែលអញនឹងបង្ហាញឯងចុះ។ អញនឹងបង្កើតនគរ១យ៉ាងធំពីឯង អញនឹងឲ្យពរដល់ឯង ទាំងលើកឈ្មោះឯងធំផង ឯងនឹងបានធ្វើជាទីបញ្ចេញពរដល់មនុស្សទាំងឡាយ។ គ្រប់ទាំងគ្រួនៅផែនដីនឹងបានពរដោយសារឯង”។ លោកតាអ័ប្រាហាំស្តាប់បង្គាប់ព្រះអង្គ។ គាត់បានចាកចេញជាមួយនឹងប្រពន្ធរបស់គាត់។ សារ៉ា កូ យប្រុសរបស់គាត់ ឡុត ហើយនិងកម្មសិទ្ធិទាំងអស់របស់គាត់ផង។ ពួកគាត់បានចាកចេញពីស្រុកកំណើត ចេញពីក្រុងហេប្រុន ឆ្ពោះទៅកាន់ទ្លែងថ្មីមួយ ដែលពួកគាត់បានហៅថាទឹកដីសន្យា។

តើអ្នកដែលគិតទេថា ហេតុអ្វីបានជាគាត់បានធ្វើតាមអ្វីដែលព្រះជាម្ចាស់បានប្រាប់ដល់គាត់? ខ្ញុំជឿថាអ្នកប្រាកដជាដឹង! គឺគាត់បានរៀនស្រឡាញ់ និងរៀនស្តាប់បង្គាប់។ ការស្តាប់បង្គាប់របស់គាត់ គឺបានចាប់ផ្តើមពេញដំណើរជីវិតនៃការលូតលាស់របស់គាត់ ក្នុងការស្តាប់បង្គាប់ ការស្រឡាញ់ ហើយនិងសេចក្តីជំនឿ។

តើ អ្នកអាចធ្វើ វាបានទេ?

- សូមបង្ហាញសេចក្តីស្រឡាញ់ និងការថ្វាយបង្គំរបស់អ្នក ដោយការស្តាប់បង្គាប់នូវអ្វីដែលទ្រង់ប្រាប់។
- សូមស្តាប់បង្គាប់ឪពុកម្តាយរបស់អ្នក ដែលនេះគឺជាការគោរពកោតខ្លាចដល់ព្រះ។
- សូមប្តេជ្ញាចិត្តស្រឡាញ់ព្រះឲ្យអស់ពីចិត្ត ព្រលឹង គំនិត និងកំលាំងរបស់អ្នក។

សេចក្តី ស្រឡាញ់

សូមសាកល្បង!

ចូរកុំងាកក្រោយ

១. ចូរបែងចែកអ្នកលេង ១០នាក់ ក្នុង១ក្រុម១។ ក្រុមនីមួយ១ត្រូវកាន់ដៃគ្នា និងឈរជារង្វង់។ សូមទំលាក់ដៃចុះ និងមុខបែរទៅអ្នកខាងស្តាំដៃ ដោយត្រូវមើលខ្នងអ្នកនោះ (កន្ទុយ)។

២. អ្នកលេងទាំងអស់ត្រូវចងកន្ទុយភ្ជាប់នឹងខោ សំពត់ ឬ ខ្សែក្រវ៉ាត់ បើសិនជាអាច។
អ្នកលេងណាដែលមិនអាចចងកន្ទុយបាន: សូមប្រើក្រណាត់ចងភ្ជាប់គ្នាជុំវិញចង្កេះ ដូចជាខ្សែក្រវ៉ាត់ បន្ទាប់មកចងកន្ទុយភ្ជាប់នឹងវា។

៣. ចូរពន្យល់ អ្នកលេងទាំងអស់ត្រូវចាប់កន្ទុយអ្នកលេងនៅខាងមុខពួកគេ។ ពេលកន្ទុយត្រូវបានដោះចេញ អ្នកលេងម្នាក់នោះត្រូវចាញ់។

៤. ចំណុចសំខាន់: ចូរពន្យល់អ្នកលេងថា ដើម្បីឈ្នះ អ្នកលេងទាំងអស់មិនត្រូវងាកក្រោយឡើយ ប៉ុន្តែផ្តោតលើអ្វីដែលនៅខាងមុខពួកគេវិញ (គោលដៅ)។

៥. ចំណុចសំខាន់: បើរត់ជារង្វង់ ដោយព្យាយាមចាប់កន្ទុយអ្នកខាងមុខ ជាការពិបាកបន្តិច (បើមានអ្នកលេងតិច)។ ចូរនិយាយថា “ចាប់ផ្តើម” នោះអ្នកលេងទាំងអស់នឹងព្យាយាមការពារកន្ទុយរបស់ពួកគេ ពេលដែលអ្នកដទៃព្យាយាមទាញកន្ទុយរបស់ពួកគេចេញ។

៦. ពេលអ្នកបង្រៀនលេងស្រែកថា “ឈប់” អ្នកលេងណាដែលមិនរហូតកន្ទុយ គឺជាអ្នកឈ្នះ។

- សេចក្តី ពិ តផ្សារភ្ជាប់ជី វិ ត: លោកតាអ័ ប្រាហាំត្រូវបានព្រះត្រាស់ហៅឲ្យទៅរកកន្លែងថ្មី មួយ។ គាត់បានចាកចេញដោយទុកចោលរបស់របររបស់គាត់ ដូចជាស្រែកំណើ តគាត់ ឪពុកម្តាយរបស់គាត់ ការងាររបស់គាត់។ បើ មើ លទៅកាន់គាត់ គាត់បានស្តាប់បង្គាប់ព្រះ ហើ យព្រះអង្គបានប្រទានពរដល់គាត់ យ៉ាងធំសម្បើ ម។

សំណួរ

១. ខ្ញុំជឿថា ល្បែងកំសាន្តនោះគួរឲ្យរីករាយណាស់! វាជាការសំខាន់ណាស់ដែលត្រូវមើលទៅមុខជានិច្ច តើនឹងមានអ្វីកើតឡើង បើសិនជាអ្នកលេងម្នាក់ងាកបែរទៅកន្ទុយរបស់គាត់ខាងក្រោយ? (អ្នកលេងនោះនឹងបន្តយល្បឿន ហើយនិងបាត់កន្ទុយគាត់ផងដែរ)។

២. នៅក្នុងព្រះគម្ពីរ អ្វីខ្លះដែលលោកតាអ័ប្រាហាំបានបោះបង់ និងបានទុកចោល ដោយសំឡឹងឆ្ពោះទៅមុខ ហើយដើរតាមព្រះ? (ទឹកដីរបស់គាត់ មុខរបររបស់គាត់ មិត្តភ័ក្តិរបស់គាត់)

៣. ព្រះយេស៊ូវអើយ សូមអរព្រះគុណទ្រង់សម្រាប់ការហៅខ្ញុំនៅថ្ងៃនេះ។ សូមបង្ហាញខ្ញុំកឡូវនេះ នូវរបៀបដែលទ្រង់ចង់ឲ្យខ្ញុំស្តាប់បង្គាប់ និងរបៀបដែលឲ្យខ្ញុំស្រឡាញ់ ដោយអស់ពីចិត្ត អស់ពីព្រលឹង និងអស់ពីគំនិត។ (ឈប់បន្តិច) ព្រះអង្គអើយ ខ្ញុំស្រលាញ់ទ្រង់ សូមទ្រង់ជួយឲ្យខ្ញុំចេះស្តាប់បង្គាប់។

©2018 The Prayer Covenant for Children/Games provided by GameLife77.com. All rights reserved.

សេចក្តី ស្រឡាញ់

ក្រដាសកិ ច្ចការ

១ តើ អ្នកចង់ចាំនូវបន្ទាត់ទី ២ នៃការអធិ ស្ឋានពី សេចក្តី ស្រឡាញ់ទេ? សូមសរសេរវាចុះខាងក្រោម

២ បំពេញចន្លោះ

ម៉ាថាយ ២២.៣៧-៣៨ "_____ ព្រះអម្ចាស់ _____ _____

អស់អំពី _____ អស់អំពី _____ ហើ យអស់អំពី _____។

នេះជាបញ្ញត្តិ _____"។

៣ តើ អ្វី ជាការស្តាប់បង្គាប់?

៤ តើ អ្នកគិ តថាអ្វី ដែលជាការលំបាកបំផុត ក្នុងការស្តាប់បង្គាប់?

៥ ពេលឆ្លើ យតបៈ

នៅលើ ក្រដាសសរសេរដែលមានបន្ទាត់ សូមសរសេរខគម្តី រចងចាំថ្ងៃនេះ ដោយយកចិ ត្តទុកដាក់ បន្ទាប់មកបិ តវាភ្ជាប់ទៅ នឹ ងក្រដាសព័ ណ៌ ដែលអ្នកចូលចិ ត្ត ដោយក្រដាសព័ ណ៌ នោះគួរតែជាក្រដាសខគម្តី រ ធ្វើ ដូច្នេះ នោះក្រដាសព័ ណ៌ ដូចជា ស៊ុមសងខាងខគម្តី ររបស់អ្នក។ អ្នកអាចព្យួរវានៅលើ ជញ្ជាំងបន្ទប់គេងរបស់អ្នក ឬលើ តុរៀនរបស់អ្នក ដើ ម្បី រំលឹ កអ្នកពី ប ញ្ញត្តិ ធំបំផុតរបស់ព្រះជាម្ចាស់។

សេចក្តី ស្រឡាញ់

ការគោះឡើង!

តើ អ្នកធ្វើ អ្វី មុនគេ ជារៀងរាល់ថ្ងៃ?

ទុកចិ ត្ត ស្តាប់បង្គាប់ និ ងអធិ ស្ឋាន!

តើ អ្នកគួរធ្វើ អ្វី ពេលដែលអ្នកអានពី ព្រះបន្ទូលបរិ សុទ្ធរបស់ព្រះ?

ទុកចិ ត្ត ស្តាប់បង្គាប់ និ ងអធិ ស្ឋាន!

តើ អ្នកគួរធ្វើ អ្វី ពេលអ្នកត្រូវល្បួងឲ្យធ្វើ ខុស?

ទុកចិ ត្ត ស្តាប់បង្គាប់ និ ងអធិ ស្ឋាន!

តើ អ្នកគួរធ្វើ អ្វី ពេលអ្នកមានថ្ងៃមិ នល្អ ឬថ្ងៃស៊ូយ?

ទុកចិ ត្ត ស្តាប់បង្គាប់ និ ងអធិ ស្ឋាន!

តើ អ្នកគួរធ្វើ អ្វី ពេលអ្នកភ័ យខ្លាចនៅពេលរាត្រី ?

ទុកចិ ត្ត ស្តាប់បង្គាប់ និ ងអធិ ស្ឋាន!

តើ អ្នកគួរធ្វើ អ្វី ដើ ម្បី គាប់ព្រះហឫទ័ យព្រះ

ទុកចិ ត្ត ស្តាប់បង្គាប់ និ ងអធិ ស្ឋាន!

គ្រូបង្រៀនអានអក្សរនៅផ្នែកពណ៌ខ្មៅ ហើយកុមារឆ្លើយតប ដោយអានតាមតែនៅផ្នែកពណ៌ខៀវវិញ។ ក្រោយមក សូមលើកទឹកចិត្តពួកគេឲ្យសរសេរលើក្តាគោះរបស់ពួកគេតាមក្រុម ដោយសរសេរសំណួរពរពួកគេនៅលើក្តាខៀន។ សូមមើលចំណាប់អារម្មណ៍ ដែលពួកគេគោះនូវអ្វីដែលពួកគេបានសរសេរនោះចុះ!

សេចក្តី អាណិ តអាសូរ

សូមជួយទូលបង្គំឲ្យស្រឡាញ់អ្នកដទៃ
ដូចជាទ្រង់ស្រឡាញ់ទូលបង្គំ។



អ្នកស្រុកសាម៉ារីម្នាក់មានចិត្តសប្បុរស លូកា ១០.២៥-៣៧

យ៉ូហាន ១៥.១២

បញ្ញត្តិនេះគឺថា ត្រូវស្រឡាញ់អ្នកដទៃឲ្យដូចដែលខ្ញុំ
បានស្រឡាញ់អ្នករាល់គ្នាដែរ។

សេចក្តី អាណិ តអាសូរ

តើ អ្នកអាចនិ យាយបានទេ?

សូមជួយទូលបង្គំឲ្យស្រឡាញ់អ្នកដទៃ ដូចជាទ្រង់ស្រឡាញ់ទូលបង្គំទូលបង្គំ។

យ៉ូហាន ១៥.១២
បញ្ញត្តិនេះគឺថា ត្រូវស្រឡាញ់អ្នកដទៃឲ្យដូចដែលខ្ញុំបានស្រឡាញ់អ្នករាល់គ្នាដែរ។

តើ អ្នកអាចស្វែងរកបានទេ?

ម៉ាថាយ ៥.៤៤-៤៨
១កូរិនថូស ១៣.៤-៧
១យ៉ូហាន ៤.៧-៧
១យ៉ូហាន ៣.១៨

តើ អ្នកអាចដឹ ងបានទេ?

- តើនរណាដែលត្រូវបានបង្គាប់ឲ្យយើងស្រឡាញ់?
- តើយើងត្រូវស្រឡាញ់យ៉ាងដូចម្តេច?
- តើពេលណាដែលអ្នកយល់ពីសេចក្តីស្រឡាញ់របស់ព្រះអម្ចាស់?
- តើពេលណាដែលអ្នកយល់ពីសេចក្តីស្រឡាញ់របស់ត្រួសាររបស់អ្នក?

សេចក្តី អាណិ តអាសូរ



"ការអធិ ស្ឋានពោតលី ង"

សូមនាំកុមារចំណាយពេលអធិស្ឋានផ្ទាល់ៗខ្លួនម្តងទៀត ដោយការអធិស្ឋាន "សូមជួយឱ្យទូលបង្គំស្រឡាញ់ និងស្តាប់បង្គាប់ទ្រង់"។ សូមឱ្យកុមារថាតាមសេចក្តីអធិស្ឋាន។ សូមលើកទឹកចិត្តពួកគេឱ្យអធិស្ឋានតែសេចក្តីអធិស្ឋានត្រឹមតែមួយប្រយោគ ដោយទូលសូមព្រះទៅតាមពាក្យផ្ទាល់ខ្លួនរបស់ពួកគេ ដើម្បីសុំទ្រង់ជួយបង្រៀនពីសេចក្តីស្រឡាញ់ និងការស្តាប់បង្គាប់ទ្រង់។ ពួកគេអំពាវនាវតាមព្រះនាមផ្សេងៗរបស់ព្រះអង្គ ហើយនិងស្តាមព្រះហស្តរបស់ទ្រង់ ដូចដែលបានចែកចាយក្នុងមេរៀនជាគំរូស្រាប់។

សូមពណ៌ នា!

- ព្រះគុណមានន័យថាទទួលបានការស្រឡាញ់ ទោះបីជាយើងមិនធ្វើអ្វីទាំងអស់ដើម្បីទទួលបានវាក៏ដោយ។
- ស្រឡាញ់អ្នកដទៃ មានន័យថាស្រឡាញ់ដល់មិត្តភ័ក្ត និងស្រឡាញ់ខ្មាំងសត្រូវរបស់អ្នក។ អូ! នេះជាការពិបាកណាស់។
- ស្រឡាញ់អ្នកដទៃមានន័យថា ស្រឡាញ់ដូចដែលព្រះយេស៊ូវបានស្រឡាញ់ដោយការលះបង់។ នោះមានន័យថា ឱ្យអតិភាពដល់អ្នកដទៃជាងខ្លួនឯង។

សូមលើកទឹកចិត្តក្មេងឱ្យចែកចាយ និងពិភាក្សាដោយសេរីពីការព្រួយបារម្ភ និងបញ្ហាលំបាកនានារបស់ពួកគេអំពីសេចក្តីស្រឡាញ់អ្នកដទៃ តាមអ្វីដែលព្រះយេស៊ូវតម្រូវឱ្យធ្វើ។ សូមផ្តោតលើអត្ថបទព្រះគម្ពីរ ម៉ាថាយ ជំពូក៥។ កុមារប្រហែលជាចង់ចែកចាយចំណុចលំបាកៗ ក្នុងទំនាក់ទំនង និងចែកចាយអំពី ហេតុអ្វីបានជាការនោះវាលំបាកដើម្បីស្រឡាញ់អស់អ្នកណាដែលមិនចូលចិត្តពួកគេ។ សូមនិយាយអំពីលក្ខណៈនៃសេចក្តីស្រឡាញ់ ដែលបានបង្ហាញតាមរយៈអត្ថបទព្រះគម្ពីរ ១កូរិនថូស ជំពូក១៣។ តើចំណុចណាមួយដែលលំបាកក្នុងការអនុវត្តជាង តើចំណុចមួយណាដែលងាយស្រួលជាង?

សេចក្តី អាណិត អាសូរ

តើ អ្នកអាចស្តាប់លឺ ទេ?

អ្នកស្រុកសាម៉ារីម្នាក់មានចិត្តសប្បុរស (លូកា ១០.២៥-៣៧)

តើមានន័យយ៉ាងណា ដែលស្រឡាញ់អ្នកដទៃតាមដែលព្រះយេស៊ូវបានស្រឡាញ់យើងរាល់គ្នា? តោះរកចម្លើយទាំងអស់គ្នា។ មានម្នាក់បានសួរព្រះយេស៊ូវថា “តើនរណាជាអ្នកជិតខាងខ្ញុំ?” ព្រះយេស៊ូវបានពន្យល់គាត់តាមរយៈរឿងមួយ។ ទ្រង់និយាយរឿងយ៉ាងល្អណែត។ ព្រះយេស៊ូវគឺជាអ្នកនិទានរឿងយ៉ាងប៉ិនប្រសប់ម្នាក់។ ទ្រង់បានមានបន្ទូលថា “មានមនុស្សម្នាក់កំពុងតែធ្វើដំណើរពីក្រុងយេរូសាឡិម ចុះទៅក្រុងយេរីខូរ ក៏ធ្លាក់ខ្លួនទៅក្នុងកណ្តាប់ដៃពួកចោរ វាប្លន់គាត់ ព្រមទាំងវាយឲ្យត្រូវរបួសរួចចេញបាត់ទៅ ចោលគាត់ឲ្យនៅទ្រមម។ ជួនជាមានសង្ឃម្នាក់ចុះមកតាមផ្លូវនោះ កាលបានឃើញគាត់ ចុះមកតាមផ្លូវនោះ កាលបានឃើញគាត់ នោះក៏វាងតាមម្ខាងហួសទៅ”។

រវាងអ្នក និងខ្ញុំ គាត់មិនមានចិត្តអាណិតអាសូរពិតប្រាកដទេ។ ព្រះយេស៊ូវបានបន្តថា “ហើយមានពួកលេវីម្នាក់មកដល់កន្លែងនោះដែរ កាលបានឃើញហើយក៏វាងតាមម្ខាងហួសទៅទៀត”។ តើតើរាពិតទេ? តើអ្នកដឹងថានឹងមានអ្វីកើតឡើងបន្ទាប់ទេ? “តែមានសាសន៍សាម៉ារីម្នាក់ (អ្នកដែលពួកយូដាមើលងាយ មិនឲ្យតម្លៃ) បានឃើញបុរសដែលត្រូវរបួស តើអ្នកដឹងទេថា តើគាត់បានធ្វើអ្វី? គាត់បានបង្ហាញសេចក្តីស្រឡាញ់របស់ព្រះអម្ចាស់ ដោយជួយមើលថែទាំគាត់។ គាត់បានចូលទៅរុំបួសឲ្យ រួចលើកដាក់លើសត្វលារបស់គាត់ ដឹកទៅឯផ្ទះសំណាក់ ហើយបានប្រាប់ម្ចាស់ផ្ទះថា សូមថែរក្សាអ្នកនេះផង រហូតដល់គាត់បានប្រសើរឡើង។ រួចសាសន៍សាម៉ារីបាននិយាយថា “នេះប្រាក់ម្ភៃដុល្លារសម្រាប់ការព្យាបាល ហើយឯអ្នកចំណាយលើសពីនេះ ពេលខ្ញុំមកវិញ ខ្ញុំនឹងសងអ្នក”។ តើអ្នកដឹងថាព្រះយេស៊ូវបញ្ចប់រឿងនោះយ៉ាងដូចម្តេច? ទ្រង់មានបន្ទូលថា “ទៅចុះ សូមអ្នកប្រព្រឹត្តបែបយ៉ាងដូច្នោះដែរ”។

តើ អ្នកអាចធ្វើ វាបានទេ?

- សូមស្រឡាញ់ដូចដែលព្រះយេស៊ូវស្រឡាញ់ដោយបង់ថ្លៃជីវិត
- សូមស្រឡាញ់ ជាមួយនឹងសកម្មភាព ដោយមិនគ្រាន់តែពាក្យសម្តីប៉ុណ្ណោះទេ។ ពេលអ្នកយកចិត្តទុកដាក់អ្នកដទៃ អ្នកកំពុងបង្ហាញពីសេចក្តីអាណិតអាសូរ។
- សូមស្រឡាញ់ព្រះយេស៊ូវ ឲ្យរស់រំពីចិត្ត ហើយទូលសូមព្រះវិញ្ញាណបរិសុទ្ធ ឲ្យអ្នកអាចស្រឡាញ់អ្នកដទៃបាន។

សេចក្តី អាណិ តអាសូរ

សូមសាកល្បង!

មិនត្រូវបញ្ឈប់កែវទឹក

១. ចែកអ្នកលេងទៅជា ២ក្រុម (បើមានក្មេងច្រើន អាចចែកក្រុមបន្ថែមក៏បាន)

២. តំរៀបអ្នកលេងទៅជាជួរៗ ដោយស្មាត្រូវត្រង់នឹងនឹងស្មានីមួយៗ ហើយឈរឱ្យឃ្លាតគ្នា ១អស់ដៃ។

៣. នៅខាងមុខជួរ មានធុងទឹកធំៗ ហើយនៅខាងក្រោយជួរនីមួយៗ ក៏មានធុងទឹកធំៗដែរ។

៤. សូមឱ្យកែវទឹកជំរដល់អ្នកលេងម្នាក់ៗ។

៥. ពេលលឺសំលេងថា “ចាប់ផ្តើម” អ្នកលេងនៅខាងមុខគេ នៃជួរនីមួយៗត្រូវដងទឹកក្នុងធុង រួចយកទឹកដែលដងបានចាក់បំពេញកែវរបស់អ្នកលេងបន្ទាប់ក្នុងជួរ ហើយអ្នកលេងបន្ទាប់ត្រូវបន្តចាក់ទឹកឱ្យគ្នាជាបន្តបន្ទាប់ ដោយមិនត្រូវទុកទឹកនៅក្នុងកែវខ្លួនឡើយ។ អ្នកលេងក្រោយគេបង្អស់ត្រូវចាក់ទឹកចូលទៅក្នុងធុងទឹកនៅខាងក្រោយ ហើយត្រូវស្រែកឡើងថា “សូមជួយ ខ្ញុំត្រូវការទឹកបន្ថែម!”

៦. ពេលអ្នកលេងនៅខាងមុខបានលឺ ពួកគេចាប់ផ្តើមយកកែវរបស់ពួកគេដងទឹកចេញពីក្នុងធុងខាងមុខបន្ថែមទៀត រួចចាក់បន្តគ្នា ដដែលៗ រហូតទាល់តែដល់ពេលកំណត់។

៧. ចំណុចសំខាន់សម្រាប់អ្នកបង្ហាត់លេង៖ ជុំទី១ សូមកុំដាក់ទឹកនៅក្នុងធុងខាងមុខច្រើន តែជុំបន្តបន្ទាប់ ត្រូវដាក់ទឹកនៅក្នុងធុងខាងមុខបន្ថែមរហូត ដើម្បីឱ្យកុមារអាចដកទឹកនោះនៅជុំបន្តបន្ទាប់ទៀតបាន។

៨. ចំនុចអរស់សំណើច: សូមធ្វើជាគំនូសចំពាក់កណ្តាលលើធុងខាងក្រោយ ហើយប្រាប់កុមារពួកគេមានពេលត្រឹមតែ ៥នាទីប៉ុណ្ណោះ ដើម្បីចាក់ឱ្យពេញគំនូសកណ្តាលនៃធុងនោះ។

- **សេចក្តី ពិ តផ្សាភ្ជាប់ជី វិ ត៖ យើ ងត្រូ វឱ្យអ្នកដទៃទៀត នូវអ្វី ដែលយើ ងបានទទួលមកពី ព្រះជាម្ចាស់។**

សំណួរ

១. កុមាររាល់គ្នា តើហេតុអ្វីបានជាអ្នកបន្តចាក់ទឹកកតឈប់ទៅក្នុងកែវទឹករបស់អ្នក ដែលនៅបន្ទាប់អ្នកដូច្នេះ? តើហេតុអ្វីអ្នកមិនទុកទឹកនោះសម្រាប់ខ្លួនអ្នក? (ពេលខ្ញុំចាក់ទឹកឱ្យគេកាន់តែច្រើន ខ្ញុំក៏ទទួលបានវាកាន់តែច្រើនទៀតដែរ)

២. ក្នុងព្រះគម្ពីរ យើងឃើញថាមានបុរសម្នាក់ដែលរងគ្រោះ ហើយត្រូវការជំនួយ តើហេតុអ្វីបានជាអ្នកគិតថាសាសន៍សាម៉ារីម្នាក់នោះ មានចិត្តសប្បុរស សម្រាប់អ្នកដែលរងគ្រោះ ហើយគាត់បានជួយបុរសនោះ? (បុរសនោះត្រូវការជំនួយ ហើយសាសន៍សាម៉ារីអាចផ្តល់ឱ្យអ្វីដែលបុរសនោះត្រូវការ)

៣. ព្រះជាម្ចាស់ជួយទូលបង្គំ ឱ្យភ្នែករបស់ទូលបង្គំបើកឡើង ដើម្បីមើលឃើញអ្នកដែលត្រូវការជំនួយនៅជុំវិញខ្លួនទូលបង្គំ ពួកគាត់ដែលត្រូវការសេចក្តីអាណិតអាសូរ។ ឥឡូវនេះ សូមព្រះយេស៊ូវសព្វព្រះទ័យបង្ហាញទូលបង្គំឱ្យឃើញថានរណាដែលត្រូវការជំនួយ តាមរយៈជីវិតរបស់ទូលបង្គំ។ (ផ្អាកបន្តិតសិន) សូមព្រះយេស៊ូវជួយទូលបង្គំឱ្យស្រឡាញ់អ្នកដទៃ និងឱ្យទូលបង្គំក្លាយអ្នកជំនួយម្នាក់។

©2018 The Prayer Covenant for Children/Games provided by GameLife77.com. All rights reserved.

សេចក្តី អាណិ តអាសូរ

ក្រដាសកិ ច្ចការ

១ តើ អ្នកចាំបានទេ នៅបន្ទាប់ទី ៣ នៃសេចក្តី អធិ ស្ឋាន ពី សេចក្តី ណាណិ តអាសូរ? សូមសរសេរវាចុះខាងក្រោម

២ បំពេញចន្លោះ

យ៉ូហាន ១៥.១២ "នេះជា _____ គឺ ឲ្យអ្នករាល់គ្នា _____

ទៅវិ ញទៅមក ដូចជាខ្ញុំ..... អ្នករាល់គ្នាដែរ។

៣ តើ ហេតុអ្វី បានជាការសុគតរបស់ព្រះយេស៊ូវនៅលើ ឈើ ឆ្កាង ជាឧទាហរណ៍ នៃសេចក្តី ស្រឡាញ់ឥតខ្ចោះ សម្រាប់អ្នក?

៤ សូមបង្ហាញវិ ធី មួយ ដែលអ្នកអាចបង្ហាញនូវសេចក្តី ស្រឡាញ់ដែលលះបង់ សម្រាប់អ្នកណាម្នាក់ ដែលអ្នកស្គាល់។

៥ ពេលឆ្លើ យតប

ប្រើ ក្រដាសតាមការបង្គាត់បង្ហាញ ដី សពណ៌ និ ងខ្វឺ ត សូមបង្កើ តជាកាត សម្រាប់នរណាម្នាក់ ដែលអ្នកចង់បង្ហាញសេច ក្តី ស្រឡាញ់ទៅកាន់។ អ្នកអាចសរសេរខព្រះគម្ពី រចងចាំសម្រាប់ថ្ងៃនេះបានដែរ នៅផ្នែកខ្លះនៃកាតរបស់អ្នក!

សេចក្តី អាណិ តអាសូរ

ការគោះឡើ ង!

ខ្ញុំស្រឡាញ់ព្រះអង្គ អស់អំពី ចិ ត្តរបស់ខ្ញុំ!
ខ្ញុំស្រឡាញ់ ស្រឡាញ់ទ្រង់ណាស់!

ខ្ញុំស្រឡាញ់ព្រះអង្គ អស់អំពី ព្រលឹ ងរបស់ខ្ញុំ!
ខ្ញុំស្រឡាញ់ ស្រឡាញ់ទ្រង់ណាស់!

ខ្ញុំស្រឡាញ់ព្រះអង្គ អស់អំពី គំនិ តរបស់ខ្ញុំ។
ខ្ញុំស្រឡាញ់ ស្រឡាញ់ទ្រង់ណាស់!

ខ្ញុំស្រឡាញ់ទ្រង់ អស់អំពី កំលាំងរបស់ខ្ញុំ!
ខ្ញុំស្រឡាញ់ ស្រឡាញ់ទ្រង់ណាស់!

សេចក្តី ស្រឡាញ់របស់ទ្រង់គឺ ជាអ្វី មួយ ដែលខ្ញុំចង់មើ លឃើ ញ និ ងយល់បាន!
ខ្ញុំស្រឡាញ់ ស្រឡាញ់ទ្រង់ណាស់!

ខ្ញុំចង់បង្ហាញអ្នកដទៃ ដោយសេចក្តី ស្រឡាញ់ទ្រង់គឺ ពិ តប្រាកដ!
ខ្ញុំស្រឡាញ់ ស្រឡាញ់ទ្រង់ណាស់!

គ្រូបង្រៀនអានអក្សរនៅផ្នែកពណ៌ខ្មៅ ហើយកុមារឆ្លើយតប ដោយអានតាមតែនៅផ្នែកពណ៌ខៀវវិញ។ ក្រោយមក សូមលើកទឹកចិត្តពួកគេឱ្យសរសេរលើក្តាគោះរបស់ពួកគេតាមក្រុម ដោយសរសេរសំណួរពីរពួកគេនៅលើក្តាខៀន។ សូមមើលចំណាប់អារម្មណ៍ដែលពួកគេគោះឆ្លងអ្វីដែលពួកគេបានសរសេរនោះចុះ!

ការប្រែចិត្ត

ទូលបង្គំសោកស្តាយគ្រប់រាល់អំពើបាបរបស់ទូលបង្គំ។ សូមលាងសំអាតទូលបង្គំ។



រឿងប្រៀបធៀបអំពីអ្នកបម្រើដែលមិនអត់ទោស ម៉ាថាយ ១៨.២១-៣៥

ទំនុកដំកើង ៥១.២

សូមលាងទូលបង្គំឲ្យបានស្អាត ពីអំពើទុច្ចរិតរបស់ទូលបង្គំ
ហើយសូមសម្អាតទូលបង្គំពីអំពើបាបផង!

ការប្រែចិត្ត

តើ អ្នកអាចនិ យាយបានទេ?

ទូលបង្គំសោកស្តាយគ្រប់ឆាន់អំពើបាបរបស់ទូ លបង្គំ។ សូមលាងសំអាតទូលបង្គំ។

ទំនុកដំកើ ង ៥១.២

សូមលាងទូលបង្គំឲ្យបានស្អាត ពីអំពើទុច្ចរិតរបស់ទូលបង្គំ ហើយសូមសម្អាតទូលបង្គំពីអំពើបាបផង!

តើ អ្នកអាចស្វែងរកបានទេ?

ម៉ាថាយ ៦.៩-១៥

កិ ច្ចការ ៣.១៩

១យ៉ូហាន ១.៩

តើអ្នកមានអារម្មណ៍យ៉ាងដូចម្តេច ក្រោយពេលដែលអ្នកធ្វើអ្វីមួយខុស?

តើអ្នកមានអារម្មណ៍យ៉ាងដូចម្តេច ក្រោយពេលដែលអ្នកត្រូវបានអត់ទោសឲ្យ?

តើ អ្នកអាចដឹ ងបានទេ?

តើអ្វី ដែលរារាំងអ្នកពីការនិយាយថា “ខ្ញុំសុំទោស”?

ការប្រែចិត្ត

"ការអធិស្ឋានពេតលីង"

សូមនាំកុមារចំណាយពេលអធិស្ឋានផ្ទាល់ៗខ្លួនម្តងទៀត ដោយការអធិស្ឋាន "សូមជួយឱ្យទូលបង្គំស្រឡាញ់ និងស្តាប់បង្គាប់ទ្រង់"។ សូមឱ្យកុមារថាតាមសេចក្តីអធិស្ឋាន។ សូមលើកទឹកចិត្តពួកគេឱ្យអធិស្ឋានតែសេចក្តីអធិស្ឋានត្រឹមតែមួយប្រយោគ ដោយទូលសូមព្រះទៅតាមពាក្យផ្ទាល់ខ្លួនរបស់ពួកគេ ដើម្បីសូមទ្រង់ជួយបង្រៀនពីសេចក្តីស្រឡាញ់ និងការស្តាប់បង្គាប់ទ្រង់។ ពួកគេអំពាវនាវតាមព្រះនាមផ្សេងៗរបស់ព្រះអង្គ ហើយនិងស្តាប់ព្រះហស្តរបស់ទ្រង់ ដូចដែលបានចែកចាយក្នុងមេរៀនជាគំរូស្រាប់។

សូមពណ៌នា!

- តើអ្វីជាការពិបាកបំផុតសម្រាប់អ្នក ដើម្បីយល់អំពីការអត់ទោស?
- ហេតុអ្វីបានជាការនោះពិបាក ដើម្បីអត់ទោសអ្នកដទៃ ដែលធ្វើឱ្យអ្នកឈឺចាប់?
- ហេតុអ្វីបានជាពិបាកក្នុងការនិយាយថា "ខ្ញុំសុំទោស សូមអត់ទោសឱ្យខ្ញុំផង"?
- តើអ្នកមានអារម្មណ៍យ៉ាងណា ក្រោយពេលចូលដោយបានសំអាតនៅចំពោះព្រះ ឪពុកម្តាយរបស់អ្នក បងប្អូនប្រុសស្រីរបស់អ្នក ឬ មិត្តភ័ក្តិរបស់អ្នក?

សូមនាំការពិភាក្សា ដោយនិយាយអំពីព្រះទ័យរបស់ព្រះសម្រាប់ការអត់ទោសគ្រប់ៗទាំងអស់ពីបាបរបស់យើង។ ព្រះអង្គជាគ្រូបង្វឹកយើង ហើយដោយព្រោះទ្រង់អត់ទោសយើង ទើបយើងត្រូវតែមានឆន្ទៈដើម្បីអត់ទោសដល់អ្នកដទៃដែរ។ អ្នកប្រហែលជាចង់អានសេចក្តីអធិស្ឋានរបស់ព្រះទាំងអស់គ្នាហើយ។ សូមលើកទឹកចិត្តកុមារ ឱ្យចែកចាយដោយសេរីអំពីពេលដែលពួកគេពិបាកក្នុងការអត់ទោសឱ្យ និងធៀបនឹងការដែលគេត្រូវបានអត់ទោសឱ្យ ពួកគេមានអារម្មណ៍យ៉ាងណា។

ការប្រែចិត្ត

តើ អ្នកអាចស្តាប់លឺ ទេ?

រឿងប្រៀបធៀបអំពីអ្នកបម្រើដែលមិនអត់ទោស ម៉ាថាយ ១៨.២១-៣៥

ពេលនោះពេត្រុសចូលមកជិតព្រះអង្គ ហើយទូលថា៖ “ព្រះអម្ចាស់អើយ បើបងប្អូនខ្ញុំចេះតែប្រព្រឹត្តអំពើបាបមកលើខ្ញុំ តើខ្ញុំត្រូវអត់ទោសឲ្យគាត់ប៉ុន្មានដង? រហូតដល់ប្រាំពីរដងឬ?” ព្រះយេស៊ូមានព្រះបន្ទូលទៅគាត់ថា៖ “ខ្ញុំប្រាប់អ្នកថា មិនមែនប្រាំពីរដងទេ គឺ ចិតសិបដងប្រាំពីរដង។ រួចទ្រង់ចាប់ផ្តើមនិយាយរឿងមួយទៀតប្រាប់ពួកគេ។ មានស្តេចមួយអង្គ ដែលចង់គិតបញ្ជីជាមួយពួកអ្នកបម្រើ រួចទ្រង់ក៏ហៅអ្នកបម្រើបស់ទ្រង់មកទូទាត់បំណុល។ មានកូនបំណុលម្នាក់ដែលជំពាក់ប្រាក់យ៉ាងច្រើន ដែលចំនួនប្រាក់នោះ គាត់នឹងមិនអាចសងបំណុលស្តេចនោះបានឡើយ។ ស្តេចបានមានបន្ទូលថា “ដោយព្រោះអ្នកនោះគ្មានអ្វីសង ចៅហ្វាយរបស់គាត់បញ្ជាឲ្យលក់ខ្លួនគាត់ ទាំងប្រពន្ធ ទាំងកូន ទាំងរបស់បរដែលគាត់មាន ដើម្បីយកប្រាក់មកសងបំណុលនោះ”។ អ្នកបម្រើនោះក៏លុតជង្គង់នៅចំពោះស្តេច ទូលអង្វរថា “បពិត្រព្រះករុណា សូមទ្រង់មេត្តាកុំធ្វើដូច្នោះឡើយ! សូមទ្រង់ផ្តល់សេចក្តីមេត្តាករុណាដល់ខ្ញុំ និងគ្រួសារខ្ញុំផង”។ ស្តេចមានព្រះហឫទ័យអាណិតអាសូរដល់គាត់ ក៏មានបន្ទូលថា “ខ្ញុំដោះលែងអ្នក ទាំងលុបចោលបំណុលអ្នកទៀតផង”។ ប៉ុន្តែ សូមសាកល្បងស្មានទៅមើលថា តើអ្នកបម្រើនោះ បានធ្វើអ្វីដូចចៅហ្វាយគាត់ធ្វើឬទេ? ពេលអ្នកបម្រើនោះចេញទៅ គាត់បានជួបនឹងគូកនរបស់ខ្លួនម្នាក់ ដែលជំពាក់ប្រាក់គាត់មួយរយដេណារី គាត់និយាយទៅកាន់អ្នកនោះថា “ឯងអ្នកមិនព្រមសងបំណុលគ្រប់ចំនួនប្រាក់ ដែលអ្នកបានជំពាក់ខ្ញុំទេ ខ្ញុំនឹងចាប់អ្នកយកទៅដាក់គុកឲ្យខានតែបាន”។ គូកនរបស់អ្នកនោះក៏ក្រាបចុះហើយអង្វរថា “សូមមេត្តាពន្យាពេលឲ្យគ្រាផង ខ្ញុំសូមអង្វរដល់ឯង”។ តែអ្នកបម្រើដែលមានចិត្តឃោរឃៅនោះ គ្មានសេចក្តីអាណិតអាសូរដល់គូកនរបស់គាត់ឡើយ។ ផ្ទុយទៅវិញ គាត់បានចាប់អ្នកនោះទៅដាក់គុក។ មិនយូរប៉ុន្មានក្រោយពេលដែលស្តេចដឹងរឿងរ៉ាវ ដែលអ្នកបម្រើនោះបានធ្វើ។ ស្តេចមានព្រះទ័យក្រោធជាខ្លាំង និងបាននិយាយថា “នែអ្នកបម្រើអាក្រក់! យើងបានលុបបំណុលរបស់ឯងចោលទាំងអស់ ពេលឯងបានអង្វរដល់យើង។ ដូច្នេះ តើមិនគួរឲ្យឯងអាណិតមេត្តាដល់គូកនរបស់ឯង ដូចយើងបានអាណិតមេត្តាដល់ឯងទេឬ?” តើអ្នកដឹងទេថា តើស្តេចនោះធ្វើអ្វីចំពោះអ្នកបម្រើនោះ? ទ្រង់បានចាប់អ្នកនោះដាក់គុក ហើយធ្វើទារុណកម្ម រហូតដល់អ្នកនោះបានសងបំណុលគ្រប់ចំនួន។

តើ អ្នកអាចធ្វើ វាបានទេ?

- សូមប្រែចិត្តចេញពីអំពើបាបរបស់អ្នក ជារៀងរាល់ថ្ងៃ ដោយទូលសូមព្រះសំអាតអ្នកឲ្យបានស្អាតដូចហេម:។
- សូមជឿថា ព្រះអង្គលាងសំអាតគ្រប់រាល់អំពើបាបរបស់អ្នកបាន។
- សូមទូលសូមព្រះឲ្យជួយអ្នកកុំប្រព្រឹត្តបាប។
- សូមទូលសូមព្រះឲ្យជួយអ្នកឲ្យជាអ្នកអត់ទោស និងមានចិត្តសប្បុរស។
- សូមត្រៀមខ្លួនជាស្រេច ដើម្បីអត់ទោសអ្នកដទៃ និងមិនចង់កំហឹងនឹងអ្នកទាំងនោះឡើយ។

ការប្រែចិត្ត

សូមសាកល្បង!

ភ្លើងក្រហម ភ្លើងបៃតង

១. សម្រាប់ល្បែងកំសាន្តនេះ សូមបង្ហាញអ្នកលេងបន្ទាត់ចាប់ផ្តើម និងបន្ទាប់បញ្ចប់។

២. សូមប្រាប់ដល់អ្នកលេងទាំងអស់ ឱ្យឈរខាងក្រោយបន្ទាត់ចាប់ផ្តើម។

៣. សូមពន្យល់អ្នកលេងថា នៅពេលដែលអ្នកដឹកនាំស្រែកថា “ភ្លើងបៃតង” អ្នកលេងទាំងអស់អាចរត់ឆ្ពោះទៅកាន់បន្ទាប់បញ្ចប់។ តែពេលដែលអ្នកដឹកនាំស្រែកថា “ភ្លើងក្រហម” អ្នកលេងទាំងអស់ត្រូវឈប់ភ្លាមៗ។ អ្នកលេងណាដែលមិនឈប់ ត្រង់ចំណុច “ភ្លើងក្រហម” ទេ ពួកគេត្រូវត្រឡប់ទៅចំណុចបន្ទាត់ចាប់ផ្តើមវិញ។

៤. សូមប្រាប់អ្នកជួយដទៃទៀតឈរនៅត្រង់បន្ទាត់បញ្ចប់។ ហើយងាកជុំវិញមើលអ្នកលេងទាំងនោះ។ សូមឱ្យជម្រើសរវាង “ភ្លើងបៃតង” និង “ភ្លើងក្រហម”។ បើអ្នកលេងម្នាក់ណាដែលទៅដល់បន្ទាប់បញ្ចប់មុនគេ អ្នកនោះជាអ្នកឈ្នះ។

៦. ពេលអ្នកជួយប្រាប់ថា “ភ្លើងក្រហម” អ្នកជួយសូមមើលជុំវិញ និងមើលគ្រប់អ្នកលេង តើគេបានឈប់ឬនៅ។ បើមានអ្នកលេងណាកំពុងរត់ ទោះលឺសំលេងស្រែកថា “ភ្លើងក្រហម” អ្នកនោះបានល្មើសនឹងលក្ខន្តិកល្បែងនោះហើយ។ ដូច្នេះ អ្នកនោះអាច ១.ឈប់ ២.ត្រឡប់ទៅបន្ទាប់ចាប់ផ្តើមម្តងទៀត ៣.ចាប់ផ្តើមម្តងទៀតក្រោយចប់ជុំនេះ។

៧. សូមលេងល្បែងនេះបី ឬប្លែនដង

- សេចក្តី ពិ តដែលផ្សារភ្ជាប់នឹ ងជី វិ ត៖ នេះគឺ ជាការចង្អុលបង្ហាញយ៉ាងច្បាស់ពី ការប្រែចិ ត្ត: ពេលដែលនរណាម្នាក់លេងខុសលក្ខន្តិ ក គេត្រូវ ១.ឈប់លេង ២.ត្រឡប់ទៅបន្ទាប់ចាប់ផ្តើ មម្តងទៀត ៣.ចាប់ផ្តើ មម្តងទៀតក្រោយចប់ជុំនេះ។

សំណួរ

១. តាមល្បែងនេះ តើអ្នកត្រូវធ្វើអ្វី ពេលអ្នកលឺអ្នកដឹកនាំស្រែកថា “ភ្លើងក្រហម”? បើសិនជាអ្នកនៅរត់ ឬធ្វើចលនា អ្នកត្រូវ ១.ឈប់លេង ២.ត្រឡប់ទៅបន្ទាប់ចាប់ផ្តើមម្តងទៀត ៣.ចាប់ផ្តើមម្តងទៀតក្រោយចប់ជុំនេះ។

២. តាមរយៈព្រះគម្ពីរ តើអ្នកបម្រើម្នាក់នោះបានទទួលព្រះគុណ និងការអត់ទោសមកពីស្តេច ដែរឬទេ? (ពិតណាស់) ចុះតើអ្នកបម្រើម្នាក់នោះផ្តល់ការអាណិតអាសូរ និងការអត់ទោសដល់គូកនដែលជំពាក់គាត់ ដែរឬទេ? (អត់ទាល់តែសោះ) តើស្តេច ទ្រង់ពេញចិត្ត ឬមិនពេញចិត្តជាមួយនឹងអ្នកបម្រើ ដែលមិនអត់ទោសនោះ? (ពិតជាមិនពេញចិត្តទាល់តែសោះ)

៣. ព្រះយេស៊ូវ ទ្រង់ផ្តល់ឱ្យយើងនូវការអត់ទោស។ ព្រះអង្គឱ្យយើងនូវព្រះគុណ។ បើសិនជាទូលបង្គំធ្វើអ្វីដែលទ្រង់មិនសព្វព្រះហឫទ័យ សូមរំលឹកទូលបង្គំ ឱ្យចេះប្រែចិត្ត៖ ឈប់បន្តធ្វើ រួចបញ្ចាំង ងាកបែរក្រោយ ហើយនិងចាប់ផ្តើមសារជាថ្មីឡើងវិញ។ សូមទ្រង់បង្ហាញទូលបង្គំ ចំណុចណាខ្លះដែលទូលបង្គំត្រូវការការប្រែចិត្ត។ (ឈប់បន្តិច) សូមអរព្រះគុណទ្រង់ សម្រាប់ព្រះគុណ សម្រាប់ការលាង និងសម្អាតទូលបង្គំ ព្រមទាំងការអត់ទោសដល់ទូលបង្គំ។ សូមឱ្យទូលបង្គំចេះ អត់ទោសដល់អ្នកដទៃផងដែរ។

©2018 The Prayer Covenant for Children/Games provided by GameLife77.com. All rights reserved.

ការប្រែចិត្ត

ក្រដាសកិច្ចការ

១ តើ អ្នកចាំសេចក្តី អធិ ស្ឋានទំព័ រទី ៤ អំពី ការប្រែចិ ត្ត? សូមសរសេរវាចុះខាងក្រោម៖

២ បំពេញចន្លោះ

ទំនុកដំកើ ង ៥១.២ "សូមលាងខ្ញុំ _____ ពី _____

សូមសំអាត_____ ផង។ ។

៣ ហេតុអ្វី យើ ងត្រូ វលន់តួអំពើ បាបរបស់យើ ង ទៅកាន់ព្រះជាម្ចាស់រាល់ថ្ងៃ?

៤ ហេតុអ្វី សំខាន់ ពេលដែលយើ ងអត់ទោសឲ្យអ្នកដទៃ?

៥ ភ្ជាប់ការអត់ទោស:

សូមកាត់ក្រដាសជាឆ្នូតៗប៉ុនគ្នា។ នៅចុងម្ខាងនៃក្រដាសឆ្នូត សរសេរថា "ព្រះអង្គអត់ទោសដ៏ ខ្ញុំ ពេល_____" នៅចុងម្ខាងទៀត សរសេរថា "ខ្ញុំអត់ទោសឲ្យអ្នកដទៃ ពេល_____" ហើ យបិ ទចុងទាំងពី រភ្ជាប់គ្នា។ អ្នកអាចព្យួរវានៅក្នុងបន្ទប់អ្នក ដូចជាការរំលឹ កអ្នក ពី ការអរព្រះគុណព្រះ សម្រាប់ការអត់ទោសបាបដែលមិ នដែលបញ្ចប់។

ការប្រែចិត្ត

ការគោះឡើង!

តើ យើងគួរធ្វើ អ្វី ពេលយើង មិន ស្តាប់បង្គាប់?

ប្រែចិត្ត អធិស្ឋាន និង ងាកចេញ!

តើ យើងគួរធ្វើ អ្វី ពេលយើង និយាយអ្វី ខុស?

ប្រែចិត្ត អធិស្ឋាន និង ងាកចេញ!

តើ យើងគួរធ្វើ អ្វី ពេលយើង និយាយកុហក?

ប្រែចិត្ត អធិស្ឋាន និង ងាកចេញ!

តើ យើងគួរធ្វើ អ្វី ពេលយើង ចាប់ផ្តើម ឈ្លោះ?

ប្រែចិត្ត អធិស្ឋាន និង ងាកចេញ!

តើ យើងគួរធ្វើ អ្វី ពេលយើង មិន អត់ទោសឲ្យអ្នកដទៃ?

ប្រែចិត្ត អធិស្ឋាន និង ងាកចេញ!

តើ យើងគួរធ្វើ អ្វី ពេលយើង មិន ចិត្តល្អនិង អ្នកដទៃ?

ប្រែចិត្ត អធិស្ឋាន និង ងាកចេញ!

តើ យើងគួរធ្វើ អ្វី ពេលយើង មិន ចង់ដើរតាមផ្លូវរបស់យើង?

ប្រែចិត្ត អធិស្ឋាន និង ងាកចេញ!

គ្រូបង្រៀនអានអក្សរនៅផ្នែកពណ៌ខ្មៅ ហើយកុមារឆ្លើយតប ដោយអានតាមតែនៅផ្នែកពណ៌ខៀវវិញ។ ក្រោយមក សូមលើកទឹកចិត្តពួកគេឲ្យសរសេរលើក្តាគោះរបស់ពួកគេតាមក្រុម ដោយសរសេរសំណួរពរពួកគេនៅលើក្តាខៀន។ សូមមើលចំណាំអារម្ម ដែលពួកគេគោះឮអ្វីដែលពួកគេបានសរសេរនោះចុះ!

ការថ្វាយបង្គំ

ទូលបង្គំនឹងសរសើរដល់ព្រះយេហូវ៉ាអស់អំពីចិត្ត។

រឿងរ៉ាវពីកំណើតរបស់ព្រះយេស៊ូវគ្រីស្ទ លូកា ជំពូក១ និង ២

ទំនុកដំកើង ៩.១

ខ្ញុំនឹងសរសើរដល់ព្រះយេហូវ៉ាអស់អំពីចិត្ត
ខ្ញុំនឹងប្រាប់អំពីការ អស្ចារ្យទាំងអស់របស់ទ្រង់។

ការថ្វាយបង្គំ

តើ អ្នកអាចនិ យាយបានទេ?

ទូលបង្គំនឹងសរសើរដល់ព្រះយេហូវ៉ាអស់អំពីចិត្ត។

ទំនុកដំកើង ៩.១

ខ្ញុំនឹងសរសើរដល់ព្រះយេហូវ៉ាអស់អំពីចិត្ត ខ្ញុំនឹងប្រាប់អំពីការ អស្ចារ្យទាំងអស់របស់ទ្រង់។

តើ អ្នកអាចស្វែងរកបានទេ?

ទំនុកដំកើង ១៤៥

ម៉ាថាយ ២១.១៦-១៧

១ថែស្សាឡូនិច ៥.១៨

វិវរណៈ ៤.៨-១១

តើអ្វីជាការសរសើរតម្កើង?

តើខ្ញុំអាចសរសើរតម្កើងព្រះយ៉ាងដូចម្តេច?

តើ អ្នកអាចដឹងបានទេ?

ពេលណាខ្ញុំអាចសរសើរតម្កើងព្រះ?

ការថ្វាយបង្គំ

"ការអធិ ស្ឋានពេតលី ង"

សូមនាំកុមារចំណាយពេលអធិស្ឋានផ្ទាល់ខ្លួនម្តងទៀត ដោយការអធិស្ឋាន "សូមជួយឱ្យទូលបង្គំស្រឡាញ់ និងស្តាប់បង្គាប់ទ្រង់"។ សូមឱ្យកុមារថាតាមសេចក្តីអធិស្ឋាន។ សូមលើកទឹកចិត្តពួកគេឱ្យអធិស្ឋានតែសេចក្តីអធិស្ឋានត្រឹមតែមួយប្រយោគ ដោយទូលសូមព្រះទៅតាមពាក្យផ្ទាល់ខ្លួនរបស់ពួកគេ ដើម្បីសូមទ្រង់ជួយបង្រៀនពីសេចក្តីស្រឡាញ់ និងការស្តាប់បង្គាប់ទ្រង់។ ពួកគេអំពាវនាវតាមព្រះនាមផ្សេងៗរបស់ព្រះអង្គ ហើយនិងស្គាល់ព្រះហស្តរបស់ទ្រង់ ដូចដែលបានចែកចាយក្នុងមេរៀនជាគំរូស្រាប់។

សូមពណ៌ នា!

- ពេលខ្លះការសរសើរតម្កើងរបស់ខ្ញុំហាក់ដូចជាងាយស្រួលជាងអ្នកដទៃសរសើរតម្កើងព្រះ។
- សូមចែកចាយ ពេលដែលអ្នកមានអារម្មណ៍ងាយស្រួលក្នុងការសរសើរតម្កើងព្រះ។
- សូមចែកចាយ ពេលអ្នកមានអារម្មណ៍លំបាកក្នុងការសរសើរតម្កើងព្រះ។
- សូមមានចិត្តអរព្រះគុណ មិនគ្រាន់តែចង់ឱ្យព្រះសព្វព្រះហឫទ័យតែប៉ុណ្ណោះទេ តែចិត្តអរព្រះគុណជាផ្នែកមួយនៃការសរសើរតម្កើងទ្រង់។ សូមសរសើរតម្កើងទ្រង់ពេលអ្នកភ្ញាក់ឡើង! សូមសរសើរតម្កើងទ្រង់ ពេលអ្នកទៅសាលារៀន និងត្រឡប់មកផ្ទះវិញ! សូមសរសើរតម្កើងទ្រង់មុនពេលអ្នកចូលគេង!
- សូមអនុវត្តន៍ជាទំលាប់នៃការសរសើរតម្កើង ដែលមិនត្រឹមតែព្រះអង្គសព្វព្រះហឫទ័យតែប៉ុណ្ណោះទេ តែថែមទាំងធ្វើឱ្យអ្នកមានអារម្មណ៍រីករាយ និងព្រះពរផងដែរ!

កុមាររាល់គ្នានឹងយល់ពីការថ្វាយបង្គំ ពួកគេបង្ហាញការថ្វាយបង្គំនេះដោយក្តីស្រឡាញ់ដល់ព្រះយេស៊ូវ និងការនេះនឹងបន្តរីកសុះសាយ។ សូមចែកចាយជាមួយពួកគេ នូវរបៀបនានានៃការថ្វាយបង្គំដែលពួកគេចូលចិត្តបំផុត។ សូមប្រាកដ ការអរព្រះគុណត្រូវបានលើកឡើងដែរ។
វាជាការលំបាកដើម្បីអរព្រះគុណ គ្រប់ការទាំងអស់ គ្រប់ពេលទាំងអស់។ ដូច្នេះ វានឹងមិនយឺតដើម្បីចាប់ផ្តើមអនុវត្តជាទំលាប់ នៃការសរសើរតម្កើង និងការអរព្រះគុណទ្រង់។

ការថ្វាយបង្គំ

តើ អ្នកអាចស្តាប់លឺ ទេ?

រឿងរ៉ាវទាក់ទងនឹងការប្រសូត្ររបស់ព្រះយេស៊ូវគ្រីស្ទ (លូកា ជំពូក១ និង ២)

កាលពីពេលកន្លងទៅដ៏ឆ្ងាយ ជាង ២ពាន់ឆ្នាំមុន មានស្ត្រីម្នាក់ឈ្មោះម៉ារី ត្រូវបានទេវតាមួយអង្គឈ្មោះកាព្រីយ៉ែល បានលេចមកឯនាង។ ទេវតានោះបានផ្តល់សារដ៏ពិសេសមួយដល់នាង។ ទេវតានោះបាននិយាយថា កុំខ្លាចអី ម៉ារីអើយ ដ្បិតព្រះបានប្រោសមេត្តាដល់នាងហើយ។

នាងនឹងមានគភ៌ប្រសូតបានបុត្រា១ ដែលនាងត្រូវថ្វាយព្រះនាមថា យេស៊ូវ។ បុត្រនោះនឹងបានជាធំឧត្តម ហើយគេនឹងហៅទ្រង់ ជាព្រះរាជបុត្រានៃព្រះដ៏ខ្ពស់បំផុត”។ នោះក៏មានអំណរយ៉ាងអស្ចារ្យ តាមការប្រសូត្ររបស់ព្រះយេស៊ូវ។ “នោះស្រាប់មានពួកពលបរិវារកកកុញពីស្ថានសួគ៌ មកនៅជាមួយនឹងទេវតានោះ ក៏ពោលសរសើរដល់ព្រះថា ‘សូស្តីដល់ព្រះនៅស្ថានដ៏ខ្ពស់បំផុត ហើយសេចក្តីសុខសាន្តនៅផែនដី នៅកណ្តាលមនុស្ស ដែលជាទីគាត់ព្រះហឫទ័យដល់ទ្រង់” ពួកអ្នកគង្វាលភ្លាមនោះក៏បានមកមើល ហើយថ្វាយបង្គំបុត្រតូចដែលជាស្តេចតូចនោះ។ ពួកគេសរសើរតម្កើង និងថ្វាយសាក្សីរឿងដល់ព្រះ ពីអ្វីដែលពួកគេបានឃើញ និងបានលឺ។ ពួកហោរាដែលបានមកពីទិសខាងកើត ក៏ស្វែងរកបុត្រតូចយេស៊ូវដែរ។ មានផ្កាយដ៏ភ្លឺថែងចាំបានបង្ហាញផ្លូវពួកហោរានាពេលយប់ ឱ្យមកថ្វាយបង្គំមហាក្សត្ររបស់ពួកគាត់។ មានដូចជាម៉ារី យ៉ូសែប ពួកអ្នកគង្វាល និងពួកហោរា មកគោរពថ្វាយបង្គំព្រះយេស៊ូវ យើងក៏ត្រូវតែគោរពថ្វាយបង្គំទ្រង់ដូចគ្នា។ នៅថ្ងៃមួយ ពេលដែលយើងនៅឯនគរស្ថានសួគ៌ យើងនឹងឈរនៅជុំវិញបល្ល័ង្ករបស់ទ្រង់ គោរពថ្វាយបង្គំព្រះអង្គជារៀងរហូត។

តើ អ្នកអាចធ្វើ វាបានទេ?

- សូមសរសើរតម្កើងព្រះអម្ចាស់រាល់ថ្ងៃ។
- សូមសរសើរតម្កើងព្រះអម្ចាស់គ្រប់កាលៈទេសៈទាំងអស់។ ការនេះជាជម្រើស។
- សូមថ្វាយចិត្តទាំងអស់ព្រះគុណដល់ព្រះអង្គ និងសម្រាប់អ្នកដែលទ្រង់ដាក់នៅជុំវិញជីវិតអ្នកផងដែរ ដែលមាន គ្រួសាររបស់អ្នក មិត្តភ័ក្តិរបស់អ្នក និងលោកគ្រូអ្នកគ្រូរបស់អ្នក។
- សូមសរសើរតម្កើងព្រះឱ្យបានខ្ជាប់ខ្ជួន។

ការថ្វាយបង្គំ

សូមសាកល្បង!

ចម្រៀងជាចំណង់ចំណូលចិត្តរបស់ខ្ញុំ

១. សូមបង្ហាញដោយធ្វើកាយវិការដៃ សម្រាប់ចម្រៀងមានចំណងជើងថា “Humble Yourself in the Sight of the Lord.”។

២. តាមកេហាទំព័រ www.youtube.com/watch?v=qpyDJMCL9yc

៣. (បន្ទាបខ្លួនចុះ ឬ humble yourself = សូមដាក់ដៃទាំងពីរផ្គូបគ្នា និងអោនមុខទៅក្រោម។ ទ្រង់នឹងតម្កើងឡើង ឬ He will lift you up = ដោយកាយវិការបន្ទន់ជង្គង់ ដំបូងជង្គង់មួយត្រូវលើកឡើង បន្ទាប់មកឈរត្រង់ បន្ទាប់មកទៀត យកដៃទាំងពីរសង្រួមចូលគ្នាថ្វាយបង្គំដល់ព្រះអម្ចាស់)។

៤. សូមចែកអ្នកលេងជា ២ក្រុម និងអនុញ្ញាតឱ្យក្រុមនីមួយៗចម្រៀង១បទ ដើម្បីស្តាប់ ហើយនិងបង្កើតកាយវិការដៃដោយខ្លួនឯង (មានចម្រៀងថ្វាយបង្គំ ២បទ ដែលអ្នកចូលចិត្ត ត្រៀមរួចជាស្រេច)។

៥. សូមឱ្យក្រុមនីមួយៗអនុវត្តន៍ហាត់ចលនាដៃ បន្ទាប់មកបង្រៀនការធ្វើកាយវិការដៃរបស់ពួកគេ ឬ “បង្ហាញ” ដល់ក្រុមដទៃទៀត។

៦. ពេលហៀបបញ្ចប់ សូមឱ្យអ្នកលេងទាំងអស់បោះឆ្នោត ថាតើបទចម្រៀងថ្វាយបង្គំណាមួយ (ក្នុងចំណោម ពាបទ) ដែលគេចូលចិត្តជាង។ ក្រោយមកសួរថា “តើហេតុអ្វីបានជាបទចម្រៀងនោះជាចំណង់ចំណូលចិត្តរបស់អ្នក?”

- សេចក្តី ពិ តភ្ជាប់នឹ ងជី វិ ត៖ កុមារកំពុងរៀនថ្វាយបង្គំ តាមរបៀបដែលមានអត្ថន័ យសម្រាប់ពួកគេ ហើ យការសំខាន់បំផុតនោះ កុមារកំពុងចាប់ផ្តើ មឆ្លុះបញ្ចាំង និ ងគិ តថា “តើ បទចម្រៀងថ្វាយបង្គំអ្វី ដែលពួកគេចូលចិ ត្ត និ ងហេតុអ្វី ”។ អ្នកបង្ហាត់បង្រៀន សូមចែកចាយចម្រៀងថ្វាយបង្គំជាចំណង់ចំណូលចិ ត្តរបស់អ្នក និ ងចែកចាយជាមួយកុមារថា ហេតុអ្វី ចម្រៀងនោះជាការចូលចិ ត្តរបស់អ្នក។

សំណួរ

១. តាមល្បែងកំសាន្តនេះ ហេតុអ្វីបានជាអ្នកជ្រើសរើសបទចម្រៀងថ្វាយបង្គំនោះ? (ចំណុចសំខាន់៖ ចំណាយពេលសួរសំណួរ “ហេតុអ្វី”។ ការនេះនឹងជួយឱ្យកុមារចាប់ផ្តើមពិចារណាការថ្វាយបង្គំ និងហេតុអ្វីបានជាពួកគេរីករាយក្នុងការថ្វាយបង្គំ ព្រមទាំងបទចម្រៀងអ្វីជាការចូលចិត្តរបស់ពួកគេ។)

២. ក្នុងព្រះគម្ពីរ ព្រះបានបញ្ជូនព្រះរាជបុត្រាទ្រង់ ព្រះយេស៊ូវ ពួកអ្នកគង្វាល និងពួកហោរា សូម្បីតែស្តេចលើផែនដី ក៏មកថ្វាយបង្គំព្រះយេស៊ូវផងដែរ។ តើផ្នែកណាសំខាន់ក្នុងជីវិតព្រះយេស៊ូវ ការប្រសូត្រ ជីវិតរបស់ទ្រង់ ការសុគតសងថ្លៃបាប ឬ ការរស់ពីស្លាប់ឡើងវិញរបស់ទ្រង់? តើអ្នកត្រូវអរព្រះគុណទ្រង់ទេក្នុងជីវិតរបស់អ្នក?

៣. ឱ ព្រះយេស៊ូវអើយ សូមអរព្រះគុណទ្រង់ សម្រាប់ការយាងមកប្រសូត្រ។ ព្រះយេស៊ូវអើយ អរព្រះគុណទ្រង់ ដែលទ្រង់ក្លាយជាព្រះអង្គសង្គ្រោះរបស់ទូលបង្គំ ដោយបានសុគតសងថ្លៃប្រោសលោះដ៏ទូលបង្គំ។ ព្រះយេស៊ូវអើយ អរព្រះគុណទ្រង់ ដែលទ្រង់ក្លាយជាព្រះអម្ចាស់របស់ទូលបង្គំ។ ព្រះយេស៊ូវអើយ សូមបង្ហាញទូលបង្គំផ្លូវផ្សេងៗ ដែលទូលបង្គំអាចថ្វាយបង្គំទ្រង់ ក្រៅពីការច្រៀងថ្វាយបង្គំទ្រង់។ (ឈប់បន្តិច) ព្រះយេស៊ូវអើយ សូមជួយទូលបង្គំអាចប្រាប់អ្នកដទៃទៀតអំពីស្នាព្រះហស្តដ៏អស្ចារ្យរបស់ទ្រង់ តាមរយៈមាត់ទូលបង្គំ សកម្មភាពទូលបង្គំ និងកិច្ចការរបស់ទូលបង្គំ។

©2018 The Prayer Covenant for Children/Games provided by GameLife77.com. All rights reserved.

ការថ្វាយបង្គំ

ក្រដាសកិច្ចការ

១ តើ អ្នកចាំសេចក្តី អធិ ស្ឋានជួរទី ៥ អំពី ការថ្វាយបង្គំ? សូមសរសេរចុះខាងក្រោម

២ សូមបំពេញឃ្លាខាងក្រោម

ទំនុកដំកើ ង ៩.១ "ខ្ញុំនឹ ង_____ ព្រះយេហូវ៉ាអស់អំពី _____

ខ្ញុំនឹ ង _____ ពី អស់ទាំង _____

៣ តើ អ្នកអាចប្រាប់ពី របៀបថ្វាយបង្គំព្រះយេស៊ូវ ផ្សេងៗពី គ្នា បានដែរឬទេ?

៤ តើ ទម្រង់នៃការថ្វាយបង្គំបែបណា ដែលជាការចូលចិ ត្តរបស់អ្នក?

៥ ពេលឆ្លើ យតប

សូមបង្កើ តជាឧបករណ៍ តន្ត្រី (ម៉ារ៉ាខា) ដោយសាមញ្ញ និ ងរី ករាយ។ ផ្នែកខ្លះ
សូមចាក់បំពេញកែវដែលគ្មានទឹ ក ដោយអង្ករ ឬ គ្រាប់សណ្តែកសួត។ សូមតុបតែងដបដោយបិ តស្និ កគ័ រ
ឬ សរសេរខ្ទឹ ត។ សូមច្រៀងរាំថ្វាយព្រះយេស៊ូវ!

ការថ្វាយបង្គំ

ការគោះឡើង!

ព្រះយេស៊ូវសមនឹងទទួលការសរសើរតម្កើង!

អាម៉ែន អាម៉ែន!

យើងគួរសរសើរតម្កើងទ្រង់រាល់ថ្ងៃ!

អាម៉ែន អាម៉ែន!

វាផ្តល់ឲ្យទ្រង់នូវអំណរដ៏អស្ចារ្យ ដែលលើកូនរបស់ទ្រង់ច្រៀងឡើង!

អាម៉ែន អាម៉ែន!

ដូច្នេះ ឥឡូវនេះ សូមយើងច្រៀងសរសើរតម្កើងទ្រង់ឡើង!

អាម៉ែន អាម៉ែន!

ព្រះយេស៊ូវយាងមកសង្គ្រោះយើងចេញពីអំពើបាប!

អាម៉ែន អាម៉ែន!

យើងយកព្រះអង្គជាព្រះគ្រីស្ទ ស្តេចរបស់យើង ជារៀងដរាបតទៅ!

អាម៉ែន អាម៉ែន!

គ្រូបង្រៀនអានអក្សរនៅផ្នែកពណ៌ខ្មៅ ហើយកុមារឆ្លើយតប ដោយអានតាមតែនៅផ្នែកពណ៌ខៀវវិញ។ ក្រោយមក សូមលើកទឹកចិត្តពួកគេឲ្យសរសេរលើក្តាគោះរបស់ពួកគេតាមក្រុម ដោយសរសេរសំណូមពរពួកគេនៅលើក្តាខៀន។ សូមមើលចំណាប់អារម្មណ៍ ដែលពួកគេគោះនូវអ្វីដែលពួកគេបានសរសេរនោះចុះ!

ការប្តេជ្ញាចិត្ត

ព្រះយេស៊ូវអើយ ទូលបង្គំចង់ដើរតាមទ្រង់ ជាព្រះអម្ចាស់របស់ទូលបង្គំ។ សូមកែប្រែទូលបង្គំតាមដែលទ្រង់សព្វព្រះទ័យ។



ពេត្រុសមិនគ្រប់ល័ក្ខទេ លូកា ២២.៥៤-៦២

លូកា ៩.២៣

រួចទ្រង់មានព្រះបន្ទូលទៅមនុស្សទាំងអស់ថា
បើអ្នកណាចង់មកតាមខ្ញុំ ត្រូវឲ្យអ្នកនោះលះកាត់ចិត្តខ្លួនឯង
ទាំងផ្ទុកឈើឆ្កាងខ្លួនរាល់តែថ្ងៃ ហើយមកតាមខ្ញុំចុះ។

ការប្តេជ្ញាចិត្ត

តើ អ្នកអាចនិយាយបានទេ?

ព្រះយេស៊ូវអើយ ទូលបង្គំចង់ដើរតាមទ្រង់ ជាព្រះអម្ចាស់បស់ទូលបង្គំ។ សូមកែប្រែទូលបង្គំតាមដែលទ្រង់សព្វព្រះទ័យ។

លូកា ៩.២៣

រួចទ្រង់មានព្រះបន្ទូលទៅមនុស្សទាំងអស់ថា បើអ្នកណាចង់មកតាមខ្ញុំ ត្រូវឲ្យអ្នកនោះលះកាត់ចិត្តខ្លួន ទាំងផ្ទុកឈើឆ្កាងខ្លួន រាល់តែថ្ងៃ ហើយមកតាមខ្ញុំចុះ។

តើដើរតាមព្រះយេស៊ូវមានន័យយ៉ាងណា?

តើព្រះកំពុងកែប្រែខ្ញុំតាមរបៀបណា?

តើ អ្នកអាចដឹងបានទេ?

តើនរណា ឬ តើអ្វីដែលអ្នកប្តេជ្ញាចិត្តដើរតាម?

តើ អ្នកអាចស្វែងរកបានទេ?

ម៉ាថាយ ៤.១៨-២២

ម៉ាថាយ ១៦.២៤

កាឡាទី ២.២០

ការប្តេជ្ញាចិត្ត

"ការអធិស្ឋានពេតលីង"

សូមនាំកុមារចំណាយពេលអធិស្ឋានផ្ទាល់ខ្លួនម្តងទៀត ដោយការអធិស្ឋាន "សូមជួយឱ្យទូលបង្គំស្រឡាញ់ និងស្តាប់បង្គាប់ទ្រង់"។ សូមឱ្យកុមារថាតាមសេចក្តីអធិស្ឋាន។ សូមលើកទឹកចិត្តពួកគេឱ្យអធិស្ឋានតែសេចក្តីអធិស្ឋានត្រឹមតែមួយប្រយោគ ដោយទូលសូមព្រះទៅតាមពាក្យផ្ទាល់ខ្លួនរបស់ពួកគេ ដើម្បីសូមទ្រង់ជួយបង្រៀនពីសេចក្តីស្រឡាញ់ និងការស្តាប់បង្គាប់ទ្រង់។ ពួកគេអំពាវនាវតាមព្រះនាមផ្សេងៗរបស់ព្រះអង្គ ហើយនិងស្តាព្រះហស្តរបស់ទ្រង់ ដូចដែលបានចែកចាយក្នុងមេរៀនជាគំរូស្រាប់។

សូមពណ៌នា!

- ការប្តេជ្ញាចិត្តជាការសន្យាដោយស្មោះត្រង់ទៅនឹងនរណាម្នាក់ ឬ បុព្វហេតុណាមួយ។
- ការប្តេជ្ញាចិត្តជាប់ទាក់ទងនឹងពេលវេលា ប្រាក់កាស និងកិច្ចខិតខំប្រឹងប្រែង។ វាដូចជាចូលរួមនឹងក្រុមកីឡាណាមួយ ដែលទទួលបានផ្លែឈូល ត្រូវចូលរួមហ្វឹកហ្វាត់ និងត្រូវចូលរួមលេងដែរ។
- ព្រះយេស៊ូវចង់ឱ្យអ្នកប្តេជ្ញាចិត្តតាមទ្រង់ ធ្វើជាព្រះអម្ចាស់ក្នុងជីវិតរបស់អ្នក។
- "សូមកែប្រែទូលបង្គំតាមដែលទ្រង់សព្វព្រះទ័យ" ការនិយាយបែបនេះ គឺអ្នកមានឆន្ទៈរស់នៅជីវិតដែលប្តេជ្ញាចិត្តទាំងស្រុង សម្រាប់ព្រះយេស៊ូវគ្រីស្ទ។
- ការរក្សាការប្តេជ្ញាចិត្តមិនងាយស្រួលនោះទេ។

ពេលអ្នកនិយាយពីការប្តេជ្ញាចិត្ត សូមឱ្យកុមារចែកចាយការប្តេជ្ញាចិត្ត ដែលពួកគេធ្លាប់បានធ្វើ (ការលេងកីឡា ការលេងតន្ត្រី ។ល។) និងថាតើអ្វីដែលងាយស្រួល ព្រមទាំងការលំបាករបស់ពួកគេ ទាក់ទងនឹងការរក្សាការប្តេជ្ញាចិត្តទាំងនោះ។ សូមនិយាយអំពីអត្ថន័យ នៃអ្នកដើរតាមព្រះយេស៊ូវដោយប្តេជ្ញាចិត្តផងដែរ។ តើចំណុចអ្វីខ្លះ ដែលការប្តេជ្ញាចិត្តទាំងនោះខុសគ្នា? តើចំណុចអ្វីខ្លះ ដែលការប្តេជ្ញាចិត្តទាំងនោះស្រដៀងគ្នា? សូមលើកទឹកចិត្តកុមារ ឱ្យចែកចាយដោយសេរី និងដោយស្មោះត្រង់។

ការប្តេជ្ញាចិត្ត

តើ អ្នកអាចស្តាប់លឺ ទេ?

ពេត្រុសមិនគ្រប់ល័ក្ខទេ (លូកា ២២.៥៤.-៦២)

មានម្តងនោះពេត្រុសបាននិយាយទៅកាន់ព្រះយេស៊ូថា “ទោះបីជាមនុស្សទាំងអស់បដិសេធទ្រង់ក៏ដោយ ក៏ខ្ញុំនឹងមិនបដិសេធទ្រង់ដែរ”។ ព្រះយេស៊ូជ្រាបដឹងផ្សេងពីគាត់អរអាង ហើយបានប្រាប់ទៅគាត់ថា មុនមាន់រងាវបីដង គាត់នឹងបដិសេធមិនស្គាល់ទ្រង់ នៅដំណាក់សម្តេចសង្ឃ កន្លែងដែលព្រះយេស៊ូត្រូវបានចោទសួរ មុនពេលទ្រង់ត្រូវឆ្កាង។ ការនោះបានកើតឡើង ដូចអ្វីដែលព្រះយេស៊ូមានបន្ទូល។ មានស្ត្រីម្នាក់ឃើញពេត្រុស ហើយនិយាយថា “អ្នកបាននៅជាមួយព្រះយេស៊ូនោះដែរ។” ពេត្រុសប្រកែកឡើង “ទេ ខ្ញុំមិនស្គាល់មនុស្សនោះ (ព្រះយេស៊ូ) ទេ!” ពេលនោះ មានស្ត្រីម្នាក់ទៀតនិយាយទៅកាន់មនុស្សនៅទីនោះថា “អ្នកនេះ ជាពួកអ្នកនោះដែរ” គាត់ក៏បានប្រកែកម្តងទៀត។ ប៉ុន្មានម៉ោងក្រោយ ពេត្រុសភ័យខ្លាចខ្លាំងណាស់។ គាត់មិនចង់ឲ្យមនុស្សចំណាំគាត់ទៀត តែគេនៅតែបន្តនិយាយ។ “អ្នកនេះប្រាកដជាបាននៅជាមួយនឹងមនុស្សនោះដែរ។ អ្នកនិយាយដូចជាអ្នកស្រុកកាលីឡេ”។ តែពេត្រុសជេរប្រមាថ ទាំងស្បថឡើងថា “អ្នកអើយ ខ្ញុំមិនដឹងជាអ្នកថាដូចម្តេចទេ”។ ការនេះបានកើតឡើង ដូចជាព្រះយេស៊ូបានមានបន្ទូលរួចហើយ។ ភ្លាមនោះគាត់ក៏នឹកឃើញព្រះបន្ទូលនៃព្រះអម្ចាស់ ដែលមានព្រះបន្ទូលនឹងគាត់ រួចគាត់ចេញទៅក្រៅដោយយំក្តួល។ គាត់បានដឹងថា គាត់បានធ្វើនូវអ្វីដែលព្រះយេស៊ូបានប្រាប់ទុកជាមុន ហើយគាត់មានអារម្មណ៍មិនគប្បីក្រៃលែង។ ប៉ុន្តែ ព្រះយេស៊ូមិនដែលបោះបង់ចោលពេត្រុសឡើយ។ ក្រោយមក ក្រោយពេលដែលព្រះយេស៊ូរស់ឡើងវិញ ព្រះអង្គបានយាងទៅផ្ទេរទន្លេទីបេ ។ ក្រោយមក ពេលដែលព្រះយេស៊ូរស់ឡើងវិញជាមួយនឹងពួកសិស្សរបស់ទ្រង់ខ្លះ។ ព្រះយេស៊ូស្តួរពេត្រុសបីដង “ពេត្រុស តើអ្នកស្រឡាញ់ខ្ញុំទេ?” គ្រប់ពេលពេត្រុសឆ្លើយថា “ព្រះអម្ចាស់អើយ ទ្រង់ជ្រាបហើយថា ខ្ញុំស្រឡាញ់ទ្រង់” ហើយគ្រប់ពេលព្រះយេស៊ូមានបន្ទូលថា “សូមឲ្យចំណីដល់ហ្វូងចៀមខ្ញុំស៊ីផង”។ ព្រះយេស៊ូចង់ឲ្យពេត្រុសក្លាយជាសិស្សរបស់ទ្រង់ ដោយបង្កើតសិស្សបន្ត។ ទោះបីជាពេត្រុសមិនគ្រប់ល័ក្ខក៏ដោយ ព្រះយេស៊ូជ្រាបថា គាត់ពិតជាចង់ដើរតាមទ្រង់ ធ្វើជាព្រះអម្ចាស់របស់គាត់។ ចាប់ពីពេលនោះមក ពេត្រុសមិនដែលបដិសេធព្រះយេស៊ូម្តងទៀតឡើយ។

តើ អ្នកអាចធ្វើ វាបានទេ?

- សូមប្តេជ្ញាចិត្តដើរតាមព្រះយេស៊ូវ ធ្វើជាព្រះអម្ចាស់ក្នុងជីវិតអ្នក។
- សូមប្តេជ្ញាចិត្តអនុញ្ញាតឲ្យព្រះយេស៊ូវទប់ស្កាត់នូវគំនិតរបស់អ្នក សកម្មភាពរបស់អ្នក និងចំណង់របស់អ្នក។
- សូមឲ្យព្រះយេស៊ូវក្លាយជាអទិភាពជាងអ្វីៗទាំងអស់ក្នុងលោកិយនេះដែលនាំអ្នកឲ្យ ដើរតាមទ្រង់ ស្តាប់បង្គាប់ទ្រង់ និងមានលក្ខណៈដូចទ្រង់។

ការប្តេជ្ញាចិត្ត

សូមសាកល្បង!

ត្រូវ ឬ ខុស

១. សូមឱ្យអ្នកលេងឈរជាជួរចំកណ្តាលបន្ទប់ អ្នកលេងត្រូវឈរជាជួរពីខាងមុខ ដល់ខាងក្រោយ។

២. សូមចែងចែកជាជួរឈរនៅចំកណ្តាលបន្ទប់។ ខាងស្តាំ និងខាងឆ្វេង។ សូមពន្យល់ថា អ្នកនឹងសួរជាសំណួរ ហើយឱ្យពួកគេជាអ្នកឆ្លើយ ត្រូវ ឬ ខុស។ តែជាជាងគ្រាន់តែនិយាយ ត្រូវ ឬ ខុស អ្នកលេងនឹងឆ្លើយ ដោយចាប់ផ្តើមពីខាងស្តាំ សម្រាប់ចឆ្លើយ “ត្រូវ” ឬ ចាប់ផ្តើមពីខាងឆ្វេងសម្រាប់ចឆ្លើយ “មិនត្រូវ”។

៣. ឧទាហរណ៍ សំណួរមានដូចជា “ព្រះច័ន្ទរះឡើងនៅពេលថ្ងៃ!” (ចម្លើយគឺខុស ហើយអ្នកលេងត្រូវរត់ពីខាងឆ្វេង ឆ្ពោះទៅ “ជញ្ជាំងខាងឆ្វេង”)

៤. ភាពសប្បាយ៖ អ្នកលេង ២នាក់ចុងក្រោយដែលប៉ះនឹងជញ្ជាំងយឺតត្រូវចាកចេញពីការប្រកួត ឬ អង្គុយមើលគេ រហូតដល់ចាប់ផ្តើមលេងជាថ្មី។ បន្តលេងរហូតសល់តែអ្នកលេងចុងក្រោយ ៤នាក់ និងប្រកាសថា “អ្នកនោះជាអ្នកឈ្នះ”។

៥. ចំណុចសំខាន់៖ សូមសួរសំណួរវិលក ពីមេរៀនមុនៗ “ព្រះយេស៊ូវជាអ្នកគង្វាលល្អ ដែលគ្មានចៀមណាមួយបាត់បង់!” (បើឆ្លើយត្រឹមត្រូវ អ្នកលេងត្រូវរត់ខាងស្តាំពួកគេ ឆ្ពោះទៅ “ជញ្ជាំងខាងស្តាំ”)។

- សេចក្តីពិតផ្សារភ្ជាប់ជីវិត៖ ពេត្រុសមិនបាននិយាយត្រង់ទេ ពេត្រុសកុហកដើម្បីការពារខ្លួនគាត់ ហើយគាត់មានអារម្មណ៍សោកស្តាយ ក្រោយពេលគាត់បានកុហក។ ព្រះជាម្ចាស់សព្វព្រះទ័យឱ្យយើងនិយាយការពិត។ ព្រះយេស៊ូវជាផ្លូវ ជាសេចក្តីពិត និងជាជីវិត អ្នកជឿទាំងអស់ត្រូវប្តេជ្ញាចិត្តដើរតាមព្រះអង្គ និងស្តាប់បង្គាប់តាមសេចក្តីពិត។

សំណួរ

១. តាមការលេងនេះ មានចម្លើយតែពីរប៉ុណ្ណោះគ្រប់រាល់សំណួរទាំងអស់ ដែលចម្លើយនោះអាច “ត្រូវ” ឬក៏ “ខុស”។ តើអ្នករត់ទៅកាន់ទិសដៅណា ពេលចម្លើយនោះត្រឹមត្រូវ? (ខាងស្តាំ)

២. តាមរយៈព្រះគម្ពីរ តើលោកពេត្រុសបាននិយាយការពិត ឬ បាននិយាយកុហក? ហេតុអ្វីបានជាគាត់និយាយកុហក? ពេលអ្នកមានជម្រើសនិយាយការពិត ឬនិយាយកុហក តើអ្នកវើសយកមួយណា? (និយាយការពិត) ហេតុអ្វី? (ការកុហកធ្វើឱ្យយើងធ្វើខុស ដែលការនេះជាការមិនស្តាប់បង្គាប់ព្រះ)។

៣. ឱ ព្រះយេស៊ូវអើយ ទូលបង្គំចង់ដើរតាមទ្រង់ជាព្រះអម្ចាស់របស់ទូលបង្គំ។ សូមកែប្រែទូលបង្គំតាមផ្លូវដែលទ្រង់សព្វព្រះទ័យ។ សូមព្រះអង្គបង្ហាញទូលបង្គំ នូវផ្លូវដែលទូលបង្គំអាចដើរតាមទ្រង់បាន។ (ឈប់បន្តិច) ផ្លូវនោះនឹងមិនងាយស្រួលឡើយ ប៉ុន្តែ ទូលបង្គំទុកចិត្តថាទ្រង់នឹងបង្ហាញផ្លូវដល់ទូលបង្គំជាក់ជាមិនខាន។

©2018 The Prayer Covenant for Children/Games provided by GameLife77.com. All rights reserved.

ការប្តេជ្ញាចិត្ត

ក្រដាសកិច្ចការ

១ តើ អ្នកចងចាំនូវសេចក្តី អធិ ស្ថានបន្ទាត់ទី ៦ អំពី ការប្តេជ្ញាចិត្តទេ? សូមសរសេរចុះខាងក្រោម

២ បំពេញចន្លោះ

បើ អ្នកណា _____ ត្រូវឲ្យអ្នកនោះ _____ ទាំង_____

រាល់តែថ្ងៃ ហើ យ_____ ។

៣ ហេតុអ្វី ការដើ រតាមព្រះយេស៊ូវ ជាការប្តេជ្ញាចិត្ត?

៤ តើ អ្នកបានប្តេជ្ញាចិត្តលើ អ្វី ខ្លះ?

៥ ពេលឆ្លើ យតប៖

សូមបិ ទភ្នែក ហើ យទូលសួរ ទាំងស្តាប់ព្រះយេស៊ូវថា "តើ វានឹ ងទៅជាអ្វី បើ ខ្ញុំជាអ្នកដើ រតាមទ្រង់ដោយចិ ត្តឆេះឆួល និ ងប្តេជ្ញាចិ ត្ត?" តើ ទ្រង់នឹ ងធ្វើ អ្វី ? សូមគូសរូបភាពពី អ្វី ដែលព្រះយេស៊ូវបង្ហាញអ្នក បន្ទាប់មកចែកចាយរូបភាពនោះទៅ កាន់មិ ត្តរួមថ្នាក់ និ ងឪពុកម្តាយរបស់អ្នក។

ការប្តេជ្ញាចិត្ត

ការគោះឡើង!

អ្នកជួយលាងចានម្តាយអ្នកពេលមួយថ្ងៃ។

ការនោះល្អហើយ ល្អហើយ!

អ្នកចុះឈ្មោះក្នុងក្រុមកីឡាណាមួយ ហើយភ្លេចចូលរួមលេង។

ការនោះមិនល្អទេ មិនល្អទេ!

អ្នកជួយមិត្តភ័ក្តម្នាក់ ដែលមិនសូវពូកែក្នុងថ្នាក់រៀន។

ការនោះល្អហើយ ល្អហើយ!

អ្នកផ្អាកមេរៀនព្យាណូរបស់អ្នក ព្រោះអ្នកយល់ថា វាគ្មានប្រយោជន៍ ។

ការនោះមិនល្អទេ មិនល្អទេ!

អ្នករក្សារាល់ការសន្យារបស់អ្នកទាំងអស់។

ការនោះល្អហើយ ល្អហើយ!

ដូច្នេះ សូមរក្សាការប្តេជ្ញាចិត្តរបស់អ្នក និងចងចាំអធិស្ឋាន!

គ្រូបង្រៀនអានអក្សរនៅផ្នែកពណ៌ខ្មៅ ហើយកុមាររង្ហើយតប ដោយអានតាមតែនៅផ្នែកពណ៌ខៀវវិញ។ ក្រោយមក សូមលើកទឹកចិត្តពួកគេឱ្យសរសេរលើក្តាគោះរបស់ពួកគេតាមក្រុម ដោយសរសេរសំណួរពរពួកគេនៅលើក្តាខៀន។ សូមមើលចំណាប់អារម្មណ៍ ដែលពួកគេគោះនូវអ្វីដែលពួកគេបានសរសេរនោះចុះ!

ការពឹងផ្អែក

សូមបំពេញទូលបង្គំដោយព្រះវិញ្ញាណបរិសុទ្ធរបស់ទ្រង់។ ទូលបង្គំចង់ស្គាល់ផែនការទ្រង់ សម្រាប់ទូលបង្គំ។



អ្នកកំសាន្តចិត្ត យ៉ូហាន ១៤.១៥-៣១

អេភេសូ ៥: ១៨
សូមឲ្យបានពេញជាមួយព្រះវិញ្ញាណវិញ។

ការពឹងផ្អែក

តើ អ្នកអាចនិ យាយបានទេ?

សូមបំពេញទូលបង្គំដោយព្រះវិញ្ញាណបរិសុទ្ធរបស់ទ្រង់។ ទូលបង្គំចង់ស្គាល់ផែនការទ្រង់សម្រាប់ទូលបង្គំ។

អេភេសូ ៥: ១៨
សូមឲ្យបានពេញជាមួយព្រះវិញ្ញាណវិញ។

តើ អ្នកអាចស្វែងរកបានទេ?

កិច្ចការ ២.១-១៧

រ៉ូម ៨.២៦-២៧

រ៉ូម ១៥.១៣

កាឡាទី ២.២២-២៦

តើ អ្នកអាចដឹងបានទេ?

- សូមឲ្យបានពេញជាមួយព្រះវិញ្ញាណ មានន័យយ៉ាងម៉ិច?
- សូមឲ្យបានពឹងផ្អែកលើព្រះ មានន័យយ៉ាងម៉ិច?
- ស្តាប់លើសំលេងព្រះ មានន័យយ៉ាងម៉ិច?
- តើធ្វើដូចម្តេច ដើម្បីឲ្យបានពេញជាមួយព្រះវិញ្ញាណ?

ការពិ ងផ្អែក



"ការអធិ ស្ឋានពោតលើ ង"

សូមនាំកុមារចំណាយពេលអធិស្ឋានផ្ទាល់ៗខ្លួនម្តងទៀត ដោយការអធិស្ឋាន "សូមជួយឱ្យទូលបង្គំស្រឡាញ់ និងស្តាប់បង្គាប់ទ្រង់"។ សូមឱ្យកុមារថាតាមសេចក្តីអធិស្ឋាន។ សូមលើកទឹកចិត្តពួកគេឱ្យអធិស្ឋានតែសេចក្តីអធិស្ឋានត្រឹមតែមួយប្រយោគ ដោយទូលសូមព្រះទៅតាមពាក្យផ្ទាល់ខ្លួនរបស់ពួកគេ ដើម្បីសូមទ្រង់ជួយបង្រៀនពីសេចក្តីស្រឡាញ់ និងការស្តាប់បង្គាប់ទ្រង់។ ពួកគេអំពាវនាវតាមព្រះនាមផ្សេងៗរបស់ព្រះអង្គ ហើយនិងស្តាព្រះហស្តរបស់ទ្រង់ ដូចដែលបានចែកចាយក្នុងមេរៀនជាគំរូស្រាប់។

សូមពណ៌ នា!

- ព្រះចង់និយាយទៅកាន់អ្នក។ ពេលខ្លះ វាលំបាកស្តាប់លឺសំលេងទ្រង់។ ប៉ុន្តែ បើយើងនៅតែបន្តស្តាប់ នោះយើងនឹងអាចរៀនស្គាល់សំលេងទ្រង់បាន។
- យើងត្រូវតែពឹងផ្អែកទាំងស្រុងលើព្រះវិញ្ញាណបរិសុទ្ធរបស់ព្រះ។ យើងត្រូវតែទុកចិត្តលើអំណាចរបស់ព្រះ មិនមែនពឹងលើកំលាំងរបស់ខ្លួនឯងឡើយ។
- យើងត្រូវតែពឹងផ្អែកទាំងស្រុងលើព្រះវិញ្ញាណរបស់ទ្រង់ ដើម្បីឱ្យបានកាន់តែដូចព្រះយេស៊ូវ។
- ពេលអ្នកមានពេលជាមួយព្រះវិញ្ញាណ ព្រះយេស៊ូវនឹងប្រើអ្នកកាន់តែធំឡើងៗ។
- អ្នកនឹងកាន់តែមានសេចក្តីស្រឡាញ់ សេចក្តីអំណរ សេចក្តីសុខសាន្ត ភាពអត់ធ្មត់ និងផលផ្លែដទៃទៀតនៃព្រះវិញ្ញាណ។

សូមនាំកិច្ចពិភាក្សា ដោយនិយាយអំពី តើមានន័យអ្វី ដែលមានមិត្តម្នាក់ និងអ្នកជួយកំសាន្តចិត្តម្នាក់ ដែលអ្នកអាចពឹងពាក់ឱ្យជួយបង្ហាញផ្លូវអ្នកបានរាល់ថ្ងៃ។ តើទំនាក់ទំនងនោះ ដូចទៅនឹងអ្វីដែរ? សូមពិភាក្សាពីផលផ្លែផ្សេងៗនៃព្រះវិញ្ញាណ ហើយទុកឱ្យកុមារចែកចាយ ចំនុចមួយណាដែលពួកគេកំពុងព្យាយាមជំនះជាងគេ។

ការពឹងផ្អែក

តើ អ្នកអាចស្តាប់លឺ ទេ?

អ្នកជួយកំសាន្តចិត្ត (យ៉ូហាន ១៤.១៥-៣១)

ស្រមៃមើលពេលបន្តិច ដោយបិទភ្នែក និងស្រមៃទៅមិត្តម្នាក់ ដែលអ្នកស្រឡាញ់ខ្លាំង។ តើអ្នកឃើញមុខរបស់គេទេ? ឥឡូវ សូមស្រមៃថា មិត្តម្នាក់នោះនិយាយ “ខ្ញុំនឹងចាកចេញទៅថ្ងៃស្អែក ទៅកន្លែងឆ្ងាយ កន្លែងដែលអ្នកមិនអាចទៅដល់។ ប៉ុន្តែ សូមកុំចប់បារម្ភណ៍អី ខ្ញុំនឹងទុកព្រះវិញ្ញាណរបស់ខ្ញុំដែល នឹងនិយាយជាមួយអ្នក ហើយក៏ជួយដល់អ្នកផងដែរ។” ជាការពិតណាស់ ការនេះក្រៅពីព្រះ នោះនឹងមិនអាចកើតឡើងបានទេ។ ប៉ុន្តែ នេះជាអ្វីដែលបានកើតឡើង មុនពេលព្រះយេស៊ូវសុគតលើឈើឆ្កាង ហើយបានរស់ពីសុគតឡើងវិញ ដោយគង់នៅខាងស្តាំដៃនៃព្រះវរបិតាដែលគង់នៅស្ថានសួគ៌។

ព្រះអង្គមិនទុកយើងឲ្យនៅតែឯងឡើយ។ ព្រះយេស៊ូវបានមានព្រះបន្ទូលនៅក្នុងព្រះគម្ពីរ យ៉ូហាន ១៤.១៦-១៧ “នោះខ្ញុំនឹងទូលសូមដល់ព្រះវរបិតា ហើយទ្រង់នឹងប្រទានព្រះដ៏ជាជំនួយ១អង្គទៀត មកអ្នករាល់គ្នា ឲ្យបានគង់នៅជាមួយនៅអស់កល្បរៀងទៅ គឺជាព្រះវិញ្ញាណនៃសេចក្តីពិត។” ព្រះយេស៊ូវបានបញ្ជូនព្រះវិញ្ញាណរបស់ទ្រង់ មកជួយដល់ពួកជំនុំដើម្បីចាប់ផ្តើមធ្វើបេសកកម្ម។ ការនេះមិនឃ្លាតទេ ដោយគ្រាន់តែក្នុងពេលថ្ងៃពិសេសមួយ ដែលហៅថាថ្ងៃបុណ្យទី៥០ ពេលនោះមានខ្យល់បោកបក់ខ្លាំង ហើយគ្រប់គ្នាក៏បានពេញជាព្រះវិញ្ញាណបរិសុទ្ធ។ ព្រះវិញ្ញាណរបស់ព្រះអង្គគង់នៅជាមួយពួកគាត់ ដូចជាអ្នកជួយកំសាន្តចិត្ត ជាគ្រូបង្រៀន និងជាអ្នកដឹកនាំផ្លូវ។ ហើយព្រះវិញ្ញាណដដែល ក៏សង់នៅក្នុងអស់អ្នកណាដែលជាកូនរបស់ព្រះអង្គ ដូចជាអ្នក និងខ្ញុំផងដែរ។ ទ្រង់ចង់ដឹកនាំយើងដោយព្រះវិញ្ញាណរបស់ទ្រង់។ តើអ្នកកំពុងស្តាប់ព្រះវិញ្ញាណបរិសុទ្ធមែនទេ?

តើ អ្នកអាចធ្វើ វាបានទេ?

- សូមក្លាយជាអ្នកពឹងផ្អែកលើព្រះវិញ្ញាណរបស់ព្រះ ដើម្បីដឹកនាំ កំសាន្តចិត្ត និងបង្រៀនដល់អ្នក។
- សូមទូលសុំព្រះវរបិតាដែលគង់នៅស្ថានសួគ៌ ឲ្យបំពេញអ្នកដោយព្រះវិញ្ញាណបរិសុទ្ធរបស់ទ្រង់រាល់ថ្ងៃ។
- តើខ្ញុំអាចញែកពេលខ្លះ ស្តាប់សំលេងព្រះបានទេ? “សូមឲ្យទ្រង់ ហាយ ហ្វាយ” នោះមានន័យថា អ្នកនៅស្ងៀមស្ងាត់រយៈពេល ៥នាទី ជាមួយនឹងព្រះដ៏ខ្ពស់បំផុត។ ការស្តាប់អាចសំខាន់ជាងការនិយាយ។ តើព្រះអាចមានបន្ទូលមកកាន់អ្នកដោយរបៀបណា? សូមអាន ទំនុកដំកើង ៤៦.១០ ទាំងអស់គ្នា។

ការពឹងផ្អែក

សូមសាកល្បង!

ស៊ីម៉ូន ស៊ីស (Simon Sez)

១. សូមចាប់ផ្តើមពន្យល់ដល់អ្នកលេងថា ពួកគេត្រូវស្តាប់ដោយយកចិត្តទុកដាក់ ក្នុងការលេងល្បែងកំសាន្តនេះ។

២. អ្នកដឹកនាំលេងមានឈ្មោះថា “ស៊ីម៉ូន”។ ស៊ីម៉ូនស្នើអ្នកលេងឲ្យធ្វើតាមគាត់ ដូចជា “សូមប៉ះច្រមុះជើងរបស់អ្នក”។ កុមារត្រូវប៉ះច្រមុះជើងរបស់គេ តាមអ្វីដែល ស៊ីម៉ូន បានប្រាប់។

៣. កុមារនិងចាញ់ បើគេធ្វើខុសពីអ្វីដែល ស៊ីម៉ូន បានប្រាប់។

៤. ដំបូង ស៊ីម៉ូន នឹងនាំអ្នកលេងធ្វើតាម អ្វីៗដែលងាយៗសម្រាប់ពួកគេធ្វើតាម ដូចជា ប៉ះត្រចៀក លោត៥ដង ជាដើម។ សូមអង្គុយចុះ ក្រោកឈរឡើង...។ ពេលល្បែងនេះកំពុងលេង ស៊ីម៉ូន ស្នើឲ្យមានការប្រកួតប្រជែងខ្លះៗ ដូចជា “ស៊ីម៉ូន ស៊ីស ប៉ះច្រមុះជើង មិនមែនច្រមុះទេ” “ស៊ីម៉ូន ស៊ីស ប៉ះច្រមុះព្រមទាំងច្រមាមជើង” ឬ “សូមប៉ះត្រចៀក” (ដោយមិនបាននិយាយថា “ស៊ីម៉ូន ស៊ីស”)។

៥. បន្តលេងរហូតនៅសល់តែអ្នកលេង ៤នាក់ប៉ុណ្ណោះ ដែលនឹងត្រូវប្រកាស ថាជាអ្នកឈ្នះពូកែទាំងស្តាប់ និងពូកែទាំងធ្វើតាម។

៦. ចំណុចសំខាន់៖ សូមលេងម្តងទៀត តែពេលនេះ ស៊ីម៉ូន ត្រូវខ្សឹបប្រាប់វិញ។

៧. រួចបន្តលេងរហូតនៅសល់តែអ្នកលេង ៤នាក់ប៉ុណ្ណោះ ដែលនឹងត្រូវប្រកាស ថាជាអ្នកឈ្នះពូកែទាំងស្តាប់ និងពូកែទាំងធ្វើតាម។

- សេចក្តីពិតភ្ជាប់នឹងជីវិត៖ ព្រះតែងតែនិយាយមកយើងតាមរយៈព្រះវិញ្ញាណបរិសុទ្ធ។ យើងត្រូវតែពឹងផ្អែក និងទុកចិត្តលើទ្រង់ ដោយទ្រង់នឹងជួយកំសាន្តចិត្ត បង្រៀន និងដឹកនាំផ្លូវយើងរាល់គ្នា។ យើងត្រូវចំណាយពេលស្តាប់ព្រះអង្គមានបន្ទូល មកកាន់ចិត្តរបស់យើង។

សំណួរ

១. ដើម្បីស្តាប់បង្គាប់តាម “ស៊ីម៉ូន” ភ្លាមៗ តើអ្នកត្រូវធ្វើអ្វី? (ស្តាប់យ៉ាងយកចិត្តទុកដាក់ ផ្តោតអារម្មណ៍ និងស្តាប់បង្គាប់ភ្លាមៗ ពេលដែល ស៊ីម៉ូនបង្គាប់) ចុះ ពេលស៊ីម៉ូនខ្សឹបវិញ តើអ្នកត្រូវធ្វើអ្វី?

២. យើងត្រូវតែស្តាប់ព្រះវិញ្ញាណបរិសុទ្ធរបស់ព្រះ ដែលជាអ្នកកំសាន្តចិត្តយើង ជាគ្រូបង្រៀន និងជាអ្នកដឹកនាំផ្លូវរបស់យើង។ តើយើងអាចស្តាប់លឺសំលេងរបស់ព្រះបាន យ៉ាងដូចម្តេច? តើយើងត្រូវធ្វើអ្វី? (ស្តាប់យ៉ាងយកចិត្តទុកដាក់ ផ្តោតអារម្មណ៍ និងស្តាប់បង្គាប់ភ្លាមៗ ពេលដែល ព្រះអង្គបង្គាប់) តើការពឹងផ្អែក ការទុកចិត្ត លើព្រះវិញ្ញាណបរិសុទ្ធ ដើម្បីដឹកនាំអ្នក មានន័យអ្វី?

៣. ព្រះអង្គអើយ សូមបំពេញទូលបង្គំដោយព្រះវិញ្ញាណបរិសុទ្ធរបស់ទ្រង់ សូមជួយទូលបង្គំឲ្យស្តាប់សំឡេងទ្រង់ដោយយកចិត្តទុកដាក់ រាល់ពេលទ្រង់មានព្រះបន្ទូលមកកាន់ទូលបង្គំ។ សូមជួយឲ្យទូលបង្គំស្តាប់សំលេងទ្រង់ដោយយកចិត្តទុកដាក់ ពេលទ្រង់មានព្រះបន្ទូលមកកាន់ទូលបង្គំ។ ឥឡូវនេះ សូមព្រះវិញ្ញាណបរិសុទ្ធនិយាយមកកាន់ចិត្តទូលបង្គំ ហើយបង្ហាញទូលបង្គំផ្លូវមួយ ដែលទូលបង្គំអាចដើរតាមទ្រង់កាន់តែជិតស្និទ្ធបន្ថែមទៀត។ (ឈប់បន្តិច) ឱ ព្រះវិញ្ញាណបរិសុទ្ធអើយ ទូលបង្គំអរព្រះគុណទ្រង់ ដែលទ្រង់ត្រឡប់ជាគ្រូបង្រៀន និងជាអ្នកដឹកនាំផ្លូវរបស់ទូលបង្គំ។

©2018 The Prayer Covenant for Children/Games provided by GameLife77.com. All rights reserved.

ការពឹងផ្អែក

ក្រដាសកិច្ចការ

១ ទោះបីជាវាលំបាកក្តី ប៉ុន្តែ អ្នកអាចធ្វើវាបាន! តើអ្នកចងចាំសេចក្តីអធិស្ឋានបន្ទាត់ទី ៧ អំពី ការពឹងផ្អែក? សូមសរសេរវាចុះខាងក្រោម៖

២ ចូរបំពេញចន្លោះ

អេភេសូរ ៥.១៨ "សូម _____ ជា _____ ។

៣ សូមសរសេរឈ្មោះផលផ្លែនៃព្រះវិញ្ញាណបរិសុទ្ធខាងក្រោម៖

_____ _____ _____

_____ _____ _____

_____ _____ _____

៤ តើផលផ្លែណាមួយដែលពិបាកបំផុត សម្រាប់អ្នក?
តើការលំបាកនោះ សេចក្តីអធិស្ឋានអាចជួយអ្នកបានយ៉ាងដូចម្តេច?

៥ ពេលឆ្លើយតប៖
សូមឲ្យព្រះនូវ ហាយហ្វាយ (High Five)! សូមបិទភ្នែករបស់អ្នក និងស្តាប់សំលេង
ដែលព្រះទ្រង់នឹងមានបន្ទូលមកកាន់អ្នក។ តើព្រះអង្គបានរំលឹកអ្នកពីខគម្ពីរណាមួយទេ?
តើទ្រង់បានឲ្យអ្នកគំនិតណាមួយ ដែរឬទេ? តើទ្រង់បានរំលឹកអ្នក តាមមនុស្សជាក់លាក់ណាម្នាក់ទេ?
សូមគូស ឬ សរសេរចុះលើ ក្រដារបស់អ្នក នូវអ្វីដែលអ្នកយល់ថា ព្រះនឹងមានបន្ទូលមកកាន់អ្នក។

ការពិ ងផ្អែក

ការគោះឡើ ង!

ខាទី បានសម្រេចចិ ត្តនាំមិ ត្តរបស់គាត់ទៅព្រះវិ ហារ។

ដោយព្រះវិ ញ្ញាណ? ត្រូ វហើ យ ត្រូ វហើ យ

ជូ មិ នបានសិ ក្សា និ ងលួចចម្លងពេលប្រឡង។

ដោយព្រះវិ ញ្ញាណ? មិ នត្រូ វទេ មិ នត្រូ វទេ

ស៊ូ ស៊ី បានចែកចាយទី បន្ទាល់របស់គាត់ជាមួយនឹ ងមិ នរួមថ្នាក់ទាំ ងអស់របស់គាត់។

ដោយព្រះវិ ញ្ញាណ? ត្រូ វហើ យ ត្រូ វហើ យ

ប្រេន បានអធិ ស្ឋានឲ្យបាលជំងឺ ដល់ម្តាយគាត់ ដែលម្តាយគាត់ឈឺ ធ្ងន់ធ្ងរ។

ដោយព្រះវិ ញ្ញាណ? ត្រូ វហើ យ ត្រូ វហើ យ

ពេត្រុសបានយករបស់ខ្លះៗដែលមិ នមែនជាកម្មសិ ទ្ធិ របស់គាត់។

ដោយព្រះវិ ញ្ញាណ? មិ នត្រូ វទេ មិ នត្រូ វទេ

ចេស៊ី បានអធិ ស្ឋាន សម្រាប់កូនបេសកជនម្នាក់។

ដោយព្រះវិ ញ្ញាណ និ ងនោះជាការគោះ!

គ្រូបង្រៀនអានអក្សរនៅផ្នែកពណ៌ខ្មៅ ហើយកុមារឆ្លើយតប ដោយអានតាមតែនៅផ្នែកពណ៌ខៀវវិញ។ ក្រោយមក សូមលើកទឹកចិត្តពួកគេឲ្យសរសេរលើក្តាគោះរបស់ពួកគេតាមក្រុម ដោយសរសេរសំណួរពីរពួកគេនៅលើក្តាខៀន។ សូមមើលចំណាប់អារម្មណ៍ ដែលពួកគេគោះឆ្លើយអ្វីដែលពួកគេបានសរសេរនោះចុះ!

គំនិត ៣ល

សូមធ្វើឲ្យទូលបង្គំក្លាយជាអ្នកនាំសារនៃព្រះគុណ
សេចក្តីពិត និងសេចក្តីយុត្តិធម៌របស់ទ្រង់។

ព្រះយេស៊ូវ និងកុមារ ម៉ាថាយ ១៨.១-៦

យ៉ូហាន ១.១៤

យើងរាល់គ្នាបានឃើញសិរីល្អទ្រង់ គឺជាសិរីល្អនៃព្រះរាជបុត្រាតែ១
ដែលមកពីព្រះវរបិតា មានពេញជាព្រះគុណ និងសេចក្ដីពិត។

ឥទ្ធិ ពល

តើ អ្នកអាចនិ យាយបានទេ?

សូមធ្វើឱ្យទូលបង្គំក្លាយជាអ្នកនាំសារនៃព្រះគុណ សេចក្តីពិត និងសេចក្តីយុត្តិធម៌របស់ទ្រង់។

យ៉ូហាន ១.១៤
យើងរាល់គ្នាបានឃើញសិរីល្អទ្រង់ គឺជាសិរីល្អនៃព្រះរាជបុត្រាតែ១ ដែលមកពីព្រះវរបិតា មានពេញជាព្រះគុណ និងសេចក្តីពិត។

តើ អ្នកអាចស្វែងរកបានទេ?

ម៉ាថាយ ១៩.១៣-១៥
កិច្ចការ ២.១៦-១៧
លូកា ១៨.១៥-១៧

តើ អ្នកអាចដឹងបានទេ?

- តើអំណោយទានអ្វីខ្លះដែលព្រះឱ្យមកអ្នក?
- តើខ្ញុំអាចបង្ហាញព្រះគុណរបស់ព្រះដល់អ្នកជំនៃបានយ៉ាងដូចម្តេច?
- តើអ្វីដែលជាភាពខុសគ្នារវាងសេចក្តីពិតនិងការកុហក?
- តើមានបញ្ហាអ្វីជាមួយនឹងការកុហក?

តន្ត្រី ពល



"ការអធិ ស្ឋានពេតលី ង"

សូមនាំកុមារចំណាយពេលអធិស្ឋានផ្ទាល់ៗខ្លួនម្តងទៀត ដោយការអធិស្ឋាន "សូមជួយឱ្យទូលបង្គំស្រឡាញ់ និងស្តាប់បង្គាប់ទ្រង់"។ សូមឱ្យកុមារថាតាមសេចក្តីអធិស្ឋាន។ សូមលើកទឹកចិត្តពួកគេឱ្យអធិស្ឋានតែសេចក្តីអធិស្ឋានត្រឹមតែមួយប្រយោគ ដោយទូលសុំព្រះទៅតាមពាក្យផ្ទាល់ខ្លួនរបស់ពួកគេ ដើម្បីសុំទ្រង់ជួយបង្រៀនពីសេចក្តីស្រឡាញ់ និងការស្តាប់បង្គាប់ទ្រង់។ ពួកគេអំពាវនាវតាមព្រះនាមផ្សេងៗរបស់ព្រះអង្គ ហើយនិងស្តាព្រះហស្តរបស់ទ្រង់ ដូចដែលបានចែកចាយក្នុងមេរៀនជាគំរូស្រាប់។

សូមពណ៌ នា!

- ព្រះយេស៊ូវផ្តល់នូវយុត្តិធម៌រាល់ថ្ងៃ ពេលទ្រង់ព្យាបាលអ្នកជំងឺ និងជួយដល់អ្នកក្រីក្រ។
- ព្រះអង្គមិនយកចិត្តទុកដាក់ថាអ្នក ចាស់ ឬ ក្មេង មាន ឬ ក្រ នោះទេ។
- ព្រះអង្គយកចិត្តទុកដាក់មនុស្សគ្រប់គ្នាដោយស្មើភាពគ្នា។
- ព្រះអង្គផ្តល់ក្តីស្រឡាញ់ និងព្រះគុណដល់មនុស្សគ្រប់គ្នា។
- ព្រះអង្គតែងតែមានព្រះបន្ទូលដោយសេចក្តីពិត។

សូមឱ្យកុមារចែកចាយវិធីផ្សេងៗ ដែលពួកគេអាចក្លាយជាភ្នាក់ងារ សម្រាប់ភាពយុត្តិធម៌។ សូមពិភាក្សា ពេលដែលការនោះលំបាក ដើម្បីប្រាប់សេចក្តីពិត។ តើហេតុដូចម្តេចមិនឱ្យអ្នកនិយាយដោយពិតត្រង់បាន ដោយលាក់ព្រះបន្ទូលរបស់ព្រះទុកតែក្នុងចិត្តអ្នក?

ឥទ្ធិពល

តើ អ្នកអាចស្តាប់លឺ ទេ?

ព្រះយេស៊ូវ និងកុមារ (ម៉ាថាយ ១៨.១-៦)

ថ្ងៃមួយ ពួកសិស្សបានកំពុងអង្គុយជជែកនិយាយនឹងព្រះយេស៊ូវ។ ពួកគាត់ហាក់ដូចជាយើងរាល់គ្នាដែរ ដែលពេលខ្លះព្រួយបារម្ភណ៍ អំពីនរណាដែលទទួលបានការយកចិត្តទុកដាក់យ៉ាងល្អនៅផ្ទះ នៅសាលារៀន ឬ នៅកន្លែងលេងកំសាន្ត ដែលពួកសិស្សក៏ខ្វល់ខ្វាយស្រដៀងនឹងយើងដែរ។ ពួកគាត់សួរព្រះយេស៊ូវ “អឺ អឺ... ដូច្នេះ” ពួកគាត់រអេះក្បាល ដោយសួរព្រះអង្គថា “តើនរណាធំជាងគេក្នុងនគរស្ថានសួគ៌?” តាមខ្ញុំស្មានគឺថា ពួកគាត់រំពឹងថា ព្រះយេស៊ូវនឹងចង្អុលនរណាម្នាក់ក្នុងចំណោមពួកគាត់ជាក់ជាមិនខាន។

ព្រះយេស៊ូវជ្រាបពីអ្វីដែលពួកគេកំពុងគិត រួចទ្រង់ហៅក្មេងម្នាក់មកជិតទ្រង់។ ព្រះអង្គមានបន្ទូលថា “សូមឈរក្បែរខ្ញុំ” បន្ទាប់មកព្រះអង្គបានមើលទៅកាន់ពួកសិស្ស ហើយមានបន្ទូលដោយសេចក្តីអស្ចារ្យថា “ដូច្នេះ អ្នកណាដែលបន្ទាបខ្លួន ឱ្យបានដូចកូនតូចនេះ អ្នកនោះឯងឈ្មោះថា ធំជាងគេក្នុងនគរស្ថានសួគ៌ហើយ។” ព្រះអង្គមានព្រះបន្ទូលអស្ចារ្យបន្ថែមទៀតថា “អ្នកណាដែលទទួលកូនតូចណាមួយដូចកូននេះ ដោយនូវឈ្មោះខ្ញុំ នោះក៏ឈ្មោះថាទទួលខ្ញុំដែរ។” ការនោះពិតជាអស្ចារ្យខ្លាំងណាស់ អ្នកដឹងទេ ពេលព្រះយេស៊ូវបានមានបន្ទូល ព្រះអង្គក៏មានចង់សំដៅដូចនោះមែនទេ។ អោះព្រះអង្គតែងតែមានបន្ទូលពិតត្រង់។

ព្រះយេស៊ូវមានដួងចិត្តសម្រាប់យុត្តិធម៌។ ព្រះអង្គយកចិត្តទុកដាក់អ្នកក្រីក្រ។ ព្រះអង្គបង្ហាញសេចក្តីអាណិតអាសូរដល់អ្នកមានជំងឺ។ ព្រះអង្គបាននាំសេចក្តីសុខសាន្ត ដល់អស់អ្នកដែលរងគ្រោះផ្លូវចិត្ត។ ព្រះអង្គក៏តែងតែសព្វព្រះទ័យចំណាយពេលជាមួយនឹងកុមារ ដែលជានិច្চាកាលពួកគេតែងតែមើលរំលង។ ព្រះយេស៊ូវមានបន្ទូលថា “កុំឱ្យមើលងាយចំពោះកូនតូចណាមួយនោះឡើយ។” តើអ្នកអាចយល់បានទេ ថាតើព្រះអង្គស្រឡាញ់ និងយកចិត្តទុកដាក់អ្នកខ្លាំងប៉ុណ្ណា?

តើ អ្នកអាចធ្វើ វាបានទេ?

- សូមអនុញ្ញាតឱ្យព្រះប្រើអ្នក ជាអ្នកនាំសារនៃព្រះគុណ សេចក្តីពិត និងសេចក្តីយុត្តិធម៌។
- សូមសម្រេចចិត្តចេញពីចិត្តអ្នក ដើម្បីនិយាយតែសេចក្តីពិតប៉ុណ្ណោះ។
- សូមចងចាំព្រះបន្ទូលរបស់ព្រះ។

ឥទ្ធិ ពល

សូមសាកល្បង!

កាយវិការដោយដៃពីការពិន័យ និងដំណឹងល្អ

១. អ្នកលេងទាំងអស់ត្រូវឈរជាជួរក្នុងបន្ទប់នៅផ្នែក ឬក៏កន្លែងណាមួយ។សូមចង្អុលទៅកាន់ចំណុចមួយដែលនៅឆ្ងាយ។ សូមពន្យល់អ្នកលេងឲ្យរត់ពីទីនេះ (ចំណុចចាប់ផ្តើម) ទៅកាន់ទីនោះ (ចំណុចដែលនៅឆ្ងាយ) រួចហើយត្រឡប់មកវិញ។

២. ចំណុចសំខាន់៖ សូមកំណត់ម៉ោង ដែលអ្នកលេងនោះត្រូវត្រឡប់មកចំណុចចាប់ផ្តើមវិញ។ សូមប្រាប់អ្នកលេងដោយត្រូវរត់ម្តងទៀត ប៉ុន្តែ ពេលនេះអ្នកលេងត្រូវរត់មកដល់ចំណុចចាប់ផ្តើមវិញ ត្រឹមតែពាក់កណ្តាលនៃពេលដែលពួកគេរត់លើកទី១។ បើពួកគេមិនអាចមកដល់ទីត្រឹមពេលពាក់កណ្តាលនោះទេ ពួកគេត្រូវពិន័យ ឬ ឲ្យអារ៉ាំង់ដី (pushups) ១០ដង។ សូមចំណាំថា អ្នកលេងទាំងអស់នឹងមិនអាចរត់មកដល់ទីទាន់ពេលឡើយ ព្រោះល្បែងកំសាន្តនេះតម្រូវឲ្យអ្នកលេងត្រូវចាញ់។

៣. សូមអនុញ្ញាតឲ្យអ្នកលេងទាំងអស់ព្យាយាមម្តងទៀត ហើយអនុញ្ញាតឲ្យតែកុមាររត់ប៉ុណ្ណោះ។

៤. ក្រោយអ្នកលេងព្យាយាមជាច្រើនដងហើយ ក្រោយមកសូមពន្យល់ថាពួកគេនឹងមិនអាចរត់ដល់ទីទាន់ពេលឡើយ ដោយពួកគេមានពេលខ្លី ហើយត្រូវតែទទួលរងពិន័យ។

៥. ក្រោយពេលដែលអ្នកលេងត្រូវពិន័យដោយអារ៉ាំង់ដីរួចហើយ សូមឲ្យអ្នកបង្រៀនលេងរត់មក ហើយនិយាយទៅកាន់អ្នកបង្រៀនលេងម្នាក់ទៀតថា “អ្នកមិនត្រូវឲ្យកុមាររងពិន័យឡើយ អ្នកមើលឃើញថាពួកគេប្រឹងប្រែងយ៉ាងណាទេ!” រួចត្រូវឆ្លើយតបថា ប៉ុន្តែ យើងទាំងអស់គ្នាព្រមព្រៀងរួចហើយថាពួកគេនឹងត្រូវរងពិន័យ។ ចូរឲ្យអ្នកបង្រៀនលេងដទៃទៀតនិយាយថា “ចាំបន្តិច ខ្ញុំនឹងសងថ្លៃការពិន័យនោះវិញ” (ធ្វើតាមការព្រមព្រៀងគ្នាពីមុន ដោយឲ្យអ្នកបង្រៀនលេងដទៃធ្វើអារ៉ាំង់ ១០ដង)។

- **សេចក្តី ពិ តភ្ជាប់នឹ ងជី វិ ត៖ ព្រះសព្វព្រះទ័ យប្រើ កុមារមានឥទ្ធិ ពលដល់ក្រុមគ្រួ សារ និ ងមិ ត្តភ័ ក្តិ របស់ពួកគេ។**

សំណួរ

១. ក្មេងប្រុសៗ ក្មេងស្រីៗ តើដៃរបស់អ្នកព្យាយាមការពារពីការពិន័យដោយធ្វើអារ៉ាំង មែនទេ? (មិនមែនទេ អ្នកបង្រៀនលេងបានសងការពិន័យរបស់យើង ហើយបានធ្វើអារ៉ាំង់ជំនួសវិញ) ពិតជាអស្ចារ្យណាស់! ហេតុអ្វីបានជាអ្នកបង្រៀនលេងត្រូវសងការពិន័យរបស់អ្នក?

២. តាមរយៈព្រះគម្ពីរដោយសារតែអំពើបាបរបស់យើង គ្រប់ការទាំងអស់មិននាំឲ្យព្រះសព្វព្រះទ័យនោះទេ ដោយយើងត្រូវទទួលការពិន័យនោះ (សេចក្តីស្លាប់)។ តើនរណាដែលសងការពិន័យរបស់អ្នក? (ព្រះយេស៊ូវ) ហេតុអ្វីព្រះយេស៊ូវសងការពិន័យរបស់អ្នក?

៣. ឱ ព្រះយេស៊ូវគ្រីស្ទអើយ ទូលបង្គំអរព្រះគុណទ្រង់សម្រាប់សេចក្តីស្រឡាញ់ដល់ទូលបង្គំជាខ្លាំង ដោយទ្រង់បានសុគតជំនួសទូលបង្គំ ដើម្បីសងការពិន័យរបស់ទូលបង្គំ។ ក្មេងប្រុសៗ ក្មេងស្រីៗ ចូរស្ងៀមស្ងាត់មួយភ្លែត ដោយសញ្ជឹងគិតថា ព្រះយេស៊ូវស្រឡាញ់អ្នកខ្លាំងយ៉ាងណា។ (ឈប់បន្តិច) ឱ ព្រះយេស៊ូវអើយ សូមអត់ទោសគ្រប់រាល់អំពើបាបទូលបង្គំ។ ទូលបង្គំចង់កែប្រែ និងត្រឡប់ចេញពីអំពើបាបទាំងនោះ។ សូមព្រះយេស៊ូវធ្វើជាព្រះអង្គសង្គ្រោះរបស់ទូលបង្គំ។ សូមព្រះយេស៊ូវបង្រៀនរបៀបដែលជីវិតទូលបង្គំអាចបង្ហាញព្រះគុណ សេចក្តីពិត និងសេចក្តីយុត្តិធម៌បាន? (ឈប់បន្តិច) សូមព្រះយេស៊ូវអើយ ទូលបង្គំអរព្រះគុណទ្រង់ សម្រាប់ការកែទូលបង្គំត្រឡប់ជាកូនទ្រង់ម្នាក់ដែរ។ សូមព្រះវិញ្ញាណបរិសុទ្ធបំភ្លឺផ្លូវទូលបង្គំជារៀងរាល់ថ្ងៃ!

©2018 The Prayer Covenant for Children/Games provided by GameLife77.com. All rights reserved.

ឥទ្ធិ ពល

ក្រដាសកិ ច្ចការ

❶ តើ អ្នកអាចចាំជួរទី ១ នៃសេចក្តី អធិ ស្ឋាន និ ងសសេរចុះដូចខាងក្រោមនេះទេ?

❷ បំពេញចន្លោះ

យ៉ូហាន ១.១៤ "យើ ងរាល់គ្នាបានឃើ ញ _____ គឺ ជា _____ នៃ _____

ដែលមកពី _____ មានពេញជា _____ និ ង _____ ។

❸ តើ អ្នកដែលទទួលស្វាគមន៍ អ្នកថ្មី ណាម្នាក់ មកសាលារៀនអ្នក ព្រះវិ ហារអ្នក ដែរឬទេ? បើ មាន
សូមចែកចាយពេលណា ដែលអ្នកស្វាគមន៍ ម្នាក់នោះ។ បើ សិ នមិ នទាន់ទេ
តើ អ្នកអាចសាកល្បងទទួលស្វាគមន៍ គេបានទេ? បើ អ្នកធ្វើ កាន់តែច្រើ ន នោះវានឹ ងកាន់តែងាយស្រួ ល!

❹ តើ អ្នកធ្លាប់មានឥទ្ធិ ពល ឬ ធ្លាប់បញ្ចុះបញ្ចូលនរណាម្នាក់ ដោយឲ្យគេធ្វើ ការដ៏ ត្រឹ មត្រូ វ ក្នុងពេលស្ថានភាពលំបាក
ដែរឬទេ? បើ មាន សូមចែកចាយរបៀបដែលមនុស្សម្នាក់នោះឆ្លើ យតប ទៅនឹ ងជំនួយរបស់អ្នក។

❺ ពេលឆ្លើ យតប៖

សូមទូលសួរព្រះ ព្រមទាំងស្តាប់សំលេង ដូចដែលអ្នកឆ្លើ យតាមសំណួរទាំងនេះ។ តើ អ្នកអាចគិ តបានទេ
នូវវិ ធី ដែលព្រះអាចប្រើ អ្នក ដើ ម្បី ឈោងចាប់មនុស្សជាច្រើ ននៅជុំវិ ញអ្នក? ប្រហែលជា
ចាប់ផ្តើ មនៅជាមួយក្រុមអធិ ស្ឋាន នៅព្រះវិ ហារ? ប្រហែល អញ្ជើ ញមិ ត្តភ័ ក្តិ ខ្លះទៅព្រះវិ ហារ
ដែលគេមិ នសូវបានទៅ? ទទួលស្វាគមន៍ អ្នកជិ តខាង ឬ ក្មេងណាដែលមកជាលើ កតំបូង ក្នុងថ្នាក់រៀនអ្នក?

ឥទ្ធិ ពល

ការគោះឡើង!

ខ្ញុំចង់ក្លាយជាភ្នាក់ងារនៃសេចក្តី ពិ ត!
ខ្ញុំនឹ ងធ្វើ ខ្ញុំនឹ ងធ្វើ !

ខ្ញុំចង់ថ្លែងពី ព្រះបន្ទូលនៃព្រះគុណរបស់ទ្រង់!
ខ្ញុំនឹ ងធ្វើ ខ្ញុំនឹ ងធ្វើ !

ខ្ញុំចង់បង្ហាញភាពយុត្តិ ធម៌របស់ព្រះអង្គ តាមជី វិ តរបស់ខ្ញុំរាល់ថ្ងៃ!
ខ្ញុំនឹ ងធ្វើ ខ្ញុំនឹ ងធ្វើ !

ខ្ញុំចង់ជួយអស់អ្នកដែលបាត់បង់ និ ងអ្នកបានវង្វេង។
ខ្ញុំនឹ ងធ្វើ ខ្ញុំនឹ ងធ្វើ !

ខ្ញុំចង់ជួយអស់អ្នកដែលត្រូ វការជំនួយ!
ខ្ញុំនឹ ងធ្វើ ខ្ញុំនឹ ងធ្វើ !

ខ្ញុំចង់ជួយអស់អ្នកដែលអ្នកដទៃមើ លរំលង!
ខ្ញុំនឹ ងធ្វើ ខ្ញុំនឹ ងធ្វើ !

ខ្ញុំចង់ក្លាយជាភ្នាក់ងារនៃសេចក្តី ស្រឡាញ់របស់ទ្រង!

គ្រូបង្រៀនអានអក្សរនៅផ្នែកពណ៌ខ្មៅ ហើយកុមារឆ្លើយតប ដោយអានតាមតែនៅផ្នែកពណ៌ខៀវវិញ។ ក្រោយមក សូមលើកទឹកចិត្តពួកគេឱ្យសរសេរលើក្តាគោះរបស់ពួកគេតាមក្រុម ដោយសរសេរសំណួរពរពួកគេនៅលើក្តាខៀន។ សូមមើលចំណាប់អារម្មណ៍ដែលពួកគេគោះនូវអ្វីដែលពួកគេបានសរសេរនោះចុះ!

ភាពជាសិស្ស

សូមកែទូលបង្គំ សម្រាប់សិរីល្អរបស់ទ្រង់
ព្រមទាំងនាំអ្នកដទៃដើរតាមទ្រង់។

សុល ពីតើស៊ីស ក្លាយជាប៉ុល ជាសាវ័ករបស់ព្រះយេស៊ូវគ្រីស្ទ កិច្ចការ ៩.១-២២

ម៉ាថាយ ២៨.១៩

ម៉ាថាយ ២៨.១៩ "ដូច្នេះ ចូរទៅបញ្ចុះបញ្ចូលឲ្យមានសិស្សនៅគ្រប់ទាំងសាសន៍ ព្រមទាំងធ្វើបុណ្យជ្រមុជទឹកឲ្យ ដោយនូវព្រះនាមព្រះវរបិតា ព្រះរាជបុត្រា និងព្រះវិញ្ញាណបរិសុទ្ធចុះ"។

ភាពជាសិស្ស

តើ អ្នកអាចនិយាយបានទេ?

សូមកែទូលបង្គំ សម្រាប់ឆន្ទៈល្អរបស់ទ្រង់ ព្រមទាំងនាំអ្នកដទៃដើរតាមទ្រង់។

ម៉ាថាយ ២៨.១៩

ម៉ាថាយ ២៨.១៩ “ដូច្នេះ ចូរទៅបញ្ចុះបញ្ចូ លឲ្យមានសិស្សនៅគ្រប់ទាំងសាសន៍ ព្រមទាំងធ្វើបុណ្យជ្រមុជទឹកឲ្យ ដោយនូវព្រះនាមព្រះវរបិតា ព្រះរាជបុត្រា និងព្រះវិញ្ញាណបរិសុទ្ធចុះ”។

តើ អ្នកអាចស្វែងរកបានទេ?

ម៉ាកុស ១៦.១៥

យ៉ូហាន ១៧.៤-៥

រ៉ូម ១០.១៣-១៧

កូឡុស ៣.១៧

តើ អ្នកអាចដឹងបានទេ?

- តើបេសកជនជាអ្វី?
- តើសិស្សជាអ្វី?
- តើមានវិធីណាខ្លះដែលយើងអាចប្រាប់គេអំពីព្រះយេស៊ូវ?
- តើមានន័យអ្វីដែលធ្វើអ្វីមួយសម្រាប់សិរីល្អនៃព្រះ?

ភាពជាសិស្ស

"ការអធិស្ឋានពេតលេង"

សូមនាំកុមារចំណាយពេលអធិស្ឋានផ្ទាល់ៗខ្លួនម្តងទៀត ដោយការអធិស្ឋាន "សូមជួយឲ្យទូលបង្គំស្រឡាញ់ និងស្តាប់បង្គាប់ទ្រង់"។ សូមឲ្យកុមារថាតាមសេចក្តីអធិស្ឋាន។ សូមលើកទឹកចិត្តពួកគេឲ្យអធិស្ឋានតែសេចក្តីអធិស្ឋានត្រឹមតែមួយប្រយោគ ដោយទូលសុំព្រះទៅតាមពាក្យផ្ទាល់ខ្លួនរបស់ពួកគេ ដើម្បីសុំទ្រង់ជួយបង្រៀនពីសេចក្តីស្រឡាញ់ និងការស្តាប់បង្គាប់ទ្រង់។ ពួកគេអំពាវនាវតាមព្រះនាមផ្សេងៗរបស់ព្រះអង្គ ហើយនិងស្តាព្រះហស្តរបស់ទ្រង់ ដូចដែលបានចែកចាយក្នុងមេរៀនជាគំរូស្រាប់។

សូមពណ៌នា!

- បេសកជន ជាអ្នកទាំងឡាយណាដែលត្រូវបានទទួលការត្រាស់ហៅមកពីព្រះ ដើម្បីបង្រៀនដំណឹងល្អនៃព្រះយេស៊ូវគ្រីស្ទ។
- ជាច្រើនដង មានន័យថា ការធ្វើដំណើរទៅកាន់ប្រទេសឆ្ងាយៗ ហើយរៀនពីភាសាថ្មី និងវប្បធម៌ថ្មី។ នេះជាជីវិតដែលលះបង់ខ្ពស់ និងថ្វាយទាំងស្រុងទៅកាន់ព្រះ។
- ព្រះយេស៊ូវចង់ឲ្យយើងគ្រប់គ្នា ក្លាយជាបេសកជន គ្រប់កន្លែងណាដែលយើងរស់នៅ ហើយក្លាយជាពន្លឺ នៅសាលារៀន និងនៅផ្ទះផងដែរ។

អ្នកប្រហែលចង់ចាប់ផ្តើមដោយជួយកុមារ ចែកចាយរឿងរ៉ាវទាក់ទងនឹងបេសកជនចេញពីពួកជំនុំបស់ពួកគេ ឬអ្នកដែលគេស្គាល់នៅជុំវិញពិភពលោក។ សូមលើកទឹកចិត្តពួកគេឲ្យនិយាយអំពីវិធី ដែលពួកគេអាចចែកចាយព្រះយេស៊ូវ ជាមួយនឹងគ្រួសារ ព្រមទាំងមិត្តភក្តិរបស់អ្នក។

ភាពជាសិស្ស

តើ អ្នកអាចស្តាប់លឺ ទេ?

សុល ពីតើស៊ីស ក្លាយជាប៉ុល ជាសាវ័ករបស់ព្រះយេស៊ូវគ្រីស្ទ កិច្ចការ ៩.១-២២

ប៉ុល មានម្តងអ្នកស្មន់ និងជាសត្រូវរបស់ព្រះគ្រីស្ទ និងអ្នកដើរតាមព្រះអង្គដែរ បានក្លាយជាអ្នកដឹកនាំដ៏មានកិច្ចពលំបំផុត
1 ក្នុងចំណោមអ្នកដឹកនាំឯទៀត ហើយក៏ជាបេសកជនសម្រាប់ដំណឹងល្អ នៅពួកជំនុំនានាដែរ។ ការនេះបានកើតឡើង
នៅថ្ងៃមួយ ដែលម្នាក់ឈ្មោះថា សុល (មុនពេលដែលបានប្តូរឈ្មោះជាប៉ុល)
កំពុងដើតាមផ្លូវទៅក្រុងដាម៉ាស។ ភ្លាមនោះ មានពន្លឺដ៏ភ្លឺមួយពីលើមេឃ
បណ្តាលឲ្យគាត់ដួលចុះដល់ដី។ ពន្លឺនោះបណ្តាលភ្នែកគាត់មិន
អាចមើលឃើញ។ សុលបានលឺសំលេងមួយនិយាយថា
“សុល នែសុល ហេតុអ្វីបានជាអ្នកបៀតបៀនដល់ខ្ញុំដូច្នេះ។”
គាត់ឆ្លើយដោយសួរថា “ឱព្រះអម្ចាស់អើយ ព្រះអង្គណានុ៎ះ?”
រួចគាត់បានលឺនិយាយថា “ខ្ញុំនេះជាព្រះយេស៊ូវ ដែលអ្នកបៀតបៀន
អ្នកធាក់ជល់នឹងជន្លួញដូច្នេះ។” រួចគាត់ក៏ងប្អូរ។ ក្នុងរយៈ ៣ថ្ងៃ
គាត់មើលអ្វីមិនឃើញ ហើយគាត់ក៏មិនបានបរិភោគអ្វីទាំងអស់ដែរ។
មានអ្នកចំរៀព្រះម្នាក់ឈ្មោះ អាន៉ាន៊ាស ដែលព្រះបានចាត់បញ្ជូនឲ្យ
ទៅស្វែងរកសុល។ “អាន៉ាន៊ាស ខ្ញុំបានប្រើឲ្យអ្នកទៅប្រោសភ្នែករ
បស់សុល។ ខ្ញុំបានរើសគាត់ឲ្យក្លាយជាបេសកជន។” លោកអាន៉ាន៊ាស
មិនបានយល់ច្បាស់ពីការនេះទេ។ ព្រោះគាត់បានលឺគេនិយាយពីគ្រប់ទាំងកា
រអាក្រក់ ដែលសុលបានធ្វើទុក្ខដល់គ្រីស្ទាន ប៉ុន្តែ អាន៉ាន៊ាស ស្តាប់បង្គាប់ព្រះ។
ព្រះបានព្យាបាលសុល ហើយសុល ក៏បានចាប់ផ្តើមបង្រៀន និងប្រកាសព្រះបន្ទូលគ្រប់ទីកន្លែងដែលគាត់បានទៅ។
មនុស្សជាច្រើន បានក្លាយជាអ្នកដើរតាមព្រះយេស៊ូវគ្រីស្ទ។ ក្រោយមក ឈ្មោះ សុល ក៏បានប្តូរទៅជា ប៉ុល វិញ។
ក្នុងព្រះគម្ពីរមានជាសំបុត្រ និងសេចក្តីបង្រៀនជាច្រើនរបស់គាត់ ផ្ញើរទៅដល់ពួកជំនុំជាច្រើន។ គាត់បានប្តូរឈ្មោះ
ប៉ុល្លូសវិញ សម្រាប់ព្រះយេស៊ូវ ដែលថ្វាយគ្រប់ទាំងសិរីល្អដល់ព្រះ និងបង្រៀនអ្នកដទៃឲ្យធ្វើដូចជាគាត់ដែរ។

តើ អ្នកអាចធ្វើ វាបានទេ?

- ចូរសម្រេចចិត្តចេញពីចិត្តអ្នកថា ទោះបីជាធ្វើអ្វីក៏ដោយ ក៏អ្នកនឹងធ្វើដើម្បីថ្វាយសិរីល្អដល់ព្រះ។
- ចូរចងចាំថា អំណោយទាន និងលទ្ធភាពរបស់អ្នកបានមកពីព្រះ។
- ចូរឲ្យអ្វីដែលអ្នកធ្វើ ក្លាយជាអំណោយនៃសេចក្តីស្រឡាញ់ដល់ព្រះយេស៊ូវ។
- ចូរទូលសូមព្រះ ឲ្យជួយអ្នកវីរកម្រើនភាពក្លាហានឡើង ដើម្បីនាំអ្នកដទៃទៀតដើរតាមព្រះអង្គ។
- ចូរទូលសូមព្រះ សម្រាប់ឱកាសផ្សាយក្តីស្រឡាញ់ នៅកន្លែងណាដែលយើងទៅ។
- សូមប្រើចលនាដៃ ចាប់តាំងពីការបង្កើត រហូតដល់ព្រះយេស៊ូវគ្រីស្ទ ដើម្បីផ្សាយដំណឹងល្អ ជាមួយនឹងមិត្តភ័ក្តិ
និងក្រុមគ្រួសាររបស់អ្នក។ នេះជាវិធីសាស្ត្រដែលសាមញ្ញ ហើយងាយស្រួល។ នៅលើទំព័រ១០៩
ផ្នែកខាងក្រោយសៀវភៅ។

ភាពជាសិស្ស

សូមសាកល្បង!

ការភ្ជាប់នឹងសំណាញ់

១. សូមបង្ហាញប្រាប់អ្នកលេងនូវព្រំដែនកំណត់ ដែលពួកគេនឹងចាប់ផ្តើមលេង។

២. ដោយសុវត្ថិភាព៖ បើមានអ្នកលេងច្រើននាក់ នោះត្រូវចែកពួកគេជាច្រើនក្រុម ដោយក្មេងអាយុតិចបំផុត លេងកន្លែងមួយ និងក្មេងអាយុច្រើនជាងគេ លេងកន្លែងមួយផ្សេងទៀត។

៣. ចំណុចសំខាន់៖ សូមពន្យល់អ្នកលេង ល្បែងនេះនឹងមិនបញ្ចប់ទេ លុះត្រាតែអ្នកលេងទាំងអស់ចាប់បានសំណាញ់។

៤. ចំណុចសំខាន់៖ សូមជ្រើសរើសអ្នកលេងទាបជាងគេម្នាក់ ត្រូវធ្វើជាម្នាក់ “អ៊ីត/It”។ សូមជ្រើសរើសអ្នកលេងត្រូវធ្វើជា “អ៊ីត/It”។ អ្នកលេងណាដែលត្រូវបានជ្រើសរើស ឱ្យធ្វើជា “អ៊ីត/It” បន្ទាប់មករត់ដេញចាប់អ្នកឯទៀតដោយព្យាយាមទៅ “ប៉ះ/Tag” ម្នាក់ក្នុងចំណោមអ្នកឯទៀត (ប៉ះអ្នកលេងទាំងនោះដោយដៃ) ខណៈអ្នកលេងឯទៀតព្យាយាមរត់គេច។

៥. បើអ្នកលេងម្នាក់ដែលហៅថា “អ៊ីត/It” ប៉ះអ្នកលេងណាម្នាក់ នោះអ្នកទាំងពីរនឹងត្រឡប់ក្លាយជា “អ៊ីត/It” ហើយអ្នកលេងទាំងពីរ ត្រូវកាន់ដៃដោយលាតសន្ធឹងដូចជា “សំណាញ់”។

៦. ពេលដែលអ្នកលេងថ្មីត្រូវបាន “អ៊ីត/It” ប៉ះ ត្រូវចូលរួមជា “សំណាញ់” ដែលអ្នកលេងទាំងនោះកាន់ដៃគ្នាជាជួរវែងមួយ។

៧. សូមបន្តលេងរហូតដល់ “សំណាញ់” នោះ ប្រមូលបានអ្នកលេងទាំងអស់។

៨. សូមបន្តលេងឱ្យបានច្រើនដង តាមពេលដែលបានកំណត់ ហើយពេលនីមួយៗ អ្នកដែលទាបជាងគេត្រូវចាប់ផ្តើមដោយធ្វើជា “អ៊ីត/It”។

- សេចក្តីពិភាក្សានិងជីវិត៖ អ្នកលេងម្នាក់បានចាប់ផ្តើម ដោយចាប់អ្នកលេងតែម្នាក់តែប៉ុណ្ណោះ បន្ទាប់មកសំណាញ់នឹងរីកកាន់តែធំឡើងៗ និងបានចាប់កាន់តែច្រើនឡើងក្នុងពេលតែមួយ ហើយចុងក្រោយនោះនឹងចាប់បានទាំងអស់ដាក់ក្នុងសំណាញ់។ ការបង្កើតសិស្សចាប់ផ្តើមដោយការបង្រៀនមនុស្សតែម្នាក់តែប៉ុណ្ណោះ បន្ទាប់មកវានឹងបន្តធ្វើពហុគុណច្រើនឡើងៗ!

សំណួរ

១. តាមការលេង តើកុមារប៉ុន្មានអ្នក ដែលនឹងត្រូវបានចាប់ដាក់ក្នុងសំណាញ់ ដើម្បីបញ្ចប់ល្បែងកំសាន្តនេះ ៣ ឬ ៤នាក់ ? (គឺគ្រប់គ្នា!) ចាំបន្តិច ចុះតើអ្នកលេងម្នាក់ចាប់បានអ្នកលេងទាំងអស់ដាក់ក្នុងសំណាញ់បាន ដោយរបៀបណា? (ដោយចាប់ផ្តើមតែម្នាក់ រួចវានឹងបន្តធ្វើពហុគុណយ៉ាងរហ័សៗ)។

២. តាមរយៈព្រះគម្ពីរតើព្រះយេស៊ូវបានប្រាប់ឱ្យអ្នកដើរតាមទ្រង់ពួកសិស្សទ្រង់ធ្វើអ្វី?តើព្រះយេស៊ូវបានប្រាប់ពួកសិស្សទ្រង់ ឱ្យបង្កើតសិស្ស តែក្នុងសាសន៍មួយតែប៉ុណ្ណោះមែនទេ? (អត់ទេ គឺគ្រប់សាសន៍ទាំងអស់!)

៣. ឱ ព្រះយេស៊ូវអើយ ទូលបង្គំចង់ស្តាប់បង្គាប់ទ្រង់ ដោយបង្កើតសិស្សគ្រប់ទាំងសាសន៍។ ទូលបង្គំអាចចាប់ផ្តើមកន្លែងនេះថ្ងៃនេះ ដោយអធិស្ឋានសម្រាប់ជាតិសាសន៍ទាំងអស់ ហើយដោយប្រាប់គ្រប់អ្នកដែលទូលបង្គំបានស្គាល់ពីព្រះយេស៊ូវ។ ព្រះអង្គអើយ សូមបង្ហាញទូលបង្គំកន្លែងនេះ នូវមនុស្សទាំងឡាយណាដែលព្រះអង្គចង់ឱ្យទូលបង្គំលើកទឹកចិត្តដោយដើរតាមទ្រង់។ (ឈប់បន្តិច) ព្រះយេស៊ូវអើយ សូមបង្រៀនទូលបង្គំ នូវរបៀបក្លាយជាអ្នកបង្កើតសិស្សដ៏ល្អម្នាក់។

©2018 The Prayer Covenant for Children/Games provided by GameLife77.com. All rights reserved.

ភាពជាសិស្ស

ក្រដាសកិច្ចការ

១ អ្នកជិតចប់មេរៀនហើយ! តើអ្នកចងចាំសេចក្តីអធិស្ឋានជួរទី ៩ អំពីភាពជាសិស្សទេ? សូមសរសេរចុះខាងក្រោម៖

២ បំពេញចន្លោះ

ម៉ាថាយ ២៨.១៩ "ដូច្នេះ ចូរ _____ ឲ្យមាន _____ នៅគ្រប់ _____

ព្រមទាំងធ្វើ _____ដោយនូវ _____ _____ និង _____ ចុះ។

៣ តើបេសកជនជាអ្វី?

៤ តើអ្នក ឬក៏ខ្ញុំអាចក្លាយជាបេសកជន ដោយបង្កើតសិស្ស សូម្បីតែជាមួយនឹងអ្នកជិតខាងយើងបាន យ៉ាងដូចម្តេច?

៥ ពេលឆ្លើយតប៖

សូមប្រាប់ឈ្មោះមនុស្សណាម្នាក់ ដែលអ្នកស្គាល់ ប៉ុន្តែគាត់មិនស្គាល់ព្រះយេស៊ូវនៅឡើយ។
សូមសរសេរឈ្មោះគាត់លើកាតមួយ ហើយប្តេជ្ញាចិត្តអធិស្ឋានសម្រាប់គាត់រាល់ថ្ងៃ។ ចូរចងចាំថា
ព្រះអាចប្រើអ្នក ដើម្បីប្រាប់អ្នកដទៃពីសេចក្តីស្រឡាញ់ទ្រង់បាន។

ភាពជាសិស្ស

ការគោះឡើង!

ខ្ញុំពិតជាចង់បានព្រះទ័យហឬទ័យព្រះ ដើម្បីស្រឡាញ់។

ពិតណាស់ ពិតណាស់!

ខ្ញុំពិតជាចង់បានព្រះទ័យហឬទ័យព្រះ ដើម្បីបំរើ។

ពិតណាស់ ពិតណាស់!

ខ្ញុំដឹងថាព្រះអាចប្រើខ្ញុំ ដូចជាចំណែកតូចមួយរបស់ទ្រង់។

ពិតណាស់ ពិតណាស់!

ដើម្បីចែកចាយរឿងរ៉ាវនៃសេចក្តីស្រឡាញ់ដែលមិនដែលបញ្ឈប់។

ពិតណាស់ ពិតណាស់!

ខ្ញុំចង់ទៅបង្កើតសិស្សក្នុងព្រះនាមព្រះយេស៊ូវ។

ពិតណាស់ ពិតណាស់!

តើអ្នកនឹងចូលរួមចំណែកធ្វើដូចខ្ញុំដែរ ឬទេ?

ពិតណាស់ ពិតណាស់!

គ្រូបង្រៀនអានអក្សរនៅផ្នែកពណ៌ខ្មៅ ហើយកុមារឆ្លើយតប ដោយអានតាមតែនៅផ្នែកពណ៌ខៀវវិញ។ ក្រោយមក សូមលើកទឹកចិត្តពួកគេឱ្យសរសេរលើក្តាគោះរបស់ពួកគេតាមក្រុម ដោយសរសេរសំណួរពរពួកគេនៅលើក្តាខៀន។ សូមមើលចំណាំអារម្ភ ដែលពួកគេគោះនូវអ្វីដែលពួកគេបានសរសេរនោះចុះ!

សិទ្ធិអំណាច



អធិស្ឋានក្នុងព្រះនាមព្រះយេស៊ូវគ្រីស្ទ។
អាម៉ែន

មនុស្សខ្វាក់ម្នាក់ឈ្មោះ បារទីមេ ម៉ាកុស ១០.៤៦-៥២

ភីលីព ២.៩

“ដោយហេតុនោះបានជាព្រះបានលើកទ្រង់យ៉ាងខ្ពស់
ហើយបានប្រទានឲ្យមាននាមដ៏ប្រសើរលើសជាង
អស់ទាំងនាមផង។”

សិទ្ធិអំណាច

តើ អ្នកអាចនិ យាយបានទេ?

អធិស្ឋានក្នុងព្រះនាមព្រះយេស៊ូវគ្រីស្ទ។ អាម៉ែន

ភីលីព ២.៩

“ដោយហេតុនោះបានជាព្រះបានលើកទ្រង់យ៉ាងខ្ពស់ ហើយបានប្រទានឲ្យមាននាមដ៏ប្រសើរលើសជាងអស់ទាំងនាមផង។”

តើនឹងមានការអ្វីកើតឡើង បើអ្នកជាអ្នកគ្រប់គ្រងពិភពលោកនេះ?

ហេតុអ្វីបានជាមានអំណាច ដោយនូវព្រះនាមព្រះយេស៊ូវគ្រីស្ទ?

តើ អ្នកអាចដឹ ងបានទេ?

ហេតុអ្វីជាការល្អ ដែលព្រះយេស៊ូវគ្រប់គ្រងពិភពលោកនេះ?

ហេតុអ្វីយើងគួរអធិស្ឋានក្នុងព្រះនាមព្រះយេស៊ូវគ្រីស្ទ?

តើ អ្នកអាចស្វែងរកបានទេ?

ម៉ាថាយ ១.២១

ម៉ាថាយ ២៨.១៨

យ៉ូហាន ១៤.១៣

កិច្ចការ ៤.១២

សិទ្ធិអំណាច

"ការអធិស្ឋានពោតលើង"

សូមនាំកុមារចំណាយពេលអធិស្ឋានផ្ទាល់ខ្លួនម្តងទៀត ដោយការអធិស្ឋាន "សូមជួយឱ្យទូលបង្គំស្រឡាញ់ និងស្តាប់បង្គាប់ទ្រង់"។ សូមឱ្យកុមារថាតាមសេចក្តីអធិស្ឋាន។ សូមលើកទឹកចិត្តពួកគេឱ្យអធិស្ឋានតែសេចក្តីអធិស្ឋានត្រឹមតែមួយប្រយោគ ដោយទូលសុំព្រះទៅតាមពាក្យផ្ទាល់ខ្លួនរបស់ពួកគេ ដើម្បីសុំទ្រង់ជួយបង្រៀនពីសេចក្តីស្រឡាញ់ និងការស្តាប់បង្គាប់ទ្រង់។ ពួកគេអំពាវនាវតាមព្រះនាមផ្សេងៗរបស់ព្រះអង្គ ហើយនិងស្តាព្រះហស្តរបស់ទ្រង់ ដូចដែលបានចែកចាយក្នុងមេរៀនជាគំរូស្រាប់។

សូមពណ៌នា!

- ព្រះគម្ពីរចែងថា "គ្រប់ទាំងអំណាចបានប្រគល់មកខ្ញុំនៅលើស្ថានសួគ៌ ហើយលើផែនដីផង។" ពេលយើងអធិស្ឋានក្នុងព្រះនាមព្រះយេស៊ូវគ្រីស្ទ យើងមានសិទ្ធិអំណាច។
- មានការលើកឡើងជាសំណួរ៖ បើយើងអធិស្ឋានក្នុងព្រះនាមព្រះយេស៊ូវគ្រីស្ទ តើព្រះឆ្លើយតបគ្រប់ទាំងសេចក្តីអធិស្ឋានរបស់យើង ដែលយើងចង់បានពីទ្រង់ បានដែរឬទេ?
- សេចក្តីអធិស្ឋានរបស់យើងត្រូវផ្តោតលើការ ដែលថ្វាយសិរីល្អដល់ព្រះវរបិតាដែលគង់នៅស្ថានសួគ៌ ហើយមានប្រយោជន៍សម្រាប់អាណាចក្រព្រះអង្គនៅលើផែនដី។

សូមឱ្យកុមារចែកចាយដោយសេរីអំពីជីវិតអធិស្ឋានរបស់ពួកគេ។ តើពួកគេធ្លាប់បានទទួលបានចម្លើយពីការអធិស្ឋានរបស់ពួកគេ ដែរឬទេ? តើពួកគេធ្លាប់បានរសាយចិត្ត ដោយសារពួកគេគិតថាសេចក្តីអធិស្ឋានខ្លះៗ ដែលមិនទទួលបានចម្លើយតាមអ្វីដែលពួកគេសង្ឃឹមទុក?

សិទ្ធិអំណាច

តើ អ្នកអាចស្តាប់លឺ ទេ?

មនុស្សខ្វាក់ម្នាក់ឈ្មោះ បារទីមេ (ម៉ាកុស ១០.៤៦-៥២)

បារទីមេ បានខ្វាក់ ហើយគាត់ជាអ្នកសូមទាននៅមាត់ផ្លូវនៅក្រុងយេរីខូរ។ គាត់ដឹងពីការអស្ចារ្យជាច្រើន ដែលព្រះយេស៊ូវបានធ្វើ។ គាត់ក៏បានលឺនូវរបៀបដែលព្រះយេស៊ូវព្យាបាលអ្នកមានជម្ងឺ មនុស្សខ្វាក់ និងអស់អ្នកដែលមិនអាចដើរបានដែរ។ បារទីមេ ចង់ឲ្យព្រះយេស៊ូវព្យាបាលគាត់ផងដែរ។

គាត់ស្រែកឡើងថា “ឱព្រះយេស៊ូវ សូមអាណិតមេត្តាដល់ទូលបង្គំផង!”

មនុស្សដែលនៅជុំវិញបារទីមេ មិនមានចិត្តល្អឡើយ។ ពួកគេស្រែកកំហែងថា “ឆ្លងនៅស្ងៀម!” តែគាត់ស្រែករឹតតែខ្លាំងឡើងរកព្រះយេស៊ូវ។ ព្រះយេស៊ូវបានលឺគាត់ ក៏មានព្រះបន្ទូលថា “ចូរនាំគាត់មកឯខ្ញុំ។” បណ្តាជនក៏បាននិយាយថា “ចូរសង្ឃឹមចុះ ទ្រង់បានហៅឯងហើយ!” គាត់ក៏បោះអាវធំគាត់ចោល រួចស្ទុះក្រោកទ្រង់ទៅឯព្រះយេស៊ូវ។ ព្រះយេស៊ូវមានព្រះបន្ទូលសួរគាត់ថា “តើចង់ឲ្យខ្ញុំធ្វើអ្វីឲ្យអ្នក?” នោះគាត់ក៏ឆ្លើយឡើងថា “លោកគ្រូអើយ សូមប្រោសភ្នែកទូលបង្គំឲ្យបានភ្លឺឡើង!” ទ្រង់ក៏មានព្រះបន្ទូលទៅគាត់ថា “ទៅចុះសេចក្តីជំនឿអ្នកបានសង្គ្រោះអ្នកហើយ។” បារទីមេ ជឿថាព្រះយេស៊ូវមានអំណាចប្រោសឲ្យជាបាន។ ឥឡូវនេះ អ្នកអាចស្រមៃបានថា តើគាត់សប្បាយចិត្តខ្លាំងយ៉ាងណា ពេលដែលភ្នែករបស់គាត់បានភ្លឺឡើង។ ហើយតើអ្នកអាចស្រមៃថា តើគាត់នឹងមានអារម្មណ៍យ៉ាងណា ពេលដែលយើងបានភ្នែកឡើងឃើញព្រះយេស៊ូវ? គាត់មិននៅដូចពីមុនទៀតឡើយ គឺគាត់បានចាប់ផ្តើមដើរតាមព្រះយេស៊ូវ ហើយបានប្រាប់មនុស្សគ្រប់គ្នាពីការអស្ចារ្យដែលព្រះយេស៊ូវបានធ្វើ។

តើ អ្នកអាចធ្វើ វាបានទេ?

- សូមផ្តោតសេចក្តីអធិស្ឋានរបស់អ្នក លើអ្វីដែលនឹងគាប់ព្រះទ័យព្រះយេស៊ូវ។
- សូមអធិស្ឋានក្នុងព្រះនាមព្រះយេស៊ូវ សម្រាប់ប្រាជ្ញា និងការដឹកនាំ។
- សូមអធិស្ឋានក្នុងព្រះនាមព្រះយេស៊ូវ សម្រាប់ការព្យាបាល និងកំលាំង។
- សូមជឿចេញពីចិត្តរបស់អ្នក ដោយក្នុងព្រះនាមព្រះយេស៊ូវគ្រីស្ទមានអំណាចពិតប្រាកដ។

សិទ្ធិអំណាច

សូមសាកល្បង!

"ធ្វើតាមអ្នកដឹកនាំលេង"

១. សូមពន្យល់អ្នកលេងទាំងអស់ថា ពួកគេជាអ្នកដឹកនាំលេងល្បែងនេះ ហើយពួកគេត្រូវជម្រុញចិត្តអ្នកលេងយ៉ាងណា។

២. អ្នកលេងទាំងអស់ត្រូវបញ្ឈរស្មាទល់នឹងស្មា មាន២ផ្សែងគ្នា តែត្រូវបែរមុខរកគ្នា ដោយនៅជិតល្មមដែលអាចឲ្យដៃសន្ធឹងទៅប៉ះនឹងអ្នកផ្សែងបាន។ ពេលចាប់ផ្តើម អ្នកលេងម្នាក់ត្រូវរត់ពីខាងមុខជួរ រហូតដល់បញ្ចប់ជួរ តាមចន្លោះដៃសន្ធឹងរបស់អ្នកលេងឯទៀត។

៣. ស្តាប់ទៅដូចជាងាយស្រួល? ឈប់សិន! អ្នកដែលរត់ត្រូវរត់ដោយបិទភ្នែក (អាចចងក្រមា ឬ គ្រាន់តែបិទភ្នែក)។

៤. ចំណុចសំខាន់សម្រាប់អ្នកដឹកនាំលេង៖ អ្នកដឹកនាំលេងម្នាក់ឈរចុងបញ្ចប់ជួរ ដើម្បីចាំប្រាប់ឲ្យគេឈប់រត់ពេលគាត់រត់ដល់ទី។ ចំណុចសំខាន់៖ នេះជាការទទួលខុសត្រូវរបស់អ្នកដឹកនាំលេង សម្រាប់សុវត្ថិភាពដល់អ្នកលេងទាំងអស់គ្នា។

៥. ចំណុចសំខាន់សម្រាប់អ្នកលេង៖ ចូរប្រាកដថា អ្នកលេងទាំងអស់ដែលឈរតាមជួរគួរយល់ថា បើអ្នកលេងម្នាក់រត់ខុសផ្លូវ ពួកគេត្រូវជួយដោយប្រើដៃប្រាប់ជាសញ្ញា ឲ្យវិលចូលត្រូវជួរវិញ។

៦. អ្នកលេងម្នាក់ ត្រូវបានជ្រើសរើសឲ្យរត់ រវាងជួរទាំងពីរ ចាប់ពីចំណុចចាប់ផ្តើម ដល់គោលដៅ។

- សេចក្តី ពិ តភ្ជាប់នឹ ងជី វិ ត៖ អ្នកលេងទាំងអស់បានស្តាប់ និ ងធ្វើ តាមអ្នកបង្រៀនលេង ព្រោះពួកគេទុ កចិ ត្តអ្នកបង្រៀនលេងទាំងនោ៖ ដែលយើ ងត្រូ វស្តាប់ "អ្នកបង្រៀនលេង" របស់យើ ង។ សូម្បី តែអ្នក ជឿព្រះយេស៊ូវគួរតែទុកចិ ត្ត ស្តាប់ និ ងធ្វើ តាមព្រះយេស៊ូវ ព្រោះទ្រង់មានគ្រប់ទាំងអំណាចចេស្តា!

សំណួរ

១. តាមការលេងនេះ តើអ្នកគិតថាលំបាកមែនទេ ដែលទុកចិត្តអ្នកដឹកនាំលេង ពេលដែលគាត់ប្រាប់អ្នកឲ្យរត់ទាំងបិទភ្នែកនោះ? ហេតុអ្វីអ្នកស្តាប់តាមអ្នកដឹកនាំលេង ហេតុអ្វី អត្តពលកស្តាប់តាមគ្រូបង្ហាត់ពួកគេ? (គ្រូបង្ហាត់មានបទពិសោធន៍ជាងអ្នក គ្រូបង្ហាត់ចង់ឲ្យអ្នកឈ្នះ គាត់មានគិចនិចបង្រៀន ហើយគាត់ក៏មានចក្ខុវិស័យប្រសើរផងដែរ។

២. ចាប់តាំងពីព្រះបានបង្កើតរបស់ទាំងអស់ ទ្រង់គ្រប់គ្រងទាំងអស់ ហើយព្រះរាជ្យបុត្រាទ្រង់ ព្រះយេស៊ូវគ្រីស្ទ ជាស្តេចលើអស់ទាំងស្តេចផងដែរ នោះតើអំណាចចេស្តាអស្ចារ្យយ៉ាងណា ដែលអាចប្រទានឲ្យ រាល់ពេលដែលអ្នកអធិស្ឋានគាប់ព្រះហឫទ័យទ្រង់ដោយនូវព្រះនាមព្រះយេស៊ូវ? (គ្រប់អំណាចអាចឲ្យបាន)។

៣. ឱ ព្រះអង្គអើយ ទូលបង្គំសូមអរព្រះគុណទ្រង់ សម្រាប់ការបញ្ជូនព្រះយេស៊ូវមកលើផែនដី សូមអរព្រះគុណទ្រង់ដែលទ្រង់អនុញ្ញាតឲ្យទូលបង្គំក្លាយកូនម្នាក់របស់ទ្រង់ ដែលអាចអធិស្ឋានក្នុងព្រះនាមព្រះយេស៊ូវគ្រីស្ទ។ ព្រះអង្គអើយ ទូលបង្គំពឹងផ្អែកលើព្រះវិញ្ញាណបរិសុទ្ធ ដើម្បីដឹកនាំទូលបង្គំ។ ព្រះអង្គអើយ តើទ្រង់នឹងប្រើជីវិតទូលបង្គំបែបណា ដើម្បីថ្វាយសិរីល្អដល់ទ្រង់បាន? (ឈប់បន្តិច) ទូលបង្គំទូលសូមក្នុងព្រះនាមព្រះយេស៊ូវគ្រីស្ទ។

©2018 The Prayer Covenant for Children/Games provided by GameLife77.com. All rights reserved.

សិ ទ្ធិ អំណាច

ក្រដាសកិ ច្ចការ

❶ អបអរសាទរ! អ្នកបានចូលដល់សេចក្តី អធិ ស្ថានបន្ទាត់ចុងក្រោយហើ យ អំពី សិ ទ្ធិ អំណាច! សូមសរសេរចុះខាងក្រោម៖

❷ ចូរបំពេញចន្លោះ

ភី លី ព ២.៩ "ដោយហេតុនោះ បានជាព្រះ _____ ទ្រង់ _____

ហើ យបាន _____ ដ៏ ប្រសើ រ _____ ទាំងនាមផង។

❸ តាមការគិ តអំពី រឿងក្នុងព្រះគម្ពី រថ្ងៃនេះ ហេតុអ្វី អ្នកគិ តថា បារទី មេ ត្រូ វបានព្យាបាលដោយព្រះយេស៊ូវគ្រី ស្ទ? បើ ព្រះយេស៊ូវបានលឺ បារទី មេ តើ ទ្រង់អាចលឺ សំលេងអ្នកដែរទេ? ហើ យបើ ព្រះយេស៊ូវលឺ សំលេងអ្នក តើ ទ្រង់អាចឆ្លើ យតបសេចក្តី អធិ ស្ថានរបស់អ្នក ដូចជាទ្រង់បានឆ្លើ យតបនឹ ងបារទី មេ ដែរទេ? ចម្លើ យនេះ គឺ ត្រឹ មត្រូ វណាស់! អ្នកអាចទូលសូមព្រះឲ្យព្យាបាល ឲ្យផ្តល់កំលាំង ឬ ឲ្យផ្តល់ជំនួយសម្រាប់អ្នក និ ងអ្នកដទៃទៀត ព្រោះព្រះស្តាប់លឺ និ ងអាចឆ្លើ យតបសេចក្តី អធិ ស្ថានបាន!

❹ ពេលឆ្លើ យតប៖

សូមធ្វើ ជាប្រអប់សំណូមអធិ ស្ថានមួយ។ អ្នកអាចប្រើ ប្រាស់ប្រអប់ណាក៏ បាន ដូចជា ប្រអប់ស្បែកជើ ង ឬ ប្រអប់ពី ក្រដាសកាតុងរឹ ងទំហំណាមួយដែលអ្នកជ្រើ សរើ ស។ អ្នកក៏ អាចតុបតែងប្រអប់នោះ ដោយខ្ចប់ក្រដាស ឬ បិ ទស្ទិ កគ័ រ ឬ សរសេរដោយសាមញ្ញថា "ប្រអប់អធិ ស្ថានរបស់ខ្ញុំ"។ សូមសរសេរចុះសេចក្តី អធិ ស្ថានរបស់អ្នក និ ងរក្សាវាក្នុងប្រអប់នោះទុកជាការចងចាំ ក្នុងការអធិ ស្ថានរាល់ថ្ងៃ។ បើ ព្រះឆ្លើ យតបនូវសេចក្តី អធិ ស្ថានរបស់អ្នក ចូរសរសេរចុះដៃក្នុងប្រអប់ ដើ ម្បី អរព្រះគុណដល់ទ្រង់សម្រាប់ការស្តាប់លឺ សំលេង និ ងការឆ្លើ យតបសេចក្តី អធិ ស្ថានរបស់អ្នក!

សិទ្ធិអំណាច

ការគោះឡើង!

ព្រះយេស៊ូវជានាមដែលខ្ពស់លើ សអស់ទាំងនាម!
អាម៉ែន អាម៉ែន!

ក្នុងព្រះនាមព្រះយេស៊ូវ យើងរកឃើញសេចក្តីពិត និងអំណាច!
អាម៉ែន អាម៉ែន!

ក្នុងព្រះនាមព្រះយេស៊ូវ យើងរកឃើញការព្យាបាល និងកំលាំង!
អាម៉ែន អាម៉ែន!

ក្នុងព្រះនាមព្រះយេស៊ូវ យើងរកឃើញសេចក្តីសង្ឃឹម និងអំណរ!
អាម៉ែន អាម៉ែន!

ក្នុងព្រះនាមព្រះយេស៊ូវ យើងរកឃើញព្រះគុណ និងសេចក្តីសុខសាន្ត!
អាម៉ែន អាម៉ែន!

ក្នុងព្រះនាមព្រះយេស៊ូវ យើងរកឃើញសេចក្តីស្រឡាញ់ដែលគ្រប់លើកូណ៎!
អាម៉ែន អាម៉ែន!

គ្រូបង្រៀនអានអក្សរនៅផ្នែកពណ៌ខ្មៅ ហើយកុមារឆ្លើយតប ដោយអានតាមតែនៅផ្នែកពណ៌ខៀវវិញ។ ក្រោយមក សូមលើកទឹកចិត្តពួកគេឱ្យសរសេរលើក្តាគោះរបស់ពួកគេតាមក្រុម ដោយសរសេរសំណូមពរពួកគេនៅលើក្តាខៀន។ សូមមើលចំណាប់អារម្មណ៍ដែលពួកគេគោះស្នូរអ៊ីដែលពួកគេបានសរសេរនោះចុះ!

ឯកសារសេចក្តី សញ្ញាអធិ ស្ឋានរបស់ខ្ញុំ

ឈ្មោះ

កាលបរិច្ឆេទ

©2018 The Prayer Covenant for Children. All rights reserved.

សេចក្តីស្រឡាញ់



©2018 The Prayer Covenant for Children. All rights reserved.

©2018 The Prayer Covenant for Children. All rights reserved.

©2018 The Prayer Covenant for Children. All rights reserved.

©2018 The Prayer Covenant for Children. All rights reserved.

©2018 The Prayer Covenant for Children. All rights reserved.

©2018 The Prayer Covenant for Children. All rights reserved.

©2018 The Prayer Covenant for Children. All rights reserved.

©2018 The Prayer Covenant for Children. All rights reserved.

©2018 The Prayer Covenant for Children. All rights reserved.

ម្រៀបចែងនាដៃអំពីដំណឹងល្អនៃការបង្កើតទៅឯពន្ធកិច្ចរបស់ព្រះគ្រីស្ទ

នេះជាឧទាហរណ៍សម្រាប់កុមារ ដើម្បីចែកចាយដំណឹងល្អ ដោយប្រើកាយវិការដៃ។ សូមធ្វើតាមដ្យាក្រាមនីមួយៗខាងក្រោម ហើយមើលថាតើ វាផ្តល់ភាពរីករាយ និងងាយស្រួលប៉ុណ្ណា ដើម្បីចែកចាយជាមួយមិត្តភក្តិ និងគ្រួសាររបស់អ្នក! នេះជាឧបករណ៍ល្អមួយ ដែលចងភ្ជាប់គ្នាបានល្អ ទៅនឹងសេចក្តីអធិស្ឋានភាពជាសិស្ស "ចូរប្រើទូលបង្គំសម្រាប់សិរីល្អរបស់ទ្រង់ និងសម្រាប់នាំអ្នកដទៃដើរតាមទ្រង់ដែរ។"



១. តាំងពីដំបូងឡើយ ព្រះបានបង្កើតពិភពលោកដ៏ល្អឥតខ្ចោះ។



២. អំពើបាបបានកាត់ផ្តាច់ពិភពលោកដ៏ល្អឥតខ្ចោះ។



៣. ឈ្មួលនៃអំពើបាប គឺជាសេចក្តីស្លាប់។



៤. ព្រះរាជបុត្រារបស់ព្រះ ព្រះយេស៊ូវបានសងថ្លៃរបស់អំពើបាប។



៥. ព្រះយេស៊ូវគឺជាមនុស្សដ៏ឥតខ្ចោះតែមួយគត់។



៦. ព្រះយេស៊ូវបានសុគត។



៧. ព្រះយេស៊ូវបានបញ្ចុះក្នុងផ្នូរ។



៨. ព្រះយេស៊ូវបានរស់ពីសុគតឡើងវិញ។



៩. ព្រោះព្រះយេស៊ូវបានសុគត សម្រាប់គ្រប់រាល់អំពើបាបរបស់អ្នក។



១០. ឥឡូវនេះ ព្រះយេស៊ូវប្រទានឱ្យអ្នកនូវអំណោយដ៏អស់កល្បជានិច្ច។



១១. តើអ្នកពេញចិត្តនឹងអំណោយនេះដែរឬទេ?



១២.ដោយសេចក្តីជំនឿ ចូរទូលសូមព្រះឱ្យទ្រង់ក្លាយជាព្រះអង្គសង្គ្រោះរបស់អ្នក។



១៣. ចូរចែញទៅប្រាប់គេអំពីដំណឹងល្អនេះចុះ!

©2018 The Prayer Covenant for Children/Creation to Christ Hand Motions provided by GameLife77.com and line drawings provided by One Hope. All rights reserved

The PRAYER COVENANT For Children!

ការតាំងសញ្ញានៃការអធិស្ឋានសម្រាប់ធនធានកុមារ

អាចស្វែងរកតាមអ៊ីនធើណេត ដែលមានគំរូសៀវភៅរបស់យើង សៀវភៅតូចៗ
កាតអធិស្ឋាន សៀវភៅផាត់ពំណ៍ និងវីដេអូវគ្គហ្វឹកហ្វឹនដទៃទៀត ការស្តាប់សំឡេង
និងធនធានដែលអាចទាញយកមកប្រើប្រាស់បានដទៃទៀត។

theprayercovenant.org/children

VISION: ចង់ឃើញការភ្ញាក់ឡើងនៃអំណាចដ៏ខ្ពស់បំផុតរបស់ព្រះយេស៊ូវគ្រីស្ទតាមរយៈព្រះបន្ទូលរបស់ទ្រង់។
MISSION: ដឹកនាំកុមារ និងមនុស្សចាស់ឱ្យដើរតាមព្រះយេស៊ូវ តាមរយៈអំណាចនៃការតាំងសញ្ញាអធិស្ឋាន។
ចូលរួមជាមួយចលនានេះនៅថ្ងៃនេះ៖ សម្រាប់ព័ត៌មានបន្ថែម សូមចូលទៅកាន់គេហទំព័រ

ចូរអំពាវនាវដល់អញ នោះអញនឹងឆ្លើយតប ហើយនឹងបង្ហាញអោយឯង
ឃើញការយ៉ាងធំហើយមុតមាំដែលឯងមិនដឹង។ យេរេមា ៣៣: ៣